ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៩**

**សវនាការលើកទី៣១**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc Lavegne)*
លោក ធូ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍
*(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
លោក លឹម ស៊ុយហុង
លោកស្រី សែ កុលវុឌ្ឍី
លោក ម៉ាតូ គ្រីស្ពារ *(Mr. Matteo Crippa)*
កញ្ញា ណាថាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក យ៉េត ចរិយា

លោក វីលៀម ស្មីត *(Mr. William Smith)*

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល

*(Mr. Zachery Lampell)*

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**ជនជាប់ចោទ៖**

លោក កាំង ហ្កេក អ៊ាវ

**មេធាវីការពារជនជាប់ចោទ ៖**

លោក ការ សាវុត្ថ

លោក ហ្វ្រង់ស្វ័រ រូ

*(Mr. François ROUX)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក យុង ផានិត

លោក គីម ម៉េងឃី

លោក ហុង គីមសួន

កញ្ញា ម៉ុច សុវណ្ណារី

កញ្ញា ទី ស្រ៊ីនណា

លោកស្រី ស៊ីលឃីស្ទូត ហ្ស៊ីនស្គី

*(Ms. Silke Studzinsky)*

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

កញ្ញា ចេស្ស៊ីកា ហ្វីណែល

*(Ms. Jessica FINELLE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី** ៖ ជនជាប់ចោទ កាំង ហ្កេកអ៊ាវ ហៅ ឌុច

សួរដោយ លោក យ៉េត ចរិយា ផ្ដើមពី ........ ទំព័រ ៤
សួរដោយ លោក វីលៀម ស្មីត ផ្ដើមពី ........ ទំព័រ ៣៣
សួរដោយ លោក ហុង គឹមសួន ផ្ដើមពី ........ ទំព័រ ៦៤
សួរដោយ កញ្ញា ម៉ុច សុវណ្ណារី ផ្ដើមពី ........ ទំព័រ ៧៩
សួរដោយ លោកស្រី ស៊ីលឃី ស្ទូតហ្សែនស្គី ផ្ដើមពី ........ ទំព័រ ៨៣

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ហុង គឹមសួន | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ៍ន | បារាំង |
| កញ្ញា ម៉ុច សុវណ្ណារី | ខ្មែរ |
| លោក ហ្វ្រង់ស្វ័រ រ៉ូ | បារាំង |
| លោកស្រី សែ កុលវុឌ្ឍី | ខ្មែរ |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលយី ស្ទួតហ្សីនស្គី | អង់គ្លេស |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

[០៩:០៥:៣០]

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះសាលាដំបូង ប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។

ជាដំបូងនេះ ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន ភាគីដែលត្រូវអញ្ជើញចូលរួមដំណើរការសវនាការដេញដោលនៅថ្ងៃនេះ ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរព លោកប្រធាន ។ ភាគីដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះ មានវត្តមានគ្រប់ចំនួន ។

**ប្រធានអង្គជំនុំ៖**

មុននឹងចាប់ផ្តើមដំណើរការពិភាក្សាដេញដោល អង្គជំនុំជម្រះសូមជម្រាបជូនដំណឹងនូវព័ត៌មានមួយចំនួនទាក់ទងទៅនឹងការកំណត់កម្មវិធីសវនាការ ។ អង្គជំនុំជម្រះ សូមជម្រាបដល់ភាគីនូវព័ត៌មានមួយចំនួន ទាក់ទងទៅនឹងកម្មវិធីសវនាការ ។ អង្គជំនុំជម្រះសូមជម្រាបថា អង្គជំនុំជម្រះនឹងរៀបចំនូវកិច្ចប្រជុំរៀបចំសវនាការ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០០៩ នៅវេលារសៀលចាប់ពីម៉ោងមួយកន្លះ ។ កម្មវិធីជំនុំជម្រះសម្រាប់រយៈពេលបីសប្តាហ៍ខាងមុខនេះ អង្គជំនុំជម្រះបានរៀបចំដូចខាងក្រោមនេះ៖

ថ្ងៃច័ន្ទ ទី២២ ខែមិថុនា ដល់ព្រឹកថ្ងៃពុធ ទី២៤ ខែមិថុនា កាលវិភាគភាគីសួរសំណួរដល់ជនជាប់ចោទទាក់ទងទៅនឹងប្រតិបត្តិការ ស-២១ និង ជើងឯក ។

នៅរសៀលថ្ងៃពុធ ទី២៤ ខែមិថុនា ដល់ថ្ងៃច័ន្ទ ទី២៩ ខែមិថុនា អង្គជំនុំជំម្រះ និងភាគីពិភាក្សាដេញដោលដល់ជនជាប់ចោទ លើអង្គហេតុការបង្កើតប្រតិបត្តិការនៃមន្ទីរសន្តិសុខព្រៃស ឬហៅថា ស-២៤ ។

ថ្ងៃអង្គារ៍ ទី៣០ ខែមិថុនា ដល់ថ្ងៃអង្គារ៍ ទី១៤ ខែកក្កដា ឆ្នាំ២០០៩ ស្តាប់ចម្លើយអ្នករស់រានមាន

ជីវិតពីមន្ទីរសន្តិសុខស-២១ មជ្ឈមណ្ឌលភ្នំពេញ ដោយកំណត់រយៈពេលមួយថ្ងៃសម្រាប់ស្តាប់ចម្លើយម្នាក់ ។ នៅក្នុងរួមមាន KW01, D25/3, D25/1, CP1/6, E2/61, E2/23, E2/33, E2/80, E2/32 ។

អង្គជំនុំជម្រះសូមឆ្លៀតយកឱកាសនេះ ដើម្បីទាញនូវចំណាប់អារម្មណ៍ដល់ភាគីថា អង្គជំនុំជម្រះនឹងប្រើនូវរហស្សនាមសម្រាប់សាក្សីដែលមិនទាន់បានផ្តល់នូវសក្ខីកម្ម ហើយនិងប្រើរហស្សនាមសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវស្តាប់ចម្លើយក្នុងដំណាក់កាលនោះ ។ អង្គជំនុំជម្រះសូមជំរុញដល់ភាគីឲ្យបន្តធ្វើដូច្នេះទៀត នៅពេលដែលភាគយោងទៅលើបុគ្គលិកណាមួយក្នុងតុលាការនេះ ។

[០៩:១០:១៥]

ក្នុងគោលបំណងដើម្បីធានាថា សវនាការប្រព្រឹត្តទៅបានឆាប់រហ័ស អង្គជំនុំជម្រះបានធ្វើការពិនិត្យឡើងវិញនូវបញ្ជីឈ្មោះសាក្សី ហើយសូមស្នើកាត់បន្ថយនូវបញ្ជីឈ្មោះសាក្សីនោះ ភាគីនឹងទទួលបានឯកសារបញ្ជីឈ្មោះសាក្សីភ្ជាប់មកជាមួយនឹងកំណត់សម្គាល់ដែលនឹងត្រូវធ្វើការពិភាក្សា ។ អង្គជំនុំជម្រះបានធ្វើការគណនាពេលវេលាថា បើសិនមានការព្រមព្រៀងលើបញ្ហាដែលបានលើកឡើងខាងលើនេះ នៅពេលបញ្ចប់កិច្ចប្រជុំរៀបចំសវនាការ យើងនឹងអាចចំណេញពេលវេលារហូតដល់៣០ថ្ងៃ នៃថ្ងៃធ្វើសវនាការ ។

នេះជាព័ត៌មាន មានការប្រែប្រួលលើកាលវិភាគក្នុងការធ្វើសវនាការនៅក្នុងអំឡុងពេលបីសប្តាហ៍ទៅខាងមុខនេះ ហើយនិងមានការពិចារណារកវិធីសាស្ត្រក្នុងការចាត់វិធានការដំណើរការសវនាការឲ្យបានឆាប់រហ័ស ។ ហើយព័ត៌មានគឺអង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីអម្បាញ់មិញនេះរួចហើយ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទមកកាន់ឈើរាងវង់ក្រចកសេះនៅទីនេះ ។

**លោក វីលៀម ស្មីត៖**

អរុណសួស្តី លោក លោកស្រីចៅក្រម! ប្រសិនបើខ្ញុំសុំអាចលើកបញ្ហាបច្ចេកទេស ដោយសង្ខេបទាក់ទងទៅនឹងការដេញដោលសំណួរទៅកាន់ជនជាប់ចោទនៅព្រឹកនេះ ដូចដែលយើងបានលើកឡើងកាលពីថ្ងៃសុក្រ ។ សហព្រះរាជអាជ្ញានឹងដាក់ឯកសារមួយចំនួននៅចំពោះមុខជនជាប់ចោទ ដើម្បីឲ្យគាត់ផ្តល់យោបល់នៅព្រឹកនេះ ហើយខ្ញុំសួរថាប្រសិនបើអាចធ្វើទៅបាន គឺសុំឲ្យខាងសោតទស្សន៍ធ្វើការផ្លាស់ប្តូរចរន្តរូបភាពមកខាងរូបភាពរបស់សហព្រះរាជអាជ្ញា ហើយអាចភ្ជាប់រូបភាពក្នុងរយៈពេលមួយម៉ោងសាមសិបនាទី។ ហើយនៅពេលដែលយើងដកឯកសារ យើងនឹងត្រឡប់ទៅរូបភាពដើមវិញ។

ហើយយើងនឹងបញ្ជាក់ជូនផ្នែកសោតទស្សន៍ ប្រសិនបើថានៅពេលណាដែលត្រូវមើលដោយជនជាប់ចោទ ហើយត្រឡប់ទៅកាំមេរ៉ារបស់យើងវិញ ដើម្បីធ្វើការផ្លាស់ប្តូរនឹងដំណើរការនីតិវិធីរបស់យើងឱ្យមានប្រសិទ្ធភាព ប្រសិនបើអាចធ្វើទៅបានទៅតាមនេះ ។

[០៩:១៣:១១]

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមលើកជាមតិយោបល់មួយ អ្នកកាសែតទាំងឡាយបានកត់សម្គាល់ថា នៅពេលដែលឯកសារបានបង្ហាញនៅក្នុងអេក្រង់របស់យើង ការបន្តសវនាការរបស់យើងនេះ គឺវាអត់មាន ដូច្នេះគឺវាទាក់ទងទៅនឹងការកត់ត្រានៅក្នុងបណ្ណាសាររបស់យើង ដូច្នេះខ្ញុំសូមរំឮកថា នៅពេលដែលយើងដាក់ឯកសារនៅក្នុងអេក្រង់របស់យើង យើងមិនគួរបង្ហាញនៅក្នុងអេក្រង់នោះរយៈពេលវែងនោះទេ ដោយសារវាមានការបាត់បង់ទៅនឹងការថតយកទៅលើដំណើរការនៅក្នុងបណ្ណសាររបស់យើង ។

*(ចៅក្រមពិភាក្សា)*

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះយល់ព្រមតាមសំណើរបស់តំណាងសហព្រះរាជអាជ្ញាដែលលើកឡើងនេះ ។ ប៉ុន្តែអង្គជម្រះសូមរំឭកថា ទីមួយ អង្គជម្រះផ្តល់អំឡុងពេលក្នុងការធ្វើការដេញដោលដល់តំណាងសហព្រះរាជអាជ្ញានៅក្នុងអង្គហេតុដែលបានកំណត់ គឺប្រតិបត្តិការនៅមន្ទីរសន្តិសុខស-២១ ព្រមទាំងជើងឯកនេះតែបីម៉ោងប៉ុណ្ណោះ ។ ហើយក្នុងអំឡុងពេលបីម៉ោងនេះ គឺយើងគិតនៅក្នុងអំឡុងពេលនៃការដេញដោលសុទ្ធសាត ។ ដូច្នេះ សូមលោកតំណាងសហព្រះរាជអាជ្ញាជ្រាបពីបញ្ហានេះ ។ ហើយទីពីរ ក្នុងករណីដែលមានការបញ្ចាំងនូវឯកសារ ឬក៏រូបភាពផ្សេងៗនោះ គឺមានការរៀបចំដោយលឿននៅពេលដែលចប់ភ្លាម គឺមានការត្រូវការប្តូរប្រព័ន្ធនៃរូបភាពដើម្បីឱ្យបានលឿនតាមដែលអាចធ្វើទៅបាន ។

តទៅនេះ សូមអង្គជម្រះសូមប្រគល់វេទិកានេះជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីដំណើរការនូវកិច្ចពិភាក្សាដេញដោលរបស់ខ្លួន ។ សូមអញ្ជើញ ។

**លោក យ៉េត ចរិយា៖**

សូមអរគុណ លោកប្រធាន ។

អ្វីដែលតំណាងអយ្យការចង់ធ្វើការនៅពេលនេះ គឺបង្ហាញជនជាប់ចោទនូវឯកសារមួយចំនួន

ដែលមានការជឿជាក់យ៉ាងច្បាស់ថា ត្រូវបានសរសេរឡើងដោយជនជាប់ចោទដើម្បីឲ្យជនជាប់ចោទបញ្ជាក់អះអាង នឹងឆ្លើយទៅលើអ្វីដែលគាត់បានធ្វើកន្លងមក ។ តាមរយៈឯកសារទាំងនេះ យើងសង្ឃឹមថា តាមរយៈដំណើរការនេះ យើងនឹងអាចទទួលបានបន្ថែមទៀតលើដំណើរការអំពីតួនាទីពិតប្រាកដរបស់ជនជាប់ចោទក្នុងការចាប់ខ្លួន ការសួរចម្លើយ ការធ្វើទារុណកម្ម និងការសម្លាប់នៅស-២១ ។ យើងចង់សួរបន្ថែមទៀតទៅលើជនជាប់ចោទផងដែរថា ទាក់ទងនឹងការពាក់ព័ន្ធរបស់គាត់ជាមួយនឹងការសួរចម្លើយ ការធ្វើទារុណកម្ម ការសម្លាប់ ម៉ែន សាន ហៅ យ៉ា ។ យើងជឿជាក់ថា ធ្វើដូច្នេះនឹងបង្ហាញឲ្យឃើញអំពីកម្រិតនៃការចូលរួមរបស់ជនជាប់ចោទក្នុងការធ្វើទារុណកម្ម និងការសម្លាប់នៅស-២១ ។

ឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមជាមួយនឹងប្រធានបទ គឺការចាប់ខ្លួន ។ លោកប្រធាន ឥឡូវសុំឲ្យជនជាប់ចោទពិនិត្យមើលឯកសារលេខ E5/2.10 ។ ERN ជាភាសាខ្មែរគឺលេខ 00227230 ភាសាអង់គ្លេសគឺ 00227224 និងភាសាបារាំងគឺ 00294492 ឯកសារនេះមានចំណាររបស់ជនជាប់ចោទទៅលើចម្លើយសារភាពរបស់ ព្រុំ ឃឿន ចុះថ្ងៃទី២៨ ខែ១០ ឆ្នាំ១៩៧៥ ។ សុំឲ្យខាងសោតទស្សន៍បន្តមកកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ។

[០៩:១៨:៣៦]

**ប្រធានអង្គជំនុំ៖**

ចំណែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធរូបភាពទៅកុំព្យូទ័ររបស់តំណាងសហព្រះរាជអាជ្ញា ។

**សួរដោយលោក យ៉េត ចរិយា៖**

បានឃើញឯកសារចំពោះមុខហើយ សូមលោកចាំឆ្លើយនឹងសំណួរដូចតទៅ៖

**ស៖** តើលោកបញ្ជាក់បានទេថា លោកអ្នកសរសេរចំណារនេះ ដែលមានគូសពណ៌ក្រហមជារង្វង់មូលជុំវិញ ។ លោកឆ្លើយថា មែន ឬមិនមែន?

**ឆ៖** ជម្រាបប្រសាសន៍លោកប្រធាន អក្សរនេះ ជាអក្សរខ្ញុំ ។

**ស៖** ជាមួយចំណារនេះ លោកបានសំណូមពរឲ្យចាប់ខ្លួន ព្រុំ ឌួង និង អាង លី នៅលើចម្លើយសារភាព ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៧៥ ខណៈដែលលោកធ្វើជាអនុប្រធានស-២១ ។ តើវារឿងធម្មតារឿងសម្រាប់លោក ដែលលោកស្នើឲ្យចាប់ខ្លួនបុគ្គលណាម្នាក់ ក្នុងនាមលោកជាអនុប្រធាន? សូមលោកបញ្ជាក់ ។

[០៩:២០:០០]

**ឆ៖** លោកប្រធានជាទីគោរព! ដំបូងខ្ញុំសូមជម្រាបអង្គសវនាការទាំងមូល អំពីពាក្យថា "ម-២១" ។ ម-២១ នេះ ជាលេខាធិការដ្ឋានរបស់ ណាត ប្រធានស-២១ ។ ម-២១ នេះស្ថិតនៅក្រោមអំណាចរបស់គាត់ទាំងស្រុង មិនមែនស្ថិតនៅក្រោមអំណាចរបស់អនុប្រធាន ឬគណៈកម្មាធិការនេះទេ ។ ឯកសារមានខ្ញុំអាចបញ្ជាក់ជូនបាន ។ ឯចំណែកចម្លើយដែលមានចំណងជើងថា ព្រុំ ឃឿន នេះបើតាមខ្ញុំវិភាគតាមដានមើលចម្លើយពីមុនមក គឺជាសេចក្តីសរុបរបស់ខ្ញុំទៅលើចម្លើយឈ្មោះ ឡុង សេង ទៅវិញទេ ប៉ុន្តែរឿងនេះយើងកុំនិយាយ ។ ខ្ញុំសូមបញ្ជាក់ជូនអង្គសវនាការទាំងមូលតាមរយៈលោកប្រធានថា ណាត នៅពេលដែលគាត់ធ្វើជាប្រធាន គាត់ប្រើពាក្យ "ម-២១" នេះ ដើម្បីសុំចាប់មនុស្សដែលមិនឆ្លងតាមអង្គការ មានសមត្ថកិច្ច គឺមានន័យថា មិនឆ្លងតាមមេ គឺសេនាធិការទេ ។ ឯកសារមាន ។

ដូច្នេះ ខ្ញុំត្រូវគេបញ្ជាឲ្យសរសេរសង្ខេប ហើយចុងបញ្ចប់មានសំណូមពរបែបនេះ ឯកសារនៅសល់ច្រើន នេះវាច្បាស់លាស់ គឺមានអក្សរថា "ម-២១" នៅហ្នឹង ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។

**ស៖** សំណួរ តើលោកបានរំពឹងទុកថាសំណើរបស់លោកនឹងត្រូវបានអនុញ្ញាតឬទេ? ហើយជនអស់នោះនឹងត្រូវធ្លាក់ចូលក្នុងការសួរចម្លើយនៅស-២១ ឬទេ?

**ឆ៖** តាមខ្ញុំចាំ អាង លី ចូលមកដល់មន្ទីរ ស-២១ ។ ប៉ុន្តែ ព្រុំ ឌួង ខ្ញុំមិនចាំទេ ។

**ស៖** អរគុណ ។ ឥឡូវនេះ សុំមើលឯកសារដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ឧបសម្ព័ន្ធ(គ) 18.81 ERN ជាភាសាខ្មែរលេខ 00001898 ជាភាសាអង់គ្លេសលេខ 00001897 និងជាភាសាបារាំង គឺលេខ 00250332 ។ ឯកសារនេះ គឺជាកំណត់ហេតុស-២១ ធ្វើនៅថ្ងៃ៥ ខែសីហា ឆ្នាំ១៩៧៧ ។ លោកបានពិនិត្យលើឯកសារនេះហើយ ឬនៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ជាទីគោរព! ឯកសារនេះ ខ្ញុំឃើញតាំងពីសម័យស៊ើបអង្កេតម៉្លេះ គឺជាចំណាររបស់ខ្ញុំ ក្រោយអំពីបានទទួលលិខិតមួយដែលមេខ្ញុំប្រគល់មកឲ្យ គឺលិខិតរបស់បង ចេង អន ខាងឧស្សាហកម្ម នៅពេលដែលខ្ញុំទៅធ្វើការនៅនឹងគាត់ ។ ដល់ខ្ញុំចេញត្រឡប់មកផ្ទះវិញ ខ្ញុំចារអានេះដើម្បីបញ្ជាឲ្យគេសួរចម្លើយ ។ រឿងដែលខ្ញុំសុំលោកព្រះរាជអាជ្ញាមេត្តាអនុគ្រោះនៅពេលនេះ សូមឲ្យទាំងអស់គ្នាពិនិត្យមើល ចំណាររបស់ខ្ញុំទៅនឹងខ្លឹមសារបកប្រែ ។ ខ្លឹមសារបកប្រែនេះអត់ត្រូវទេទៅនឹងចំណាររបស់ខ្ញុំ ។ យើងទាំងអស់គ្នាពិនិត្យបញ្ហានេះ ចំពោះមុខច្បាប់ ។

[០៩:២៤:២៥]

**សៈ** នៅក្នុងសំណួរ នៅក្នុងសំណើទី៣ របស់លោកទៅលើកំណត់ហេតុនេះ លោកសរសេរថា "តាមរកខ្សែវាដែលនៅសល់ឲ្យអស់ ហើយចាប់ដាច់ខាត" កំណត់ហេតុនេះ ហាក់បីដូចជាការបញ្ជាជាជាងសំណើ តើលោកឯកភាពដូច្នេះទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំសូមអានខ្លួនឯងឡើងវិញនូវចម្លើយ-- សំណូមពរទីបីរបស់ខ្ញុំ ដែលបញ្ជាទៅឲ្យបង ម៉ម ណៃ ។ "ទីបី តាមរកខ្សែវា ដែលនៅសល់ឲ្យអស់ ហើយឲ្យចំៗ" គឺឲ្យចំ មិនមែនឲ្យចាប់ទេ ។ ដូច្នេះ ខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ដូច្នេះសូមមើលខ្លឹមសារដែលខ្ញុំសរសេរទៅនឹងខ្លឹមសារបកប្រែ យើងទាំងអស់គ្នាពិនិត្យបញ្ហានេះ ។ ទីពីរ ក៏អ៊ីចឹង ។

**សៈ** តើលោកចាប់សំណួរ-- តើលោកចង់ចាប់ខ្លួនមនុស្ស--

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ លោកសហព្រះរាជអាជ្ញា ខ្ញុំសូមទោសដែលខ្ញុំបានឡើងកាត់ បើសិនជាមានបញ្ហានៅក្នុងការបកប្រែឯកសារនេះ គឺយើងត្រូវដោះស្រាយការប្រែនេះជាមុនសិន ។ ហើយខ្ញុំចង់ដឹងថា តើនរណាជាអ្នកបកប្រែឯកសារនេះ? ដូចជាមានការបង្ហាញយ៉ាងច្បាស់ថា គឺការប្រើភាសាដែលថា ត្រូវកំណត់ឲ្យច្បាស់លាស់ ឬក៏ត្រូវចាប់ឲ្យដាច់ខាតនោះ គឺវាមានន័យផ្ទុយគ្នា ។ ដូច្នេះមុននឹងលោកអាចបន្តបានខ្ញុំសូមស្នើឲ្យធ្វើការបញ្ជាក់ថា តើនរណាគេជាអ្នកបកប្រែឯកសារនេះ?

**ប្រធានអង្គជំនុំ៖**

អញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ទាក់ទងទៅនឹងការបកប្រែឯកសារនេះ ដូចជាលោកប្រធាន បានដឹងហើយអំពីទំហំនៃការងារបកប្រែនៅ អ.វ.ត.ក ជួនកាល គឺខាងការិយាល័យសហព្រះរាជអាជ្ញាត្រូវធ្វើការបកប្រែឯកសារអស់ទាំងនុ៎ង ក៏ប៉ុន្តែ ការបកប្រែដែលមានបង្ហាញនៅក្នុងអេក្រង់នោះ គឺគ្រាន់តែជាការចង្អុលបង្ហាញតែប៉ុណ្ណោះ ចំណែកការបកប្រែឯកសារជាផ្លូវការ គឺមាននៅក្នុងសំណុំរឿងរួចទៅហើយ ។ សម្រាប់សវនាការនៅព្រឹកនេះ បើសិនជាមានបញ្ហាទាក់ទងទៅនឹងការបកប្រែ ដូចជា

លោកប្រធានបានដឹងហើយ គឺជាការលំបាកណាស់ ដើម្បីធ្វើការបកប្រែពីភាសាខ្មែរ មកជាភាសាអង់គ្លេស និងភាសាបារាំង ។ ហើយហេតុផលមួយនោះ គឺមានពាក្យមួយចំនួនដែលមិនមាននៅក្នុងភាសាខ្មែរ តែមាននៅក្នុងភាសាអង់គ្លេស ហើយបើសិនជាមានបញ្ហាក្នុងការបកប្រែឯកសារនេះ បញ្ហាតូច ឬក៏បញ្ហាធំ ដែលបានលើកឡើងដោយមេធាវីការពារក្តី ហើយដូចជាលោកប្រធានបានដឹងហើយ គឺយើងបានផ្តល់ឯកសារនេះទៅឲ្យជនជាប់ចោទកាលពីថ្ងៃសុក្រមុន ។ ឯកសារនេះ ក៏មាននៅក្នុងសំណុំរឿងជាច្រើនខែរួចមកហើយ ដូច្នេះ ខ្ញុំសូមឲ្យធ្វើការបកប្រែដែលមានដាក់នៅលើអេក្រង់ គ្រាន់តែជាការណែនាំតែប៉ុណ្ណោះ ។ ហើយបើសិនជាមានបញ្ហាមែន គឺសុំឲ្យជនជាប់ចោទគាត់ធ្វើការចង្អុលបង្ហាញ ហើយត្រូវចាំថា ឯកសារជាភាសាខ្មែរ គឺជាឯកសារគោល ។ នោះ គឺជាអ្វីដែលជនជាប់ចោទគាត់បានសរសេរ ។

[០៩:២៨:២១]

**ប្រធានអង្គជំនុំ៖**

តាមការកត់សម្គាល់របស់អង្គជំនុំជម្រះឃើញថា វាអាចមានបញ្ហាពីរ មិនមែនជាបញ្ហាតែមួយទេ ។ បញ្ហាអម្បាញ់មិញនេះ គឺប្រើពាក្យ សូម្បីតែពាក្យខ្មែរហ្នឹងឯង ការសរសេរហ្នឹងឯង ក៏វាជាការលំបាកនៅក្នុងសំណេរដើម ដែល “ច” និង “ម” អានថាចំ ដែលនៅក្នុងអក្ខរាវិរុទ្ធរបស់ខ្មែរហ្នឹង មិនមានទេ គឺសរសេរ “ច” ដាក់ស្រះ “ំ” ទេ ហើយអ៊ីចឹងវាអាចច្រឡំពាក្យតាំងដើមជាភាសាខ្មែរហ្នឹងថា “ចំ” ឬក៏ “ចាប់” ហ្នឹងឯង វាអាចច្រឡំតាំងពីដើមដោយសារហ្នឹងវាមានការយូរទៅហើយ វានាំឲ្យមានភាពមិនច្បាស់លាស់ ។ នេះហើយ ដែលជាមូលហេតុក៏អាចនាំមកឲ្យការបកប្រែហ្នឹងច្រឡំដែរ ។ អ៊ីចឹងការច្រឡំរបៀបនេះ វាមិនមែនមានន័យថា អង្គជម្រះជាអ្នកទទួលបន្ទុកក្នុងការវិភាគ ក្នុងការពិចារណាថ្លឹងថ្លែងលើការសួរដេញដោលនេះ គឺអាចយល់បាននូវអ្វីដែលជាការលើកឡើងនេះ វិភាគថា តើជាភស្តុតាងដាក់បន្ទុក ឬជាភស្តុតាងដោះបន្ទុក ឬក៏ស្ថានភាពយ៉ាងម៉េច គឺអាចយល់បានបញ្ហាហ្នឹងហើយ ។

ហើយជនជាប់ចោទក៏ខ្លួនឯងក៏បានកត់សម្គាល់ បានន័យថា លោកបានមើលអំពីឯកសារនេះ ហើយបានកត់សម្គាល់នេះជាក់លាក់នៅក្នុងរឿងនេះហើយ គឺថាភាពមិនច្បាស់លាស់នៅក្នុងការ ទាំងការបកប្រែ ទាំងការអាននូវការពាក្យ និងប្រើពាក្យហ្នឹង គឺមានការខុសរហូតដល់គាត់អានខ្លួនឯងបញ្ជាក់ខ្លួនឯង គឺមានភាពច្បាស់លាស់ ហើយយើងផ្ទៀតផ្ទាត់ទៅឃើញច្បាស់លាស់ ។ ហើយដូច្នេះ

អ៊ីចឹង គឺយើងគិតថា មិនមានបញ្ហាអីធំដុំទេ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាបន្តទៀត ។ ហើយធ្វើសូមធ្វើការបញ្ជាក់ដូចអម្បាញ់មិញនេះ ដែលក្នុងករណីណាដែលវាមានការមិនច្បាស់លាស់ ។

[០៩:៣០:០០]

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** អរគុណលោកប្រធាន ។ សំណួរមួយទៀត តើលោកចង់ចាប់ខ្លួនមនុស្សជាច្រើននិងបញ្ជូនមក ស-២១ ឬ? តើលោកឯកសារភាពចំណុចនេះទេ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! មុននឹងខ្ញុំចូលទៅដល់ការឆ្លើយនូវសំណួររបស់លោក ខ្ញុំសូមអនុញ្ញាតបញ្ជាក់ជូនលោកថា ការបកប្រែអត្ថបទអំមិញនេះ សូម្បីតែ (ខ)ទី២ ក៏ខុសដែរ ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ហើយឥឡូវខ្ញុំសូមឆ្លើយទៅនឹងសំណួររបស់លោក ។

ខ្ញុំអត់មានចេតនាចង់ចាប់មនុស្សចូលមកមន្ទីរ ស-២១ ទេ នេះសូមបញ្ជាក់ជូនដោយខ្លីប៉ុណ្ណេះ ។

**ស៖** ជាចុងក្រោយលើអង្គហេតុនៃការចាប់ខ្លួន សូមមើលឯកសារដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺឧបសម្ព័ន្ធ “គ” លេខ ERN ជាភាសាខ្មែរ គឺ 0002--00002476 និងភាសាអង់គ្លេស 00001904 ។ ERN ជាភាសាបារាំងគ្មានទេ ។ ឯកសារនេះ គឺមានចំណាររបស់ជនជាប់ចោទលើចម្លើយសារភាព ស-២១ របស់ មុត ហេង ដែលបានធ្វើឡើងនៅថ្ងៃទី២២ ខែមិថុនា ឆ្នាំ១៩៧៨ ។ សំណួរ តើលោកអាចបញ្ជាក់បានទេថា លោកជាអ្នកសរសេរចំណារនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ចំណារនេះ គឺជាចំណាររបស់ខ្ញុំ ។

**ស៖** សំណួរបន្ត ។ នៅក្នុងចំណារនេះ លោកសរសេរថា “ដកវាជាបន្ទាន់ ចាប់ហើយ វាយសួរចម្លើយទៅ ។ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៧៧” លោកធ្លាប់បាននិយាយថា នៅក្នុងឆ្នាំ១៩៧៨ គឺវាជាឆ្នាំមមាញឹកមួយរបស់លោក តើយើងអាចឯកភាពគ្នាថា នេះគឺជាបញ្ជាឲ្យចាប់ខ្លួនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំសូមឆ្លើយនឹងសំណួរនេះវែងបន្តិច ប៉ុនឲ្យច្បាស់។ ឯកសារដើមមិនមែនចម្លើយរបស់មិត្ត មុត ហេង ទេ បើតាមឃើញប៉ុននុ៎ង គឺជាប្រវត្តិរូបរបស់មិត្ត មុត ហេង ដែលនៅក្នុងកណ្ដាប់ដៃ មិត្តហ៊ី គេកាន់កាប់ ។ ដល់មិត្ត មុត ហេង នេះ មានបាតុភាព មិត្តហ៊ី គេរាយការណ៍នឹងបាតុភាព រួមទាំងប្រវត្តិរូបនេះមកឲ្យខ្ញុំ ឲ្យខ្ញុំទៅស្នើយោបល់ខាងលើ ។ ដល់ខ្ញុំបានយោបល់សម្រេចពីខាងលើហើយ ខ្ញុំចារនៅលើប្រវត្តិរូបដែលនៅក្នុងដៃខ្ញុំស្រាប់ ឲ្យទៅមិត្តហ៊ី គេចាត់ចែងសួរចម្លើយ ។ នេះជារឿងដែលខ្ញុំគិតថា រឿងកន្លងមកហើយវាអាចអ៊ីចឹង ។ នេះខ្ញុំសូមបញ្ជាក់ជូន

លោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។ សូមចប់ ។

**ស៖** អរគុណ ។ សំណួរបន្ត តាមឧទាហរណ៍នេះ លោកមានការទទួលខុសត្រូវដោយផ្ទាល់ សម្រាប់មនុស្សណា ដែលត្រូវបានចាប់ខ្លួន ឬមនុស្សណាមិនត្រូវបានចាប់ខ្លួន តើលោកឯកភាពទេ បញ្ហានេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញាជាទីគោរព! បុគ្គលិកនៅមន្ទីរ ស-២១ យើងខ្ញុំបាន រាយការណ៍បាតុភាពជូនទៅខាងលើ ហើយខាងលើអនុម័តសម្រេចបានៗយើងខ្ញុំចាប់ ។ ចំនួនមនុស្ស ប្រហែលជាមួយរយប្ដាយ ឬពីររយនាក់ ។ នេះតាមតួលេខដែលខាងសហព្រះរាជអាជ្ញាលោកបានមាន ប្រសាសន៍ប៉ុន្មានថ្ងៃមុននេះ ។ ដូច្នេះ នៅស-២១ ដំណើរការចាប់មនុស្សគឺអ៊ីចឹង ។ ខាងក្រោមជាអ្នកស្នើ អចិន្ត្រៃយ៍ជាអ្នកសម្រេច ។ ខ្ញុំជាអ្នកស្នើតាមការឯកភាពគ្នាក្នុងឋានៈ ហើយអចិន្ត្រៃយ៍ ឬពួនួន ឬបង ខៀវ ឈ្មោះដើម សុន សេន ជាអ្នកសម្រេច ។ សរុបមកជាងមួយរយនាក់ ជិតទៅពីររយនាក់ ។ នេះ សូមជ្រាប សូមជម្រាបសូមលោកព្រះរាជអាជ្ញាប៉ុណ្ណឹង ។

[០៩:៣៥:០០]

**ស៖** អរគុណ ។ សំណួរដែលមិនពាក់ព័ន្ធនឹងឯកសារ ។ សំណួរ តាមការអះអាងរបស់លោក ចំពោះមុខសវនាការនេះ កុមារដែលមកជាមួយឪពុកម្ដាយ ត្រូវបំបែកចេញពីឪពុកម្ដាយ ដោយយក ឪពុកម្ដាយទៅឃុំ ឯកុមារទាំងនេះយកទៅសម្លាប់ ។ កុមារខ្លះយកទៅសម្លាប់ភ្លាម កុមារខ្លះមិនត្រូវ សម្លាប់ភ្លាមទេ ។ កុមារដែលមិនសម្លាប់ភ្លាម តើយកទៅឃុំនៅកន្លែងណា?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការណ៍នេះ ខ្ញុំមិនដិតដល់ ដូច្នេះមិនជាក់ស្ដែង គ្រាន់តែឃើញឯកសារនៅសល់ គេប្រមូលពីស្រែមកមួយរយហុកសិបនាក់យកទៅសម្លាប់ ។ ដូច្នេះ ខ្ញុំ ឃើញឯកសារនេះ សូមសន្និដ្ឋានជូនអង្គសវនាការទាំងមូល តាមរយៈលោកព្រះរាជអាជ្ញាថា កុមារទាំង អស់បំបែកចេញពីឪពុកម្ដាយ មួយភាគធំយកទៅស្រែ ព្រៃស ។ តែប្រហែលអាចមានខ្លះបំបែកពីឪពុក ម្ដាយហើយទៅកម្ទេចក្បែរៗមជ្ឈមណ្ឌលភ្នំពេញ ក្បែរៗបរិវេណវិទ្យាល័យពញាយ៉ាត ។ នេះសូម ជម្រាបជូនលោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**ស៖** ពេលរង់ចាំការសម្លាប់ រយៈពេលហ្នឹង តើមានឱ្យម្ហូបអាហារទៅលើកុមារនោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំនិយាយនេះ តាមសន្និដ្ឋានទេ ព្រោះខ្ញុំបាទ អត់ ទៅមើលច្បាស់ហ្នឹងភ្នែក ហើយក៏មិនបានណែនាំអីច្បាស់លាស់ទេ ។ ម្ហូបអាហារមាន ក៏ប៉ុន្តែ ក្នុង

លក្ខណៈអត្តខាត់ដូចគ្នានឹងជនងរគ្រោះនៅឯខាងព្រៃសនោះដែរ មិនបរិបូរណ៍ទេ ។

**ស៖** អរគុណ សំណួរមួយទៀត ។ អ្នកទោសដែលឃុំយូរជាងគេ មានរយៈពេលប៉ុន្មានខែ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំមិនចាំទេ ។

**ស៖** តើលោកនៅចាំឈ្មោះអ្នកទោសនោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។ ខ្ញុំអត់បានបូកសរុបទេ ក៏ប៉ុន្តែ បើសិនឲ្យខ្ញុំឆ្លើយតាមវិភាគ និងសន្និដ្ឋាន ប្រហែលជាមានម្នាក់ដែលយូរជាងគេ គឺលោកគ្រូ លោកសាស្ត្រាចារ្យ ភីង តុន តែប៉ុណ្ណោះ ជាង១០ខែ ។

[០៩:៣៨:០៨]

**ស៖** បើឃុំយូរដូចលោកអះអាងនេះ បណ្តាលឲ្យសក់ក្បាលអ្នកទោស ដែលឃុំខ្លួននោះវែង តើមានជាងកាត់សក់ឲ្យពួកគាត់ទេ?

**ឆ៖** ជម្រាប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំមិនដិតដល់បញ្ហានេះទេ ។

**ស៖** អ្នកទោសមានច្រើន ត្រូវប្រើខ្នោះដៃ ខ្នោះជើងច្រើន តើខ្នោះដៃ ខ្នោះជើងទាំងនោះ អ្នកណាជាអ្នកផ្តល់ឲ្យ និងធ្វើដោយអ្នកណា?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្នោះដៃ ខ្នោះជើង ខ្នោះដៃប្រមូលពីប៉ូលិសសង្គមចាស់ អាខ្នោះដៃអូតូម៉ាទិច ហើយក៏ដូចអាលេខ៨ដែរ ។ ឯចំណែក ខ្នោះជើងក៏អាចប្រមូលចេញពីគុកធំ គុកព្រៃស អីៗច្រើនដែរ ក៏ប៉ុន្តែអាចមានធ្វើថែមនេះខ្នោះជើង វាជារនងហើយនិងកង ។ ដូច្នេះ វាមិនពិបាកអីនឹងធ្វើទេ ។

**ស៖** អរគុណ ។ អ្នកទោសទាំងអស់ត្រូវឃុំក្នុងបន្ទប់ទាំងយប់ទាំងថ្ងៃ ម្ហូបអាហារមិនគ្រប់គ្រាន់ តាមដឹងពេលយប់មានបើកភ្លើងតាមបន្ទប់ឃុំខ្លួននីមួយៗ ។ ពេលនោះមានសត្វល្អិតមកលេងភ្លើង ហើយសត្វនោះធ្លាក់មកក្រោម ។ អ្នកទោសនៅទីនោះតែងតែចាប់សត្វល្អិតទាំងនោះស៊ីដើម្បីបំបាត់ការស្រេកឃ្លាន តើលោកដឹងទេបញ្ហានេះ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំមិនដឹងទេ ប៉ុន្តែបាតុភាពនេះ ខ្ញុំជឿ ។

**ស៖** លោកជឿថាមាន?

**ឆ៖** បាទ ខ្ញុំជឿ ខ្ញុំជឿដោយស្មោះ ។

**ស៖** លោកថា រយៈពេលការឃុំខ្លួនអ្នកទោសនៅស-២១ មុននឹងយកទៅកម្ទេច គឺអាស្រ័យទៅលើការសួរចម្លើយចប់ ឬមិនទាន់ចប់ ។ ចុះចំណែក ការឃុំខ្លួនលើលោកគ្រូ ភឹង តុន មានរយៈពេលជិតម្ភៃខែ និង កែ គឹមហួត មានរយៈពេលជិតដប់បួនខែ ដែលត្រូវជាគ្រូរបស់លោក គឺពួកគាត់ត្រូវបានឃុំខ្លួនយូរជាងគេ បើប្រៀបធៀបជាមួយអ្នកទោសសំខាន់ៗផ្សេងទៀត ។ សំណួរសួរថា ហេតុអ្វីបានជារយៈពេលនៃការឃុំខ្លួនរបស់ពួកគាត់ មានរយៈពេលយូរយ៉ាងនេះ សូមលោកបញ្ជាក់ទៅមើល?

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមទោសលោកប្រធាន! ខ្ញុំចង់ធ្វើការបញ្ជាក់បន្តិច ខ្ញុំគិតថាអាចជាបញ្ហានៃការបកប្រែ គឺខ្ញុំឮដូចថា មានរយៈពេលម្ភៃខែ សម្រាប់លោកគ្រូ ភឹង តុន ។ តើលោកអាចបញ្ជាក់បានទេថា រយៈពេលម្ភៃខែហ្នឹងត្រឹមត្រូវ ឬក៏អត់?

[០៩:៤១:២៨]

**លោក យ៉េត ចរិយា៖**

សូមបញ្ជាក់ថា នេះតាមឯកសារ ។

**ជនជាប់ចោទ៖**

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! លោកគ្រូ កែ គឹមហួត ខ្ញុំដឹង ។ គាត់ធ្លាក់ខ្លួនទៅដល់ស-២១ ខ្ញុំដឹង ដឹងច្បាស់ដែលទុកយូរជាងគេ ពីព្រោះខាងលើត្រូវការសេចក្តីសារភាព អ៊ីចឹងហើយបានតម្រូវឲ្យខ្ញុំប្តូរអ្នកសួរពី ចុះឡើងរហូតដល់ មិត្តទុយ ។ ឯចំណែក លោកសាស្ត្រាចារ្យ ភឹង តុន ខ្ញុំអត់ដឹងទេ ដូចខ្ញុំជម្រាបដដែលៗ អត់ដឹងទេ អត់ដឹងថាគាត់ធ្លាក់ខ្លួនទៅដល់ហ្នឹងទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណោះ ។ ខ្ញុំជឿថា ដោយមិនដឹងអ៊ីចឹង ហើយឃើញឯកសារថា ឃើញគាត់ឈឺខ្លាំង ពេលក្រោយមកបានខ្ញុំជឿថា ប្រហែលជាគាត់ស្លាប់ ដោយជំងឺ ឬក៏ដោយសារអត់បាយ រួមផ្សំគ្នា ។ នេះខ្ញុំជឿអ៊ីចឹងនេះតាមការវិភាគរបស់ខ្ញុំ ដែលខ្ញុំសរសេរទៅជូន D25/5 ។ នេះខ្ញុំវិភាគអ៊ីចឹង នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង ។

**លោក យ៉េត ចរិយា៖**

អរគុណ ឥឡូវនេះ ខ្ញុំសូមចូលទៅកាន់ប្រធានបទទីពីរ គឺការសួរចម្លើយ ។ លោកប្រធានសុំឲ្យខាងសោតទស្សន៍ តភ្ជាប់មកកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ អនុវត្តតាមសំណើរបស់តំណាងសហព្រះរាជអាជ្ញា ។

**លោក យ៉េត ចរិយា៖**

លោកប្រធាន ខ្ញុំសុំឲ្យជនជាប់ចោទពិនិត្យមើលឯកសារសំណុំរឿងលេខ D58/2 ឧបសម្ព័ន្ធលេខ13 ERN ជាភាសាខ្មែរគឺ 00172738 ជាភាសាអង់គ្លេសគឺ 00223140 និងជាភាសាបារាំងគឺ 00296036 ឯកសារនេះមានចំណារដែលគេជឿជាក់ថាត្រូវធ្វើឡើង ដោយជនជាប់ចោទនៅលើចម្លើយសារភាព ស-២១ របស់ លី ផែល ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៧៦ ។

**ប្រធានអង្គជំនុំ៖**

លោកជនជាប់ចោទ មិនបាច់ចម្លើយទេ ព្រោះសំណួរនេះមានការច្រំដែល បានន័យថាយើងធ្វើច្រើនលើក ច្រើនសាហើយ ។ សូមលោកតំណាងសហព្រះរាជអាជ្ញា បន្តនូវសំណួរផ្សេងទៀត ។

[០៩:៤៤:២៩]

**លោក យ៉េត ចរិយា៖**

សហព្រះរាជអាជ្ញាគ្រាន់តែចង់ឲ្យឆ្លើយបញ្ជាក់ថា មែន ឬមិនមែនតែប៉ុណ្ណោះ ។

**ប្រធានអង្គជំនុំ៖**

យើងនៅចាំថា អង្គជំនុំជម្រះបានដេញដោលច្រើនជាអតិបរិមា ។

**សួរដោយលោក យ៉េត ចរិយា៖**

អរគុណលោកប្រធាន ។

**ស៖** ឥឡូវនេះ សូមលោកមើលឯកសារបន្តទៀត ដែលមានលេខ D58/11 ឧបសម្ព័ន្ធ១៣ ERN ជាភាសាខ្មែរ 00172716 និងភាសាបារាំង 00296036 ជាភាសាអង់គ្លេសមិនមានទេ ។ ឯកសារនេះជាចម្លើយសារភាពរបស់ស-២១លើ លី ផែល ដដែល ។ តើលោកប្រធានអនុញ្ញាតឲ្យជនជាប់ចោទឆ្លើយបានទេ?

**ឆ៖** លោកព្រះរាជអាជ្ញាជាទីគោរព! ខ្ញុំមើលអក្សរខ្មែរហ្នឹងអត់ដាច់ទេ ។ សូមឲ្យគេពង្រីកឲ្យធំបន្តិចមក បើមានលទ្ធភាពធ្វើទៅបាន ។

**ស៖** លោកមើលច្បាស់ហើយ ឬនៅ?

**ឆ៖** បានមើលច្បាស់ហើយ អរគុណ ។

**ស៖** តើលោកអាចបញ្ជាក់បានទេថា លោកជាអ្នកសរសេរកំណត់ហេតុនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អក្សរមិត្តប៉ុន រាយការណ៍មកខ្ញុំ ។ អក្សរមិត្តប៉ុនទេ ហើយខ្ញុំសង្ស័យថា ចំណារនេះនៅលើសំណួររបស់ រស់ ភួន ទៅវិញ ។ ឥឡូវសូមលោកមេត្តាលោកបញ្ជាក់មើល ថាជាសំណួររបស់ រស់ ភួន ឬ លី ផែល? ក៏ប៉ុន្តែអក្សរនេះ ពិតជារបស់ មិត្តប៉ុនហើយ ដែលរាយការណ៍មកឲ្យខ្ញុំ ។

[០៩:៤៧:១៨]

**ស៖** គឺលើកំណត់ហេតុរបស់ លី ផែល ។

ជាចុងក្រោយ លើប្រធានបទសួរចម្លើយ ឥឡូវនេះសូមមើលឯកសារសំណុំរឿងលេខ E5/2.24 ERN ជាភាសាខ្មែរគឺលេខ 00228010 ជាភាសាអង់គ្លេស គឺលេខ 00284048 និងជាភាសាបារាំងលេខ 00294514 ដល់ 00284516 ។ ឯកសារនេះ គឺមានចំណាររបស់ជនជាប់ចោទ ទៅនឹងចម្លើយសារភាពស-២១ របស់ ស្នួន សន ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៧៧ ។ លោកបានឃើញនៅក្នុង--ជាថ្មីម្តងទៀត តើលោកអាចបញ្ជាក់អះអាងបានថា ចំណារទាំងនេះជាចំណាររបស់លោកឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ។ ពិតជាចំណាររបស់ខ្ញុំ ។

**ស៖** នៅក្នុងចំណារទាំងអស់នេះ លោកហាក់ដូចជា មានការខ្វល់ខ្វាយយ៉ាងខ្លាំង អំពីអ្នកសួរចម្លើយរបស់លោក មិនបានបំពេញភារកិច្ច របស់ពួកគេឲ្យបានត្រឹមត្រូវ ។ តើនេះត្រឹមត្រូវ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការមិនបំពេញភារកិច្ចឲ្យបានត្រឹមត្រូវ វាជាបញ្ហាមួយដែលខ្ញុំយកចិត្តទុកដាក់ ហើយជាពិសេស បើតាមខ្លឹមសារក្នុងនេះគឺចម្លើយនេះ មិត្ត ឈុន ធំ នេះអាចធ្វើឲ្យរាលដាលផង ជាពិសេស រាលដាលដល់ បង សាម កម្មាភិបាលជើងចាស់ម្នាក់នៅឃុំប្រាំបីមុំ ស្រុកថ្កូង ខេត្តកំពង់ស្ពឺ ដែលជាមូលដ្ឋានជើងចាស់ ដែលជាមូលដ្ឋានបដិវត្តន៍ចាស់ បង្អែកបដិវត្តន៍ ។ នេះសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាប៉ុណ្ណោះ ។

[០៩:៥០:១០]

**ស៖** នៅត្រង់ចំណារដដែលនេះ បានបង្ហាញឲ្យឃើញត្រង់ *អាយវី* លោកនិយាយថា លោកបានបញ្ជូនអ្នកសួរចម្លើយឈ្មោះ ឈុន ឲ្យទៅស្រែយូរបន្តិចដែរហើយ ។ តើលោកបញ្ជូនឈ្មោះ ឈុន ទៅស្រែមែន ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំបានបញ្ជូន មិត្តឈុន ឲ្យទៅស្រែមែន សូមបញ្ជាក់ថា បញ្ជូនឲ្យទៅស្រែនេះ គឺឋិតនៅក្នុងអង្គភាពរបស់ស-២១ ដដែល មិនមែនទៅជាអ្នកទោសទេ ។ ដូច្នេះ ដកចេញសិទ្ធិចេញពីអ្នកសួរ ទៅជាអ្នកដឹកនាំគេបង្កបង្កើនផលនៅស-២១ មជ្ឈមណ្ឌលព្រៃសទៅវិញ ។ នេះសូមបញ្ជាក់ជូនលោកព្រះរាជអាជ្ញាប៉ុណ្ណេះ សូមអស់ ។

**ស៖** ដោយមានការអនុញ្ញាតពីអង្គជំនុំជម្រះ ឥឡូវនេះ ខ្ញុំសូមចាប់ផ្តើមសួរសំណួរទាំងឡាយទាក់ទងទៅប្រធានបទទីបីរបស់យើង គឺការធ្វើទារុណកម្ម ។

លោកប្រធាន ឥឡូវនេះ សុំឲ្យជនជាប់ចោទមើលឯកសារលេខ D58/11 ឧបសម្ព័ន្ធ E24 ERN ជាភាសាខ្មែរលេខ 00172792 ជាភាសាអង់គ្លេសលេខ 00223142 និងជាភាសាបារាំងលេខ 00296037 ។ ឯកសារនេះ មានចំណាររបស់ជនជាប់ចោទ ទៅលើចម្លើយសារភាពរបស់ឈ្មោះ អ៊ុំ សឿន ដែលស្រង់ដោយមន្ទីរស-២១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៥ ។

សំណួរ ជនជាប់ចោទអាចបញ្ជាក់បានទេថា តើលោកឬជាអ្នកដែលបានសរសេរចំណារពណ៌ក្រហមនៅលើចម្លើយសារភាពនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ចំណារខ្ញុំ បញ្ជាទៅឲ្យគេធ្វើទារុណកម្ម ។

**ស៖** តើការវាយតម្លៃលើចម្លើយសារភាពទាំងឡាយ គឺឋិតនៅក្នុងដំណើរការជាធម្មតារបស់លោកនៅស-២១ ឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បញ្ហានេះមានពីរ ទីមួយ អ្នកទោសាមញ្ញ ដូច អ៊ុំ សឿន នេះ វាឋិតនៅក្របខ័ណ្ឌសម្រេចរបស់ខ្ញុំដោយផ្ទាល់ ។ ចំណែក មនុស្សសំខាន់ទាមទារសេចក្តីសម្រេចពីខាងលើ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[០៩:៥៣:៣២]

**ស៖** អរគុណ ។ ឥឡូវនេះ សូមអញ្ជើញមើលឯកសារ សំណុំរឿងលេខ D58/11 ឧបសម្ព័ន្ធទី២ ERN ជាភាសាខ្មែរលេខ 00172772 ភាសាអង់គ្លេសលេខ 00225275 និងភាសាបារាំងលេខ 00250642 ។ ឯកសារនេះ មានចំណារមួយរបស់ជនជាប់ចោទ ទៅលើចម្លើយសារភាព របស់ឈ្មោះ ដាញ់ ស៊ីយ៉ាន ដែលដកស្រង់ដោយមន្ទីរស-២១ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ១៩៧៦ ។

សំណួរ ជនជាប់ចោទអាចបញ្ជាក់បានថា អក្សរពណ៌ក្រហមនេះជារបស់លោកឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អក្សរក្រហមនេះ ពិតជារបស់ខ្ញុំ ។

**ស៖** តើធ្វើដូចម្ដេចទើបលោកដឹងថា អ្នកស្រី ដាញ់ ស៊ីយ៉ាន មិនបាននិយាយការពិតអំពីបទពិសោធន៍នៅប្រទេសវៀតណាមរបស់គាត់ទេនោះ?

**ឆ៖** ខ្ញុំសុំអានជាភាសាខ្មែរ ចំណារខ្ញុំ ។ ចំណាររបស់ខ្ញុំជាភាសាខ្មែរគឺ "សួរឲ្យច្បាស់ បូកទារុណកម្មឲ្យធ្ងន់មធ្យម" ទិសដៅនៃការសួរចម្លើយដែលខ្ញុំផ្ដល់ដល់អ្នកសួររបស់ខ្ញុំគឺ ទិសដៅរកខ្សែសង្វាក់ ។ ក៏ប៉ុន្តែ ជាយុទ្ធវិធី គឺខ្ញុំបញ្ជាគេឲ្យឈប់ ឲ្យវាយ ទាល់តែនាង ដាញ់ ស៊ីយ៉ាន ឈប់និយាយថាទៅស្រុកយួន ទៅវៀតណាម ដើម្បីឲ្យជីតាព្យាបាលម្រេញ ហើយនិងខ្លួនគាត់ទៅព្យាបាលជំងឺរាំងថ្ងៃខែនេះខ្លឹមសារដែលខ្ញុំចារ ដូច្នេះ ក្នុងឯកសារនេះខ្ញុំមើល ។ សរុបមក ខ្ញុំឃើញថា នាង ដាញ់ ស៊ីយ៉ាន អត់ទាន់ឆ្លើយអីច្បាស់លាស់ទេ ហើយបែបមកយូរថ្ងៃដែរហើយ នេះខ្ញុំសម្រេចអ៊ីចឹង ណែនាំទៅកូនចៅ ។ សូមជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញាប៉ុណ្ណេះ ។

**ស៖** ប្រធានបទទាក់ទិននឹងការធ្វើទារុណកម្ម ។ សូមលោកប្រធាន ឥឡូវនេះ សុំឲ្យជនជាប់ចោទមើលឯកសារលេខ D58/11 ឧបសម្ព័ន្ធទី២៤ ERN ភាសាខ្មែរលេខ 00172792 ភាសាអង់គ្លេសលេខ 00223142 និងភាសាបារាំងលេខ 002996037 ។ ឯកសារនេះមានចំណារមួយរបស់ជនជាប់ចោទ នៅលើចម្លើយសារភាពរបស់ឈ្មោះ អ៊ុំ សឿន ដែលដកស្រង់ដោយមន្ទីរស-២១ ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ១៩៧៥។ សំណួរជនជាប់ចោទ អាចបញ្ជាក់បានទេថា តើលោកឬជាអ្នកដែលបានសរសេរចំណារពណ៌ក្រហម ទៅលើចម្លើយសារភាពនេះ?

សុំទោសលោកប្រធាន ខ្ញុំអានច្រឡំប្រធានបទ ។ សូមមើលឯកសារ ដែលមានក្នុងឧបសម្ព័ន្ធលេខ 35.35 ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ERN ជាភាសាខ្មែរលេខ 000014091 ជាភាសាអង់គ្លេសលេខ 00242278 និងជាភាសាបារាំងលេខ 00226226 ។ ឯកសារនេះមានចំណារមួយរបស់ជនជាប់ចោទទៅលើចម្លើយសារភាពរបស់ឈ្មោះ កែ គឹមហួត ដែលដកស្រង់ដោយមន្ទីរស-២១ ដែលគាត់ជាអតីតសាស្ត្រាចារ្យរបស់លោក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៧៧ ។

សំណួរ តើលោកជាអ្នកដែលសរសេរចំណារ ដែលមានគូសរង្វង់ពណ៌ក្រហមនេះឬ?

[០៩:៥៩:៥៥]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម-- លោកព្រះរាជអាជ្ញា! រង្វង់ពណ៌ក្រហមនេះមានពីររង្វង់ពណ៌ក្រហមនៅខាងស្ដាំលើអេក្រង់សរសេរថា ២២.០៧.៧៧ ពួកសួរបឋម នេះពិតជា អក្សររបស់ខ្ញុំ ចំណាររបស់ខ្ញុំ ។

**ស៖** សំណួរទីពីរ តើលោកមានបានផ្តល់ការណែនាំពិសេសណាមួយសម្រាប់ការសួរចម្លើយរបស់គាត់ដែរឬទេ?

**ឆ៖** តាមខ្ញុំចាំ នៅពេលដែលគាត់ទើបតែនឹងមកដល់ ខ្ញុំណែនាំទៅអ្នកសួរ អំពីស្មារតីដែលខ្ញុំគោរពគ្រូខ្ញុំ ពេលដែលចេញពីពេទ្យ ខ្ញុំយកឡានខ្ញុំទទួលគាត់ឲ្យចេញពីពេទ្យ ហើយខ្ញុំគ្រាគាត់ពីមន្ទីរពេទ្យយកទៅដាក់ទូក ។ នេះខ្ញុំឲ្យអ្នកសួររបស់ខ្ញុំនិយាយបញ្ហានេះ ដើម្បីឲ្យឃើញថាខ្ញុំគោរពគាត់ ប៉ុន្តែឥឡូវគាត់មកធ្លាក់នៅអ៊ីចឹង ខ្ញុំសូមអង្វរឲ្យគាត់ឆ្លើយ ។ ខ្ញុំអត់បានទៅជួបគាត់ទេ នេះជាការណែនាំ ក៏ប៉ុន្តែដល់នៅក្រាញយូរពេក យូរណាស់ ។ ដូច្នេះ ការវិវត្តន៍នៃបញ្ហាទារុណកម្ម វាចេះតែទៅហើយ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ឆ៖** អរគុណ ។ សំណួរបន្ត តើការបង្ខំឲ្យស៊ីអាចម៍គឺជាវិធីសាស្ត្ររួមជាទូទៅនៃការធ្វើទារុណ-កម្មនៅស-២១ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះសុទ្ធតែជាបទល្មើស ជាបទល្មើសក្នុងបញ្ហាធ្វើទារុណកម្ម ។

**ស៖** សំណួរបន្ត តើហេតុអ្វីបានជា កែ គឹមហួត ត្រូវគេបង្ខំឲ្យស៊ីអាចម៍ដោយត្រង់ៗ ដូច្នេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! រឿងនេះ វាជារឿងដែលក្មេងខាងក្រោមវាលួចធ្វើខ្ញុំអត់ដឹង ។

**ស៖** អរគុណ។ សំណួរបន្ត ។ ប្រសិនបើការឲ្យជនជាប់ចោទបរិភោគអាចម៍មិនត្រឹម មិនត្រូវបានអនុញ្ញាតឲ្យធ្វើនៅស-២១ ទេនោះ តើលោកមានបានធ្វើការដាក់ទណ្ឌកម្ម ឬស្តីបន្ទោសចំពោះអ្នកសួរចម្លើយដែលបានប្រើប្រាស់វិធីសាស្ត្រសួរចម្លើយ ដែលមិនគេអនុញ្ញាតឲ្យធ្វើនោះដែរឬទេ?

[១០:០៣:២៥]

**ឆ៖** បញ្ហានេះ ខ្ញុំបានជម្រាបលោកចៅក្រមស៊ើបអង្កេត គ្រប់ទិដ្ឋភាពដែរ ខ្ញុំនៅរក្សាបញ្ហានោះដដែលអត់មានអីថែមទេ ។ ក៏ប៉ុន្តែ ពេលនេះ ខ្ញុំគ្រាន់តែសុំបញ្ជាក់ថា ខ្ញុំអត់បានដាក់ទោសទេ ។

**ស៖** អរគុណ ។ ឥឡូវនេះ សូមអញ្ជើញមើលឯកសារដែលមានលេខ E5/2.1 ERN ជាភាសាខ្មែរលេខ 00227634 ជាភាសាអង់គ្លេសលេខ 00242277 និងភាសាបារាំងលេខ 00226226 ។ ឯកសារនេះ មានចំណារមួយរបស់ជនជាប់ចោទ ទៅលើចម្លើយសារភាពរបស់ សរ ភន ដែលដកស្រង់ដោយមន្ទីរស-២១ ។

សូមលោកប្រធានអនុញ្ញាតឲ្យ ខាងសោតទស្សន៍តមកកុំព្យូទ័រសហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

ខាងសោតទស្សន៍ភ្ជាប់រូបភាពទៅខាងសហព្រះរាជអាជ្ញា ។ ហើយជម្រាបអីចេះថា ខាងសោតទស្សន៍ កាលបើមានសំណូមពរជាបន្តរបស់តំណាងសហព្រះរាជអាជ្ញា សុំបង្ហាញនូវឯកសារនៅក្នុងអេក្រង់នោះ គឺលោកធ្វើតែម្តងមិនចាំបាច់ ទទួលបង្គាប់បញ្ជាពីខ្ញុំទៀតទេ នៅក្នុងអំឡុងពេលនៃដេញដោលនាពេលនេះ ។

[១០:០៥:00]

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** សំណួរ ជនជាប់ចោទអាចបញ្ជាក់បានទេថា នេះជាចំណាររបស់លោកមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា នេះជាចំណាររបស់ខ្ញុំ ។

**ស៖** អរគុណ ។ នៅក្នុងចំណារនេះលោកសរសេរថា "ស្នើបងម្ចាស់ការ សង្កត់ឲ្យជាប់ ទារុណកម្មជាមូលដ្ឋាន" តើឃ្លានេះមានន័យថា លោកមានសិទ្ធិបញ្ជាទៅលើអ្នកសួរចម្លើយឲ្យធ្វើទារុណកម្មមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំពិតជាមានសិទ្ធិបញ្ជាទៅអ្នកសួរឲ្យធ្វើទារុណកម្មដូចជា-- បានខ្ញុំបញ្ជាក់ជូនលោកព្រះរាជអាជ្ញាអម្បាញ់មិញអីចឹង ។ ចំពោះមនុស្សទោសធម្មតា លើកលែងតែអ្នកទោសសំខាន់ ។

**ស៖** អរគុណ ។ តាមចំណាររបស់លោកបង្ហាញថា មានណែនាំដល់អ្នកសួរចម្លើយឲ្យសួរចម្លើយ សួរនៅចំណុចសំខាន់ៗជាច្រើន តើជាធម្មតាលោកណែនាំដល់អ្នកសួរចម្លើយឲ្យសួរត្រង់អ្វីៗដែលលោកចង់បានឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះពិត ព្រោះចំណងជើងនៃបញ្ហានេះៗ គឺវត្ថុបំណងដែលយើងចង់បាន ខ្ញុំបញ្ជាក់ធំណាស់ ។

**ស៖** អរគុណ ។ សូមលោកប្រធានអនុញ្ញាតឲ្យផ្នែកសោតទស្សន៍ត្រឡប់ទៅរូបភាពដើមវិញ ។

សំណួរ ចម្លើយរបស់លោកកាលពីសប្តាហ៍មុនលោកថា អ្នកសួរចម្លើយអាចសួរអ្នកទោសរហូតដល់ទៅបីនាក់ផ្លាស់គ្នាក្នុងពេលតែមួយ ហើយថាគាត់សួរចម្លើយតែម្នាក់ឯងទេ ។ ដូច្នេះ អ្នកសួរចម្លើយនោះ សួរផងធ្វើទារុណកម្មផង ឬមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អ្នកសួរចម្លើយម្នាក់អាចសួរចម្លើយមនុស្សម្នាក់អ៊ីចឹង ហើយធ្វើទារុណកម្ម ដល់ធ្វើទារុណកម្មហើយគេយកទៅទុកកន្លែងវិញ គេទៅយកមួយមកទៀតរបៀបហ្នឹង ។ សូមជម្រាបលោកព្រះរាជអាជ្ញាប៉ុណ្ណោះ ។

[១០:០៨:៣០]

**ស៖** សំណួរបន្ត ហើយបើសិនជាអ្នកទោសនោះ មិនព្រមសរសេរចម្លើយសារភាពដោយខ្លួនឯង គឺអ្នកសួរចម្លើយនោះសួរផងធ្វើទារុណកម្មផង និងកត់ចម្លើយផងមែនទេ?

**ឆ៖** នេះវាចូលទៅក្នុងកិច្ចដំណើរការជាក់ស្តែង។ ដូច្នេះខ្ញុំសូមជូនជាសេចក្តីសន្និដ្ឋាន ។ បើអ្នកទោសមិនចេះសរសេរអក្សរទេ ផ្លូវមានតែមួយទេ គឺយកម៉ាញ៉េមកថតសំឡេងអ្នកទោសឲ្យនិយាយ ហើយឲ្យខាងនេះគេដកស្រង់ ខាងអង្គុលីលេខគេដកស្រង់ៗ នេះខ្ញុំសូមជូនជាសេចក្តិសន្និដ្ឋានដែលអាចពិតប៉ុណ្ណោះ ។ សូមអរគុណ ។

**ស៖** អរគុណ ។ សំណួរបន្ត លោកថាលោកធ្លាប់សួរចម្លើយឈ្មោះ ឈិត អ៊ីវ កាលដែលលោកនៅជាអនុប្រធាន ហើយក្រោយពី ឈិត អ៊ីវ សារភាពលោកបានទះកំផ្លៀងគាត់ ។ ជាទូទៅ ការធ្វើទារុណកម្មគឺដើម្បីយកចម្លើយ ប៉ុន្តែមូលហេតុអ្វីបានជាលោកផ្ទាល់ចូលចិត្តធ្វើទារុណកម្មក្រោយពីអ្នកទោសបានឆ្លើយសារភាពយ៉ាងនេះ? សូមលោកបញ្ជាក់មើល ?

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា ។ ខ្ញុំនិយាយអំពីក្រឹត្យក្រមដែលខ្ញុំសួរ មុននឹងធ្វើទារុណកម្ម ខ្ញុំមិនធ្វើទារុណកម្មនៅពេលដែលគេកំពុងខឹងទាល់តែសោះ ។ កាលណាខ្ញុំនិយាយឲ្យគេបាក់ ឲ្យគេសុខចិត្តចុះចាញ់មកខ្ញុំខាងផ្លូវចិត្ត ឬខាងផ្លូវភស្តុតាងហើយ បានៗខ្ញុំធ្វើទារុណកម្មបន្តិចបន្តួចដើម្បីពង្រាបគេថាថ្ងៃក្រោយកុំករ ។ អាហ្នឹងប៉ុណ្ណឹង របៀបហ្នឹង ។ ដោយឡែកករណី ឈិត អ៊ីវ ថ្ងៃនោះគាត់ច្រឡោតតោតតូងដាក់ ម៉ា ម៉េងឃាង ខ្ញុំនឹង ណាត ដើរទៅជាមួយគ្នា ។ ណាត កេះខ្ញុំឲ្យទៅសួរ ព្រោះ ម៉ា ម៉េងឃាង ចាញ់ហើយ ខាងផ្លូវសម្តី ម៉ា ម៉េងឃាង ចាញ់ ឈិត អ៊ីវ ។ ដូច្នេះ ខ្ញុំក៏ចូលសួរនិយាយចុះ និយាយឡើងទាល់តែ ឈិត អ៊ីវ សុខចិត្តចុះចាញ់ខ្ញុំ ។ បានខ្ញុំទះកំភ្លៀង ដែលខ្ញុំទៅទះនេះ ដើម្បីកុំឲ្យ ណាត គាត់វៃព្រោះមិនចង់ឲ្យគាត់ដែលមានថ្នាក់ធំហ្នឹងទៅជ្រលក់ដៃទះកំភ្លៀងអ្នកទោសដោយផ្ទាល់ដៃទេ ហើយចិត្តគាត់គាត់ចង់ទះ ព្រោះ ឈិត អ៊ីវ នេះពីដើមមកអធិការនគរបាលជាតិ សួរម្លើយខ្មែរក្រហម ធ្វើបាបខ្មែរក្រហមច្រើនណាស់ ណាត គាត់មានគំនុំ ហើយគាត់ចង់តែវៃទេ ហើយខ្ញុំទៅវៃជំនួស ។ ដូច្នេះរឿងនេះ វាជារឿងដោយឡែកមួយ ។ និយាយវែងបន្តិចតែសូមលោកព្រះរាជអាជ្ញាអធ្យាស្រ័យ ។

[១០:១១:00]

**ស៖** អរគុណ ។ តាមការអះអាងរបស់លោកបញ្ជាក់ថា ក្រោយមកមានបង្កើតក្រុមសួរចម្លើយនារី នៅលើអ្នកទោសស្រីៗ តើក្រុមនោះមានធ្វើទារុណកម្មទៅលើអ្នកទោសស្រីៗ ឬទេ? បើមានតើធ្វើដូចម្ដេចខ្លះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! រឿងកម្មាភិបាលនារីទៅសួរចម្លើយនារី ច្បាប់--មិនមានច្បាប់ទេៗ គោលការណ៍អនុញ្ញាតឲ្យធ្វើទារុណកម្ម អត់ដកទេ នៅតែរក្សាដដែល ។ ក៏ប៉ុន្តែ ដឹងអ្នកណាគេធ្វើកម្រិតណា ស្អីកម្រិតណាខ្ញុំក្ដាប់អត់បានទេ ។ ក្ដាប់អត់បានសោះ គឺប្រគល់ដាច់លើប្រពន្ធមិត្តហ៊ី ឈ្មោះ មិត្តមុត ជាប្រធានក្រុមហ្នឹង ហើយមិត្តហ៊ី ជួយមើលថែមទៅទៀត ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១០:១២:៤៩]

**ស៖** តើជឿជាក់ថាមានធ្វើទារុណកម្មមែនទេ?

**ឆ៖** អាចដែរ ។ អាច ជួនអីគាត់មិនឲ្យស្រីៗធ្វើគាត់អាចរុញបុគ្គលនោះទៅឲ្យមនុស្សប្រុសធ្វើទារុណកម្មក៏សឹងតែថាបាន ។ ក៏ប៉ុន្តែ អាចគាត់ធ្វើដោយដៃខ្លួនឯងក៏ថាបាន ស្រីៗអស់នោះ ។ ពីដើមនៅទ័ព ប្រពន្ធមិត្ត ហ៊ី នៅទ័ពវរសេនាតូច នៅទ័ព ។

**ស៖** អរគុណ ។ ឥឡូវនេះ ខ្ញុំសូមចាប់ផ្ដើមសំណួរនានារបស់យើងទាក់ទិននឹងប្រធានបទទីបួនអំពីការប្រហារជីវិត ។ សូមឲ្យខាងសោតទស្សន៍ចាប់រូបភាពបន្តមកដែលកុំព្យូទ័រសហព្រះរាជអាជ្ញា ។

យើងស្នើឲ្យជនជាប់ចោទពិនិត្យមើលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ត្រង់ឧបសម្ព័ន្ធ "គ" លេខ18.81 លេខ ERN ជាភាសាខ្មែរ 00001891 និងភាសាអង់គ្លេសគឺ 00021304 មិនមានបកប្រែជាភាសាបារាំងទេ ។ ឯកសារនេះ គឺជាបញ្ជីឈ្មោះអ្នកទោសស-២១ មួយដែលបង្កើតឡើងកាលពីថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨ ដែលនៅក្នុងនោះមានរាយឈ្មោះអ្នកទោសស-២១ ។

សំណួរ លោក កាំង ហ្គេកអ៊ាវ លោកអាចបញ្ជាក់បានទេថា តើលោកឬជាអ្នកដែលបានសរសេរចំណារនេះ?

**ឆ៖** អេក្រង់ខ្ញុំអត់មាននេះផង-- នៅលើអេក្រង់ខ្ញុំអត់មានឯកសារហ្នឹងបង្ហាញផង ។ អត់មានរូបឯកសារនុ៎ងទេ អេក្រង់ខ្ញុំស្ងាត់ ។

**ស៖** សំណួរ លោក កាំង ហ្គេកអ៊ាវ លោកអាចបញ្ជាក់បានទេថា តើលោកឬជាអ្នកដែលបានសរសេរចំណារនេះ?

[១០:១៥:៥៧]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជាអក្សររបស់ខ្ញុំ ។

**ស៖** សំណួរបន្ត ក្នុងចំណារនៅលើបញ្ជីឈ្មោះអ្នកទោសដែលមានរាយឈ្មោះកុមារចំនួនដប់ប្រាំពីរនាក់នេះ តើលោកបានសរសេរចំណារវាយចោលឲ្យហ្នត់ទៅ ឲ្យកូនចៅក្រោយបង្គាប់របស់លោកម្នាក់ឈ្មោះ ប៉េង ដែរ ឬទេ?

[១០:១៦:៣៤]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជាចំណាររបស់ខ្ញុំ បញ្ជាទៅឲ្យ ប៉េង វ៉ៃមែន ។

**ស៖** តើការត្រួតពិនិត្យលើបញ្ជីឈ្មោះអ្នកទោសនីមួយៗដើម្បីរកឲ្យឃើញ-- ដើម្បីរកមើលឲ្យឃើញថា អ្នកទោសណាម្នាក់ត្រូវការការសួរម្លើយបន្ថែមទៀត ឬក៏មួយត្រូវត្រៀមដើម្បីប្រហារជីវិតនោះ គឺជាភារកិច្ចដែលប្រព្រឹត្តទៅជាធម្មតារបស់លោកឬ?

**ឆ៖** ជាធម្មតាការងារអស់នេះវាស្ថិតនៅក្នុងកណ្ដាប់ដៃមិត្តហ៊ី ទេ ។ ឯចំណែកការងាររបស់ខ្ញុំធម្មតានៅលើរឿងសួរចម្លើយនេះមួយចំនួនណាទៅ ជាសំខាន់គឺសេចក្ដីរាយការណ៍ សេចក្ដីសារភាពទៅលើ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សំណួរបន្ត បន្ទាប់ពីលោកបានបញ្ជានេះទៅ ប៉េង រួចហើយនោះ តើជាធម្មតានៅក្នុងដំណើរការការងារ គឺបានន័យថា ប៉េង ឬក៏ជនណាផ្សេងទៀតបានទទួលការអនុញ្ញាតទាំងស្រុង ដើម្បីចាត់ការកម្ទេចអ្នកទោសទាំងនេះចោលហើយឬនៅ? ហើយឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំបានបញ្ជាក់ជាហូរហែរួចមកហើយថា មនុស្សដែលគេចាប់បញ្ជូនមកស-២១ទាំងប៉ុន្មាន ទោះក្មេងក៏ដោយចាស់ក៏ដោយ ប្រុសក៏ដោយ ស្រីក៏ដោយសុទ្ធតែគេសម្រេចឲ្យស-២១ ដាក់គុក ធ្វើទារុណកម្ម សួរចម្លើយ ចុងបញ្ចប់ត្រូវតែកម្ទេចឲ្យគេ ។ នេះយើងខ្ញុំត្រូវតែធ្វើដោយខានមិនបាន ។ ក្នុងកិច្ចអនុវត្តជាក់ស្ដែងប្រចាំថ្ងៃ ការងារអស់នេះ ខ្ញុំទុកឲ្យខាងមិត្តហ៊ី គេចាត់ចែង ដល់មិត្តហ៊ី មិននៅអាច មិត្តប៉េង ចាត់ចែងជំនួស ។ នេះជា--

**ស៖** តើ-- អរគុណ ។

**ឆ៖** បាទ ។

**ស៖** តើពួកគេត្រូវទៅពិគ្រោះយោបល់ជានរណាផ្សេងទៀតទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នៅក្នុងស-២១ គ្មានសិទ្ធិពិគ្រោះយោបល់ជាមួយនឹងអ្នកណាក្រៅពីមេរបស់គេផ្ទាល់ទេ ។ បញ្ជាក៏មិនទទួលពីនរណាក្រៅពីមេរបស់គេផ្ទាល់ដែរ ។

[១០:១៩:៤២]

**ស៖** អរគុណ ។ ឥឡូវនេះ សូមអញ្ជើញមើលឯកសារដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរត្រង់ឧបសម្ព័ន្ធ(គ) 16.46 លេខ ERN គឺ 0010 ចុះថ្ងៃ-- 00106315 ភាសាអង់គ្លេស 0018536263 ភាសាបារាំងគឺលេខ 00296018 ឯកសារនេះគឺជាបញ្ជីឈ្មោះអ្នកទោសស-២១ ដែលមានចំណារមួយចំនួនរបស់ឌុចនៅលើនោះ ។ សំណួរ លោកអាចបញ្ជាក់បានទេថា តើលោកឬដែលជាអ្នកសរសេរចំណារនៅផ្នែកខាងក្រោមនៃបញ្ជីនេះ?

[១០:២០:៣០]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ចំណារនេះមានមនុស្សពីរនាក់សរសេរ ។ ចំណារដែលបន្តពីឈ្មោះជនរងគ្រោះដាក់ថា "ថ្ងៃដក ដាក់ថាទុក ដាក់ថាអាចដក ហើយដាក់ឲ្យទុក" នេះ គឺចំណាររបស់ខ្ញុំ ។ ឯចំណារសរុបនៅខាងក្រោមជាចំណាររបស់បង ចាន់ ឈ្មោះដើម ម៉ម ណៃ ។

**ស៖** អរគុណ ។ សំណួរបន្ត ក្នុងចំណារនេះសរសេរថា បានសម្រេចឲ្យកម្ទេចមួយរយដប់ប្រាំនាក់ដែលក្នុងបញ្ជីនេះនឹងឲ្យទុកសែសិបបួននាក់ ។ ចំណារនោះក៏បានសរសេរដែលថា លោកបានស្នើអំពីវិធានការនេះទៅអង្គការថ្នាក់លើហើយ ហើយអង្គការថ្នាក់លើបានយល់ព្រម ។ តើលោកជឿជាក់ថា សំណូមពរឲ្យកម្ទេចរបស់លោក និងទំនាក់ទំនងនឹងត្រូវបានអនុញ្ញាតតាមច្រើន មិនត្រូវបានអនុញ្ញាតតាមឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ធម្មតាមនុស្សដែលគេប្រគល់ឲ្យស-២១ ហើយស-២១ ត្រូវតែកម្ទេច ។ ឯកសារនេះវាទាក់ទងនឹងការកម្ទេចមនុស្សមួយឈុតពីរជាដំបូងនៅឆ្នាំ១៩៧៧ ក្រោយដែលចាប់ពួកឧត្តរ ចាប់ កុយ ធួន មកដើម្បីឲ្យគុកវាធូរទូលាយបន្តិចចាប់ពួកឧត្តរបញ្ចូល ។ ដូច្នេះ ហើយខ្ញុំចាំថា ខ្ញុំចាំច្បាស់ថានៅពេលនោះមេហៅខ្ញុំទៅធ្វើការឲ្យខ្ញុំយកបញ្ជីទៅជាមួយ ។ ទៅដល់គាត់*ឌីតែ*ឲ្យ គាត់ហៅឲ្យ-- អ្ហូ! ខ្ញុំសូតឈ្មោះមនុស្សទៅឲ្យគាត់ហើយគាត់ហៅឲ្យ ខ្ញុំចារមក ។ មកដល់កន្លែងខ្ញុំប្រគល់អាឯកសារនេះទៅឲ្យ ម៉ម ណៃ ចាត់ចែងឲ្យគេអនុវត្តតាមសេចក្តីសម្រេច ។

សរុបមក រឿងដកអ្នកណាថ្ងៃណា? ដកអ្នកណាថ្ងៃណា? យើងខ្ញុំទាំងអស់គ្នានៅក្នុងស-២១

ជាពិសេសខ្ញុំអត់មានទៅរញ៉េរញ៉ៃជាមួយនឹងអង្គការសួរឃោបល់អីទៀតទេ ក្រៅពីមនុស្សសំខាន់ម្នាក់ពីរចេញ គឺយើងខ្ញុំត្រូវតែធ្វើឲ្យគេកុំឲ្យខាន ។ ធ្វើម៉េចកុំឲ្យតែរត់រួច ។ នេះគឺជាក្រឹត្យក្រមដែលគេដាក់ឲ្យមក កុំដោះលែងរបស់គេ កុំឲ្យត់រួច ដូច្នេះគេប្រគល់មកត្រូវតែយកចេញឲ្យគេ ។ ដោយឡែក មនុស្សសំខាន់មួយចំនួនត្រូវតែទុកឲ្យគេ ទាល់តែគេសម្រេចក្រែងគេត្រូវការសំណួរឲ្យសួរស្អីទៀត ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

[១០:២៣:៤៥]

**ស៖** អរគុណ ។ សំណួរមួយទៀត ក្រៅពីតាមរយៈលោក តើធ្វើដូចម្ដេចអង្គការដឹងថា អ្នកណាត្រូវត្រៀមកម្ទេច ឬមិនត្រូវកម្ទេចនោះ? សូមលោកបំភ្លឺ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! មនុស្សណាដែលគេតាមដានជាប់លាប់ គេសួរចម្លើយអានេះ ចប់ហើយនៅ? អស់ប៉ុណ្ណឹងឯង? ខ្ញុំថាអស់ហើយ ។ ដល់ទៅគេបញ្ជាមកថា អាហ្នឹងដកចេញទៅ ។ នេះជាកិច្ចប្រតិបត្តិពិសេសចំពោះមនុស្សដែលគេចាត់ទុកជាសំខាន់ ។ ជាទូទៅឲ្យតែយើងខ្ញុំថាចម្លើយហ្នឹង វាអស់ហើយ ខាងលើគេមិនទាន់សួរបញ្ជាក់អីទៀតទេ ។ យើងខ្ញុំចាត់ចែងឲ្យកម្ទេចមនុស្សនោះហើយ ព្រោះគោលការណ៍របស់គេអ៊ីចឹង បញ្ជូនមកហើយត្រូវតែកម្ទេចឲ្យគេ ។

**ស៖** អរគុណ ។ ឥឡូវនេះ សូមអញ្ជើញមើលឯកសារលេខD57 ឧបសម្ព័ន្ធលេខ00296 ជាភាសាខ្មែរលេខ ERN00171143 ភាសាអង់គ្លេសលេខ ERN00181789 ដល់ 90 និងភាសាបារាំងលេខ ERN00296035 ។ ឯកសារនេះ គឺជាបញ្ជីឈ្មោះអ្នកទោសស-២១ ភេទស្រីដែលមានចំណាររបស់ ឌុច នៅលើនោះ ។ សំណួរ លោកអាចបញ្ជាក់បានទេថា នៅក្នុងទំព័រនេះ តើលោកគឺជាអ្នកដែលសរសេរចំណារទាំងនេះឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជាចំណាររបស់ខ្ញុំ ។

**ស៖** សំណួរបន្ត ។ ក្នុងចំណារនេះបានសរសេរថា កុំយកចេញទៅក្រៅ ដែលមានន័យថាឲ្យទុកនៅក្នុងមន្ទីរស-២១ ដើម្បីសួរចម្លើយបន្តទៀតឬ?

**ឆ៖** ខ្ញុំមិនអះអាងបែបនោះទេ ។ ខ្ញុំគ្រាន់តែសូមបញ្ជាក់ថាកុំយកចេញទៅក្រៅ គឺកុំកម្ទេច ទុកសិន ។ បានន័យថាទុកសិន ។

**ស៖** អរគុណ។ ចំពោះបុគ្គលទាំងឡាយដែលលោកមិនបានសរសេរនៅក្បែរនោះ គឺមានន័យថាពួកគេត្រូវតែកម្ទេចចោលឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! រឿងនេះវាចាស់យូរហើយ ខ្ញុំភ្លេចអស់ហើយ ប៉ុន្តែសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ មនុស្សម្នាក់ ស្រីម្នាក់នៅលេខហុកសិបបួន ដើមគេបំផុតនេះ ជាពេទ្យធ្មេញដែលយើងខ្ញុំទុកប្រើ ហើយពេលដែលរត់ក៏រត់ទៅជាមួយនឹងខ្ញុំដែរ តែគ្នាឃើស្លាប់តាមផ្លូវបាត់ហើយ ។

**ស៖** សំណួរបន្ត តើលោកធ្វើដូចម្តេចទើបលោកដឹងថា មនុស្សផ្សេងទៀតដែលលោកមិនបានជ្រើសរើសឲ្យទុកទាំងនេះ គឺត្រូវបានត្រៀមដើម្បីធ្វើការប្រហារជីវិត?

[១០:២៧:៣៨]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ក្នុងឯកសារនេះអ្នកដែលខ្ញុំមិនបានជ្រើសរើសឲ្យទុកនេះអាចគេដកចេញទាំងអស់ លើកលែងតែឈ្មោះណាដែលខ្ញុំមានគូសដូចជា យឹម សុខ, ហាក់ ផាដេត ។ ហាក់ ផាដេត នេះក៏ជាពេទ្យម្នាក់ដែរ ឯចំណោក វ៉ុន ខ្ញុំមិនស្គាល់ទេ ឡាច ដារ៉ា ហៅ ថន នេះ ក្មួយពូនួន ហើយរត់ទៅជាមួយនិងខ្ញុំជាប់ជាមួយនឹងខ្ញុំ ខ្ញុំទុកប្រើនៅស-២១ នេះ ។

**ស៖** អរគុណ ។ សំណួរបន្ត តើធ្វើដូចម្តេចទៅទើបលោកដឹងថា មនុស្សផ្សេងទៀតដែលលោកមិនបានជ្រើសរើសទុកទាក់ទងគឺត្រៀម-- (សូមទោស) សំណួរនេះសួររួចហើយ ។ ឥឡូវនេះ ខ្ញុំសូមពិភាក្សាទៅលើប្រធានបទចុងបញ្ចប់របស់យើងស្តីការសួរចម្លើយ ម៉ែន សាន ហៅ យ៉ា ។

លោក កាំង ហ្គេចអ៊ាវ ដូចដែលបានលើកឡើងដោយសង្ខេបក្នុងសវនាការនេះ គឺ យ៉ា ជាលេខាភូមិភាគឦសានក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យនៅពេលដែលគាត់ត្រូវបានចាប់ខ្លួន តើរឿងនេះត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា រឿងនេះត្រឹមត្រូវហើយ ។

**ស៖** សំណួរបន្ត បន្ថែមពីលើនេះ យ៉ា មិនត្រឹមតែជាមេដឹកនាំខ្មែរក្រហម ប៉ុន្តែ តើវាពិតទេថា យ៉ា គឺជាសមាជិកម្នាក់ក្នុងចំណោមសមាជិកមជ្ឈិមបក្សលើកដំបូង?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បង ម៉ែន សាន ហៅ យ៉ា នេះគេហៅថា អាចារ្យសៀង ជាសមាជិកមជ្ឈិមបក្សពេញសិទ្ធិ ។ ជាសមាជិកមជ្ឈិមបក្សពេញ បើនិយាយពីលំដាប់ពី ប៉ុល ពត ចុះមក គាត់ជាបុគ្គលទីដប់ ប៉ុល ពត ជាទីមួយ គាត់ជាទីដប់ ។

**ស៖** អរគុណ។ តើគាត់គឺជាបុគ្គលមានឥទ្ធិពលនៅភូមិភាគឦសាននៃប្រទេសកម្ពុជាដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំមិនដឹងជាឥទ្ធិពលគាត់យ៉ាងម៉េចទេ ។ នេះខ្ញុំសូមជម្រាបប៉ុណ្ណេះ ក៏ប៉ុន្តែខ្ញុំសូមសង្ខេបប្រវត្តិបង យ៉ា ជូន ។ សម័យសង្គ្រាមប្រឆាំង លន់ នល់ គាត់ជាអ្នកដឹកជញ្ជូនសព្វាវុធ ដល់ក្រោយ១៧ មេសា បន្តិចគាត់ជាអនុលេខាគណៈកម្មាធិការសេនាធិការ រួចក្រោយមកដោយសេចក្តីត្រូវការនៃការងារ ឬយ៉ាងម៉េចមិនដឹងទេ ខាងលើបញ្ជូនគាត់ទៅឲ្យធ្វើលេខាភូមិភាគព្ហ៍សាន នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ តើគាត់ជាមនុស្សសំខាន់ដែលធ្វើឲ្យខ្មែរក្រហមមានប្រជាប្រិយភាពនៅភូមិភាគព្ហ៍សានដែរ ឬទេ?

[១០:៣១:២៧]

**ឆ៖** ដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញាអ៊ីចឹង គាត់ទៅកាន់កាប់កិច្ចការនៅខាងព្ហ៍សានឆាប់ទេ ដូចជាមួយឆ្នាំ ឬមកដល់មួយឆ្នាំផង ។

**ស៖** សំណួរបន្ត ក្រោយពីលោកត្រូវបានតែងតាំងជាប្រធានស-២១ យ៉ា ត្រូវចាប់ខ្លួននៅផ្ទះរបស់លោកនៅថ្ងៃទី២០ ខែកញ្ញា ឆ្នាំ១៩៧៦ ហើយ យ៉ា ត្រូវបានគេប្រើល្បិចឲ្យមកផ្ទះរបស់លោកដោយប្រើលេសថា ឲ្យមកពិនិត្យសុខភាព ។ តើរឿងនេះជារឿងពិតដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា រឿងនេះពិត ។

**ស៖** អរគុណ ។ សំណួរបន្ត តើលោកធ្លាប់បាននិយាយជាមួយ យ៉ា ដើម្បីអញ្ជើញគាត់ឲ្យមកផ្ទះលោកដែរឬទេ?

**ឆ៖** ពីដើមមក ខ្ញុំមិនដែលស្គាល់មុខបង យ៉ា ទេៗ ។ មកស្គាល់ថ្ងៃដែលគាត់ចូលមកដល់មន្ទីរស-២១ ហ្នឹង ។

**ស៖** អរគុណ ។ សំណួរបន្ត តើអ្នកណាជាអ្នកពិភាក្សានូវនីតិវិធីក្នុងការចាប់ខ្លួន យ៉ា?

**ឆ៖** មិន-- ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញាមិនពិភាក្សាអីទេ គឺជាសេចក្តីណែនាំរបស់មេខ្ញុំបងខៀវ គឺលោកគ្រូ សុន សេន ។

**ស៖** អរគុណ ។ សូមពិនិត្យមើលឯកសារក្នុងឧបសម្ព័ន្ធ(គ) លេខ5.56 នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ERN ជាភាសាខ្មែរលេខ009574 មិនមានបកប្រែភាសាទេ ឯកសារនេះគឺជាលិខិតស-២១ របស់ ឌុច ផ្ញើទៅ យ៉ា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៧៦ ។ សំណួរ តើលោកអាចបញ្ជាក់បានទេថា តើលិខិតនេះសរសេរដោយលោកនឹងផ្ញើទៅ យ៉ា?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ក្នុងកិច្ចដំណើរការសួរចម្លើយ យ៉ា នេះ វាផ្សំផ្គុំមនុស្សបីនាក់ ។ អ្នកសួរផ្ទាល់ គឺមិត្តប៉ុន អ្នកមានកំណត់ដឹកនាំកិច្ចអនុវត្ត គឺខ្ញុំ ឯចំណែក អ្នកត្រួតពិនិត្យហើយនិងកែតម្រូវបណ្តើរៗគឺមេខ្ញុំលោកគ្រូ សុន សេន ។ សំបុត្រនេះជាយុទ្ធវិធីមួយដើម្បីកំហែងបង យ៉ា ខាងផ្លូវចិត្ត ឲ្យគាត់សុខចិត្តសារភាព ។

[១០:៣៥:០០]

**ស៖** សំណួរបន្ត ក្នុងលិខិតនេះកោតសរសើរពីតួនាទីរបស់គាត់ក្នុងបដិវត្តន៍ និងអំពីការងារល្អៗមួយចំនួនទៀតដែលបានធ្វើចំពោះខ្មែរក្រហម ។ ប៉ុន្តែ លោកអាចសង្កត់គាត់ផងដែរថា ឲ្យទទួលស្គាល់សកម្មភាពរបស់គាត់ជាមួយវៀតណាម និងពួកបរទេសផ្សេងទៀត និងគោលដៅរបស់គាត់ក្នុងការបង្កើតបក្សប្រឆាំងបដិវត្តន៍គឺប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា ។ សូមលោកបំភ្លឺ ។

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំសូមសង្ខេបរឿងដើមពីរ ។ រឿងទីមួយគឺ រឿងមាន ចម្លើយឆ្លើយដាក់ បងយ៉ា ហូរហែចេញពីស-២១ ។ រឿងទីពីរ គឺមានទំនាស់យ៉ាងជូរចត់រវាង បងប៉ុល គឺប៉ុល ពត នេះលោកគ្រូ សុន សេន តទល់ជាមួយ យ៉ា ហើយនិង កែវ មាស ។ នេះទំនាស់ពីរនេះហើយ ដែលធ្វើឲ្យខាងលើគេសម្រេចចាប់ បងយ៉ា ឲ្យមក ស-២១ ។ ដូច្នេះ ខ្ញុំសរសេរនេះគឺដោយឈរលើការយល់ដឹងផង ហើយនិងការណែនាំផងរួមផ្សំគ្នាដើម្បីកំហែងបង យ៉ា ឲ្យសារភាព ។ នេះខ្ញុំសូមសង្ខេបជូនប៉ុណ្ណេះ ។

**ស៖** សំណួរបន្ត នៅពេលលោកសរសេរលិខិតនេះ តើលោកជឿ ឬមិនជឿថា យ៉ា ជាអ្នកក្បត់ធំ ជាងគេប្រឆាំងនឹងបដិវត្តន៍?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ឯកសារដែលគេឆ្លើយដាក់បង យ៉ា វាជាបញ្ហាមួយទេ ក៏ប៉ុន្តែសំខាន់ខ្ញុំឈរលើទំនាស់រវាងបង កែវ មាស ហើយនិងបង យ៉ា ម្ខាង ជាមួយនិងបង ប៉ុលហើយនិង បងខៀវ ម្ខាង រវាងវៀតណាម និងមិនមែនវៀតណាម។ ដូច្នេះ គេទាស់គ្នាខ្លាំងណាស់ ពីរគួហ្នឹង។ ដូច្នេះ ក្បត់ ឬមិនក្បត់មិនដឹងទេ ក៏ប៉ុន្តែ ទាស់គ្នារវាងនិន្នាការចំពោះវៀតណាម គោលជំហរចំពោះវៀតណាម ។ នេះគឺខ្ញុំបានដឹងឮតាមការគេឧទ្ទេសនាមហូរហែ ឲ្យខ្ញុំតាមរយៈ ទូរស័ព្ទតាមរយៈការសន្ទនាជាមួយមេ។ នេះគឺសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** សំណួរបន្ត តើលោកគិតថាមានអ្វីកើតឡើងចំពោះជនក្បត់ដូច យ៉ា ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! សំណួររបស់លោក វាទូលាយខ្ញុំមិនទាន់ដឹងឆ្លើយយ៉ាងម៉េច? សូមលោកមេត្តាសួរមួយបែបទៀត ដើម្បីខ្ញុំបានឆ្លើយទៅរួច។

**ស៖** ខ្ញុំបញ្ជាក់សំណួរម្តងទៀត តើលោកគិតថាមានអ្វីកើតឡើងចំពោះជនក្បត់ដូច យ៉ា?

**ឆ៖** កើតមុនចាប់ ឬក្រោយចាប់ ឬយ៉ាងម៉េច? កើតទៅលើអ្នកណា? ខ្ញុំអត់យល់ ។

**ស៖** ចង់បញ្ជាក់ថា បើសិនគាត់ជាជនក្បត់ហ្នឹង វាមានផលវិបាកអីដល់គាត់ទៅថ្ងៃក្រោយ?

[១០:៣៩:១៩]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ក្នុងបក្សកុម្មុយនីស្តកម្ពុជា អ្នកណាដែលមិនគោរពប្រជាធិបតេយ្យប្រមូលផ្តុំ គឺមិនគោរព ប៉ុល ពត ហើយទៅគោរពតាមការណែនាំរបស់វៀតណាម គេចាត់ទុកជាជនក្បត់ហើយ ។ ដូច្នេះ គេចាប់ៗ ។ នេះនិយាយពីក្នុងបក្សកុម្មុនីស្តកម្ពុជា វិន័យគេគឺអ៊ីចឹង។ អំណាចប្រមូលផ្តុំនៅលើ ប៉ុល ពត ។ អ្នកណាមិនគោរព ប៉ុល ពត ទៅគោរពជឿទុកចិត្តកម្មាភិបាលណាមួយរបស់បក្សវៀតណាម អ្នកឯងត្រូវគេចាត់ទុកថាក្បត់ហើយ ។ ទោះបក្សវៀតណាមនោះជាផាំហ៊ុង ក៏ដោយ ក៏គេចាត់ទុកថាក្បត់ដែរ ។

**ស៖** តើក្បត់ហើយចុងក្រោយយ៉ាងម៉េច?

**ឆ៖** ចាប់ៗ ឲ្យតែមានភស្តុតាងគេចាប់ ។

**ស៖** ចាប់ហើយ?

**ឆ៖** ចាប់ហើយ ស-២១សួរចម្លើយហើយ គេប្រគល់មកឲ្យស-២១ សួរសម្លើយ ធ្វើទារុណកម្មរួចហើយគេកម្ទេច ។

**ស៖** អរគុណ។ បន្ទាប់ពីទទួលបានលិខិតនេះ យ៉ា មិនទទួលស្គាល់អ្វីទាំងអស់ ពិតមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! យ៉ា គាត់ក្រាញយូរដែរទម្រាំតែល្បើក មិនដឹងជាក្រោយ លិខិតនេះគាត់នៅបដិសេធតទៀត ឬគាត់ឈប់បដិសេធហើយ ខ្ញុំភ្លេចមិនបានទេ ។ ប៉ុន្តែ គាត់ក្រាញយូរ យើងខ្ញុំត្រូវសរសេរសំបុត្រទៅគាត់មិនដឹងជាប៉ុន្មានដងទេ ខ្ញុំបាទផ្ទាល់មិនដឹងជាសរសេរសំបុត្រទៅគាត់ប៉ុន្មានដងទេ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ ឥឡូវសូមមើលឯកសារនៅក្នុងឧបសម្ព័ន្ធ (គ) នៃដីកាសន្និដ្ឋានបញ្ជូនរឿង--

**ប្រធានអង្គជំនុំ៖**

សម្រាកសិនទៅ ។

ឥឡូវនេះដល់ម៉ោងត្រូវឈប់សម្រាក ។ សូមអង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងដប់មួយសូមអញ្ជើញចូលមកវិញ ដើម្បីបន្តដំណើរការពិភាក្សាដេញដោល ។

*[សវនាការសម្រាកពីម៉ោង ១០:៤១នាទី ដល់ម៉ោង ១១:០០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តដំណើរការសវនាការដេញដោលតទៅទៀត ហើយសូមប្រគល់វេទិកានេះ ជូនទៅតំណាងសហព្រះរាជអាជ្ញា ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា ។

**សួរដោយលោក យ៉េត ចរិយា៖**

**ស៖** ឥឡូវនេះ យើងសុំមើលបន្តទៅឯកសារក្នុងឧបសម្ព័ន្ធ "គ" នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ERN ជាភាសាខ្មែរ 00053001, ERN ជាភាសាអង់គ្លេស 00184021 និងERN ជាភាសាបារាំង 00290165 ។ ឯកសារនេះ គឺជាលិខិតស-២១ របស់ ប៉ុន ផ្ញើទៅ ឌុច ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ១៩៧៦ ។ សំណួរ តើលោកអាចបញ្ជាក់បានទេថា លិខិតនេះសរសេរដោយ ប៉ុន និងផ្ញើជូនលោក?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ពិតជាលិខិតរបស់ មិត្តប៉ុន ផ្ញើមកខ្ញុំ ។

**ស៖** អរគុណ ។ សំណួរបន្ត លិខិតនេះបញ្ជាក់ថា យ៉ា ត្រូវបានធ្វើទារុណកម្មតាមបញ្ជារបស់លោក និងជាលទ្ធផល យ៉ា បានសារភាពដោយផ្ទាល់មាត់នូវអ្វីដែលគាត់បានសរសេរក្នុងចម្លើយសារ-ភាព ។ សូមលោកបញ្ជាក់មើល?

**ឆ៖** អរគុណ ។ បញ្ហា គឺមានបញ្ជាក់នៅស្រាប់ហើយ នៅក្នុងលិខិតផ្ដើមសារភាពដោយមាត់ទទេ ដូចអត្ថបទមួយសន្លឹក ដែលសរសេរផ្ទាល់ដៃដែរ ។ សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ សូមមើលឯកសារក្នុងឧបសម្ព័ន្ធ(គ) 10.5 នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ERN ជាភាសាខ្មែរ 00053000, ERN ជាភាសាអង់គ្លេស 00184020 និង ERN ជាភាសាបារាំង 00290166 ។ ឯកសារនេះ គឺជាលិខិតស-២១ របស់ ប៉ុន ផ្ញើជូន ឌុច ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ១៩៧៦ ។ សំណួរ តើលោកអាចបញ្ជាក់បានទេ ថាលោកបានទទួលលិខិតនេះពី ប៉ុន?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា ខ្ញុំពិតជាបានទទួលលិខិតនេះ ពីមិត្តប៊ុន ។

**ស៖** អរគុណ ។ សំណួរបន្ត ក្នុងលិខិតនេះ ប៊ុន បាននិយាយថា លោកបានណែនាំឲ្យគាត់សួរ យ៉ា ថាតើគ្រួសាររបស់គាត់បានដឹងថា គាត់នៅទីណា? និងបានដឹងអំពីកំហុស-- អំពីសុខទុក្ខរបស់ពួកគាត់ដែរឬទេ?

[១១:០៥:៣៩]

**ឆ៖** បើតាមខ្ញុំយល់ សំណួររបស់លោកព្រះរាជអាជ្ញា គឺសំដៅត្រង់ក្នុងប្រអប់ទីពីរ រំឭកអំពីសុខទុក្ខប្រពន្ធកូន ឃាត់ខ្លួនប្រពន្ធកូន ដឹងទេ? ពេលមកនេះ ប្រពន្ធដឹងថាទៅឯណាដែរ? ខ្ញុំមើលទៅលោកព្រះរាជអាជ្ញា សួរខ្ញុំត្រង់នេះ ឲ្យខ្ញុំបញ្ជាក់ ។ តើ--

**ស៖** បាទ ។

**ឆ៖** អរគុណ ។ ខ្ញុំសូមបញ្ជាក់ថា បងយ៉ា មានប្រពន្ធក្មេង អាយុតិចជាងគាត់២៧ឆ្នាំ ។ ដូច្នេះខាងលើក្តាប់បានតែ បងយ៉ា ស្រឡាញ់ប្រពន្ធហ្នឹងខ្លាំងណាស់ ដូច្នេះយករឿងប្រពន្ធនេះ មកលើកឲ្យខ្ញុំ ហើយមិត្តប៊ុន យកប្រពន្ធ រឿងប្រពន្ធនេះមកលើក ដើម្បីឲ្យ បងយ៉ា គិតគូដល់ប្រពន្ធកូន ។ ហើយយើងខ្ញុំភរថា ខាងលើកឃាត់ខ្លួនប្រពន្ធកូនគាត់ហើយ ។ តើគាត់ដឹងទេ? ខាងលើណែនាំឲ្យខ្ញុំ ហើយនិងមិត្តប៊ុន ជាពិសេស មិត្តប៊ុន ប្រាប់ បងយ៉ា ថា ខាងលើឃាត់ខ្លួនប្រពន្ធគាត់និងកូនគាត់ ។ ឃាត់ខ្លួនប្រពន្ធបងយ៉ា និងកូន បងយ៉ា នោះ តើបងយ៉ាដឹងទេ? ហើយពេលដែល បងយ៉ា ចេញមកនេះ ប្រពន្ធដឹងថាទៅណាដែរទេ? ហ្នឹងរបៀបសួររបស់ មិត្តប៊ុន ទេ គេរាយការណ៍មកខ្ញុំ ។ សូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** តើនេះជាការគំរាមកំហែង ដើម្បីឲ្យ យ៉ា សារភាពបន្ថែមអំពីសកម្មភាពក្បត់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា គឺវាពិតជាអ៊ីចឹងមែន ។

**ស៖** សូមមើលឯកសារសំណុំរឿងនៅក្នុងឧបសម្ព័ន្ធ(គ) 5.65 ដីកាបញ្ជូនសំណុំរឿងឲ្យស៊ើបសួរ ERN ជាភាសាខ្មែរ 00009499, ជាភាសាអង់គ្លេស 00106287, ជាភាសាបារាំង 00233429 ។ ឯកសារនេះ គឺជាចម្លើយសារភាពនៅស-២១របស់ យ៉ា ដែលមានចំណាររបស់ ឌុច ។ សំណួរ តើលោកអាចអះអាងបានថា លោកបានសរសេរចំណារយ៉ាងវែងទៅលើចម្លើយសារភាព ដែលសំដៅទៅលើ យ៉ា ដែលនិយាយថា កុំសរសេរពាក្យដែលឆ្កួតទាំងនេះ បងគ្មានសិទ្ធិរាយការណ៍អំពីបញ្ហានេះ ជូនអង្គការទេ ខ្ញុំមានសិទ្ធិ ។ សូមលោកឆ្លើយបញ្ជាក់?

**ឌ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អក្សរប៉ុន្មានតួនេះ គៀកៗនេះនៅខាងស្តាំ ផ្នែកខាងស្តាំនេះ ជាអក្សរ បងយ៉ា នៃឆូតនេះជាអក្សរ-- ជាការឆូតពណ៌ក្រហម ។ ខ្ញុំឆូតចោល ហើយខ្ញុំសរសេរថា កុំសរសេរ អាពាក្យណាដែលខ្ញុំឆូតហើយ បងឯងកុំសរសេរ ។ បងឯងគ្មានសិទ្ធិរាយការណ៍ជូនអង្គាករទេ មានតែខ្ញុំបានមានសិទ្ធិ ។ ដូច្នេះ អក្សរម្ខាងឆ្វេងនេះ គឺខ្ញុំ ចុះថ្ងៃ៣០ ខែកញ្ញា ១៩៧៦ ។ សូមជម្រាបប្រសាសន៍ ។

**ស៖** សំណួរបន្ត ក្នុងផ្នែកនៃចម្លើយសារភាពនេះដែល យ៉ា សរសេរឆូតចោលនោះ ថាសូមកត់សម្គាល់ថាឆ្លើយចម្លើយ-- ការឆ្លើយរបស់ខ្ញុំចាប់ពីថ្ងៃទី១៨ ខែ៩ ឆ្នាំ១៩៧៦ កន្លងមកនេះ គឺជាការឆ្លើយក្រោយដែលខ្ញុំបានទទួលរងនូវទារុណកម្មយ៉ាងខ្លាំងនិងធ្ងន់ធ្ងររួចហើយ ។ តើលោកមិនសប្បាយចិត្តឬ? ដែល យ៉ា បានព្យាយាមប្រាប់ដល់អង្គការអំពីការធ្វើទារុណកម្ម ដោយឯកតោភាគីបែបនេះ?

**ឌ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! តាមពិតការអនុញ្ញាត ឬក៏ការចេញបញ្ជាឲ្យខ្ញុំធ្វើទារុណកម្មឲ្យមិត្ត ប៉ុន ធ្វើទារុណកម្ម គឺខាងលើចេញបញ្ជារួចទៅហើយ ។ ដូច្នេះ ទៅឲ្យបង យ៉ា និយាយធ្វើអីទៀត ។ វារឿងខាងលើ គេដឹងអស់ទៅហើយ ដូច្នេះ ខ្ញុំឆូតចោលមិនឲ្យគាត់និយាយទេ ព្រោះខាងលើគេអ្នកបញ្ជា គេអ្នកណែនាំមក គេអ្នកសម្រេចឲ្យខ្ញុំ ហើយនិង មិត្តប៉ុន ធ្វើទារុណកម្ម ជាពិសេសឲ្យ មិត្តប៉ុន ជាដៃដល់ធ្វើទារុណកម្ម ហើយខ្ញុំអ្នកដឹកនាំ ។ ដូច្នេះទុកឲ្យគាត់និយាយធ្វើអីទៀត បើគេដឹងហើយ គេបញ្ជាសភាពការណ៍ហ្នឹងទៅហើយ ។

[១១:១០:៥១]

**ស៖** អរគុណ ។ ឥឡូវសូមមើលឯកសារសំណុំរឿង នៅក្នុងឧបសម្ព័ន្ធ(គ)18.15 នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ERN ជាភាសាខ្មែរ 00008162 ជាភាសាអង់គ្លេស 00172213 ជាភាសាបារាំង 00232722 ។ ឯកសារនេះ គឺជាលិខិតនៅមន្ទីរស-២១ របស់ឌុច ផ្ញើឲ្យ យ៉ា ចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ ។ សំណួរ តើអាចបញ្ជាក់បានទេថា លោកបានសរសេរលិខិតនេះ ផ្ញើទៅឲ្យ ប៉ុន?

**ឌ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះជាយុទ្ធវិធីនៃការសួរចម្លើយ ដែលយើងខ្ញុំពីរនាក់ដើរតួ ។ លិខិតនេះ ពិតជាលិខិតដែលខ្ញុំសរសេរទៅមិត្ត ប៉ុន មែន ។

**ស៖** អរគុណ ។ នៅក្នុងលិខិតនេះ អ្នកបានសរសេរថា “កុំឲ្យវាលេងល្បែងជាមួយយើងតទៅទៀត ” ម្តងនិយាយបង្អើបមួយម៉ាត់ ម្តងបដិសេធមួយសៀវភៅ ។ នេះអង្គការកំណត់ថា ជាបាតុភាពមើលងាយបក្ស មិនមើលងាយត្រឹមតែគណៈសន្តិបាលរដ្ឋរបស់យើងទេ ដូចនេះជាមួយលោក បងយ៉ា

នេះ សមមិត្តអាចប្រើធម៏ក្ដៅបានខ្លាំង ហើយយូរ ទោះបីភ្ជាត់ទៅដល់សម្លាប់ក៏សមមិត្តមិនមានការខុសឆ្គងនិងអង្គការដែរ ។ សូមលោកបញ្ជាក់?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ដូចខ្ញុំបានជម្រាបរួចអំមិញហើយ នេះជាយុទ្ធវិធីបំភ័យ បងយ៉ា តាមសំបុត្រ ដើម្បីឲ្យគាត់សារភាព ។ មិនមែន ប៊ុន ធានាថា បើបងយ៉ា ស្លាប់ មិត្តប៊ុនមិនមានទោសទេ អានេះជាវិធីបំភ័យ ប៊ុនទុំងទេ ។ ជាល្បែងដែលយើងខ្ញុំលែងជាមួយ បងយ៉ា ដើម្បីឲ្យគាត់សុខចិត្តសារភាព ខ្ញុំធ្វើជាសរសេរសំបុត្រទៅមួយ ទៅមិត្តប៊ុន ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** តើលោកមានបានណែនាំ ប៊ុន ឲ្យបង្ហាញលិខិតនេះទៅ យ៉ា ដែរឬទេ? ពីព្រោះ ប៊ុន បានបញ្ជាក់នៅក្នុងជ្រុងមួយនៃឯកសារនេះ ថាគាត់បានបង្ហាញ?

[១១:១៣:៤៩]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! សំបុត្រនេះខ្ញុំសរសេរដើម្បីឲ្យ មិត្តប៊ុន កាន់យកទៅបង្ហាញបងយ៉ា ។ ដូច្នេះ មិត្តប៊ុន សរសេរថារនេះ វាត្រឹមត្រូវហើយ ។

**ស៖** សំណួរបន្ត ហើយតាមលិខិតរបស់លោកនេះឃើញថា លោកបានបញ្ជាឲ្យ ប៊ុន ធ្វើទារុណកម្មទៅលើ យ៉ា ព្រោះតែខឹងសម្បារបស់លោក ដែល យ៉ា បានបដិសេធមិនព្រមឆ្លើយសារភាព ។ តើមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍! មែន ។ ហើយខ្ញុំគ្រាន់តែសូមបញ្ជាក់ដដែលឡើងវិញ ថាកិច្ចការសួរចម្លើយ បងយ៉ា នេះ មានគ្នាបីនាក់ ។

**ស៖** ឥឡូវសូមមើលឯកសារសំណុំរឿងនៅក្នុងឧបសម្ព័ន្ធ(គ)5.65 នៃដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ERN ជាភាសាខ្មែរ 00009538, ERN ជាភាសាអង់គ្លេសនិងជាភាសាបារាំងគ្មានទេ ។ ឯកសារនេះ គឺជាលិខិតនៅមន្ទីរស-២១ របស់ ឌុច ផ្ញើឲ្យ ប៊ុន ចុះថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ១៩៧៦ ។

សំណួរ តើអ្នកអាចបញ្ជាក់បានទេថា នេះជាចំណារដែលអ្នកចារទៅឲ្យ ប៊ុន?

[១១:១៥:២០]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ពិតមែន ជាចំណាររបស់ខ្ញុំ ។

**ស៖** សំណួរបន្ត តាមចំណុចទីពីរនៃឯកសារដែលបានបង្ហាញនេះលោកអាចប្រាប់បានទេ ហេតុអ្វីបានជាលោកសម្រេចមិនរាយការណ៍ជូនអង្គការ ។ តើលោកសម្រេចចេញបញ្ជាដោយខ្លួនឯងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះជា ល្បែង ឬហៅថាជា ល្បិច តាមពិតខ្ញុំរាយការណ៍ជូនអង្គការរួចទៅហើយ នេះគឺគ្រាន់តែជាល្បិចជម្រាបឱ្យ មិត្តប៊ុន យកទៅបង្ហាញ បងយ៉ា ប៊ុនន៎ុង ។

**ស៖** សំណួរបន្ត ចំណុចទីបី លោកសរសេរថា “តាមពិសោធន៍ គឺអាលោក បងយ៉ា ទាល់តែលេងក្តៅ យើងអ្នកនាងជាមួយវាមិនបានទេ ស្នើមិត្តដាក់ទៅ” ។ តើចំណុចនេះមានន័យថា លោកបញ្ជាឱ្យ ប៊ុន ធ្វើទារុណកម្មលើ យ៉ា មែនទេ?

**ឆ៖** ជម្រាបប្រសាសន៍ មែន ។ នេះក៏ជាការសម្រេចរួមពីខាងលើមកដែរ បញ្ជាអនុម័តពីខាងលើមកដែរ ។

**ស៖** អរគុណ។ សំណួរបន្ត តាមរយៈចំណារនេះបង្ហាញថា លោកអស់លទ្ធភាពអត់ធ្មត់ជាមួយ យ៉ា មែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកសហព្រះរាជអាជ្ញា! ថាខ្ញុំហួសលទ្ធភាពអត់ធ្មត់ក៏ថាបាន ប៉ុន្តែតាមពិតជាក់ស្តែង គឺខាងលើគេប្រញាប់ គេកៀក គេអស់លទ្ធភាពអត់ធ្មត់ទៅហើយ ។

**ស៖** សំណួរបន្ត ហើយលោកមានជំនឿថា ទាល់តែធ្វើទារុណកម្មទើបទទួលបានចម្លើយមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ទារុណកម្មជាវិធានការចុងក្រោយ ដូចដែលខ្ញុំបានធ្លាប់ជម្រាបរួចមកហើយ ។

**ស៖** បន្តទៅទៀតនេះ ខ្ញុំសុំសួរសំណួរដែលមិនទាក់ទងនឹងឯកសារ ។ ពាក្យថា “បញ្ជា” និង “ការណែនាំរបស់ថ្នាក់លើ” មានន័យដូចគ្នាដែរឬទេ?

[១១:១៨:២៤]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជាទូទៅ ខ្ញុំបាទផ្ទាល់មើលឃើញប្លែកខ្លះដែរ ។ ខ្ញុំតែងតែនិយាយហូរហែមកហើយថា ខ្ញុំពេញចិត្តបង ខៀវ គឺលោកគ្រូ សុន សេន ជាង ពីព្រោះគាត់បញ្ជាស្អីៗ គាត់លើកហេតុផលមកគាត់ប្រាប់ថា ធ្វើអ៊ីចេះ ។ ដូច្នេះ គាត់ណែនាំ គាត់លើកហេតុផលឱ្យយើងខ្ញុំធ្វើទៅស្រួល ឱ្យខ្ញុំបាទធ្វើទៅស្រួល ។ ឯចំណែក ពូនួន មិនអ៊ីចឹងទេ គាត់មានប្រសាសន៍មួយម៉ាត់មកហ្នឹង គឺយើងត្រូវតែរត់ធ្វើតាម ។ នេះខ្ញុំគិតឃើញថា ពូនួន ងាកទៅរកបញ្ជាច្រើនជាងណែនាំ បងខៀវ គឺលោកគ្រូ សុន សេន ងាកទៅណែនាំច្រើនជាងបញ្ជា ។ យើងខ្ញុំសង្កេតឃើញអ៊ីចឹង ប៉ុន្តែគេ

អង្គុយតុទល់មុខគ្នា ខ្ញុំទៅធ្វើការអង្គុយទល់មុខគាត់ គ្នាពីរនាក់ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ សំណួរបន្ត តើលោកគិតថា ក្នុងសម័យលោកជាអនុប្រធាន និងជាប្រធាន ស-២១ តើលោកបានអនុវត្តតាមបញ្ជាថ្នាក់លើបានកម្រិតណាដែរ?

**ឆ៖** បញ្ហាមានពីរ ។ ទីមួយបញ្ជា ទីពីរគឺគោលការណ៍ ឬក៏មាគ៌ា ។ មាគ៌ា គឺខំណាស់មិនឱ្យល្មើសមាគ៌ាទេ ។ ឯចំណែក បញ្ជា ឬសេចក្ដីណែនាំ ក៏ខំដែរ ខំឱ្យបានជាអតិបរមា ។ ម្ល៉ោះហើយមិនប៊ានឱ្យវៀចទេ ។ គេថាឆ្វេងៗ គេថាស្ដាំៗ គេថាឱ្យវ៉ៃៗ គេថាកុំអាលៗ គេថាយកទៅកម្ទេច ត្រូវតែយកទៅកម្ទេចឱ្យគេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។ ឯចំណែក មាគ៌ា គេថា ស-២១ គ្មានសិទ្ធិចាប់អ្នកណាទេ ខ្ញុំអនុវត្តតាំងពីយូរមកហើយ តាំងពីនៅធ្វើប្រធានម-១៣ មិនដែលមានប៊ានទៅចាប់អ្នកណាទេ ។ ក៏ប៉ុន្តែ មនុស្សដែលគេចាប់មកឱ្យហើយ ត្រូវតែកម្ទេចឱ្យគេ ដោះលែងមិនបាន អត្តនោម័តិមិនបានទេ ។ នេះគឺមាគ៌ា អនុវត្តមិនឆ្គងទេ ។

នេះសូមជម្រាបលោកព្រះរាជអាជ្ញាប៉ុណ្ណេះ ដោយគោរព ។

**ស៖** សំណួរបន្ត លោកបានបញ្ជាក់ច្បាស់ហើយថា កាលណាថ្នាក់ក្រោមមិនអនុវត្តតាមបញ្ជាថ្នាក់លើនឹងត្រូវកំបុតក ។ ចុះហេតុអ្វីបានជាលោកប្រឆាំងនឹងបញ្ជា នួន ជា ដោយលោកលួចប្ដូរថ្នាំពុលមក ជាថ្នាំ*ប៉ារ៉ាសេតាម៉ុល* ឱ្យទៅអ្នកទោសផឹកវិញ ។ លោកមិនខ្លាចកំបុតកទេឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បើសិនជាគាត់ដឹងកំបុតកមែន ក៏ប៉ុន្តែគ្មានអ្នកណាដឹងក្រៅពីខ្ញុំខ្លួនឯងម្នាក់ទេ សូម្បីតែប្រពន្ធក៏មិនដឹងផង ។ ដូចខ្ញុំបានជម្រាបបញ្ជាក់រួចមកហើយ ។

**ស៖** សំណួរបន្ត តើលោកអាចចាំបានទេ អ្នកសួរចម្លើយរំលោភបំពានរាងកាយលើអ្នកគ្រូឈ្មោះ ឌឹម សារឿន នោះ មានឈ្មោះអ្វី?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំអត់បានដេញដោលសួរឈ្មោះទេ ព្រោះអង្កាល់នោះ ខ្ញុំគិតថា វាជាការល្មើសវិន័យធ្វើទារុណកម្មប៉ុណ្ណឹង ដូច្នេះគ្រាន់តែឱ្យដកចេញភ្លាម ហើយលែងឱ្យសួរអ្នកទោសស្រីតទៅទៀត ហើយខ្ញុំចាត់តាំងជួរកម្មាភិបាលស្រី សួរអ្នកទោសស្រី ។ អត់មានបានសួរឈ្មោះ អត់ដឹងទេ ។ សូមអរគុណ ។

[១១:២២:៣៥]

**ស៖** សំណួរបញ្ចប់ តាមការអះអាងរបស់លោក កាលពីព្រឹកថ្ងៃអង្គារ៍ សប្ដាហ៍មុន លោកបានបញ្ជាក់ថា រាល់អ្នកទោសដែលឆ្លើយចំពោះមុខសមត្ថកិច្ច មិនដែលសារភាពការពិតទាំងអស់ឱ្យសមត្ថ-

កិច្ចដឹងទេ សូម្បីតែរូបលោកផ្ទាល់ដែលជាប់គុកជំនាន់ សីហនុ ក៏លោកសារភាពការពិតប្រហែល ហាសិបភាគរយប៉ុណ្ណោះ ដល់សមត្ថកិច្ចមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍មែន ។

**ស៖** សំណួរបន្ត ចុះនៅចំពោះមុខតុលាការនេះ រាល់ចម្លើយសារភាពរបស់លោក តើលោកគិតថាមានការពិតប៉ុន្មានភាគរយ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជាមួយនឹងប៉ូលិសសង្គមចាស់ផ្សេង យើងជាសត្រូវនឹងគ្នា ខ្ញុំជាខ្មែរក្រហម ប៉ូលីសសង្គមចាស់ វាជាឧបករណ៍ផ្តាច់ការរបស់ លន់ នល់, សីហនុ ។ ដូច្នេះ ធាតុពិតវាមិនត្រូវគ្នាទេ ។ ចំណែកតុលាការ រួមទាំងតុលាការយោធាផង យើងខ្ញុំសហការនឹងតុលាការរាយការណ៍ជូនសេចក្តីពិតដល់តុលាការ ក្នុងឋានៈខ្ញុំជាប្រជាជនកម្ពុជាមួយរូបដែលពឹងផ្អែកលើ អ.វ.ត.ក ដែលពឹងផ្អែកលើតុលាការយោធា តែមិនពឹងផ្អែកលើ គ្រិស្ទ ប៉េស៊ូ ទេ ។

**លោក យ៉េត ចរិយា៖**

អរគុណ ។ បន្តទៅនេះ ខ្ញុំសូមឲ្យសហការីខ្ញុំតាំងសំណួរបន្ត ។ អរគុណតុលាការ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ សហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វីលៀម ស្មីត៖**

អរុណសួស្តីលោក លោកស្រីចៅក្រម លោកមេធាវី និងលោក កាំង ហ្គេកអ៊ាវ ។

ខ្ញុំសូមលើកឡើងចំណុចចុងក្រោយ ដែលលោកបានលើកឡើងថា លោកសហការជាមួយនឹង អ.វ.ត.ក ហើយលោកបានផ្តល់នូវសក្ខីភាពនៅទីនេះ ។

[១១:២៥:06]

កាលពី ពីរអាទិត្យមុន លោកបានផ្តល់ចម្លើយយ៉ាងច្រើន ចំពោះសំណួររបស់អង្គសវនាការ ទាក់ទងទៅនឹងកិច្ចប្រតិបត្តិការរបស់ស-២១ និងតួនាទីរបស់លោក ។ ហើយសហចៅក្រមស៊ើបអង្កេតក៏បានសួរលោកច្រើនដែរ កាលពីឆ្នាំទៅមិញ ។ វាហាក់ដូចជាបង្ហាញថា កាលពីពីរសប្តាហ៍មុន លោកមានភាពស្មោះត្រង់ចំពោះ អ.វ.ត.ក ហើយវាហាក់ដូចជាបង្ហាញថា លោកបានផ្តល់នូវចម្លើយយ៉ាងច្រើន ហើយលោកបញ្ជាក់យ៉ាងច្បាស់អំពីសមកម្មភាពរបស់លោក ។ ហើយនៅពេលដែលខ្ញុំនិយាយអំពីករណីនេះ គឺខ្ញុំនិយាយអំពីតួនាទីរបស់លោក ដែលលោកមាន កាលពីមុននៅក្នុងការប្រព្រឹត្តិឧក្រិដ្ឋ

កម្មនៅស-២១ តួនាទីរបស់អនុប្រធានរបស់លោកគឺ ហ៊ ។ ហើយក៏ខ្ញុំលើកឡើងអំពីសកម្មភាពរបស់លោកនៅក្នុងឆ្នាំ៧៨ នៅស-២១ វាហាក់ដូចជាបង្ហាញពីកំណត់ហេតុថា វាមានភាពមិនស៊ីគ្នារវាងអ្វីដែលលោកបានលើកឡើងនៅចំពោះសហចៅក្រមស៊ើបអង្កេត និងអ្វីដែលលោកបានរៀបរាប់ជូនអង្គសវនាការកាលពីពីរសប្តាហ៍ទៅមិញ ។

**ស៖** ដូច្នេះសំណួររបស់ខ្ញុំដែលចង់ចោទសួរនោះ ថាតើលោកសម្រេចចិត្តថា លោកនឹងនិយាយស្មោះត្រង់ជាមួយនឹងអ.វ.ត.ក ឬក៏លោកមិនមានឱកាសពេញលេញ កាលពីលើកមុនចំពោះករណីនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំដាក់ខ្លួនឆ្លើយចំពោះចៅក្រមស៊ើបអង្កេតឲ្យត្រង់ក៏ដូចជាដាក់ខ្លួនឆ្លើយជូនអង្គសវនាការយើងនេះឲ្យត្រង់ ។ ចំណុចដែលយើងខ្ញុំឆ្លើយប្លែកគ្នា យើងខ្ញុំនឹកមិនទាន់ឃើញទេ បើលោកព្រះរាជអាជ្ញាឃើញត្រង់ណាដែលវាប្លែកគ្នា សូមមេត្តាបង្ហាញខ្ញុំឲ្យបានដឹងផង ដើម្បីឲ្យខ្ញុំយល់ ។ សូមអរគុណ ។

**ស៖** សូមអរគុណ ។ អង្គសវនាការនិងភាគី នឹងបង្ហាញអំពីភាពប្លែកគ្នា ប៉ុន្តែក្នុងពេលដែលការដេញដោលសំណួររបស់ខ្ញុំ ខ្ញុំនឹងលើកឡើងអំពីប្លែកគ្នានៅក្នុងព្រឹកនេះ ឬក៏នៅថ្ងៃរសៀល ។ នៅពេលនេះ គឺយើងសូមមិននិយាយអំពីចំណាររបស់លោក និងបញ្ហាជាលាយលក្ខណ៍អក្សររបស់លោក ។ យើងនិយាយអំពីថា តើលោកដំណើរការស-២១ យ៉ាងម៉េចក្នុងការងារប្រចាំថ្ងៃរបស់លោក? ដើម្បីឲ្យលោកផ្តល់នូវការយល់បន្តិច ថាតើលោកធ្វើការងាររបស់ក្នុងកម្រិតណាដែរ? ហើយតើលោកបំពេញការងារទាំងឡាយនោះក្នុងកម្រិតមួយណា? លោកបានបញ្ជាក់ថ្មីៗថា លោកមានភារកិច្ចបី នៅស-២១ គឺការគ្រប់គ្រងចាត់ចែង ការដោះស្រាយបញ្ហាផ្សេងៗ គឺការបង្រៀនបណ្តុះបណ្តាល ហើយភារកិច្ចទីបីគឺធ្វើចំណារនិងធ្វើការវិភាគទៅលើចម្លើយសារភាព ។ លោកនិយាយថា ភារកិច្ចនីមួយៗ គឺចំណាយពេលរបស់លោកមួយភាគបី ដើម្បីឲ្យយើងយល់ឲ្យមានភាពងាយស្រួល ខ្ញុំចង់សួរសំណួរមួយចំនួនអំពីការដែលលោករស់នៅឯណា? ហើយនិងជីវិតគ្រួសាររបស់លោកនៅស-២១? ហើយខ្ញុំនឹងសួរអំពីការិយាល័យរបស់លោក តើលោកមានបុគ្គលិកប៉ុន្មាន? ហើយនិងការងារប្រចាំថ្ងៃរបស់លោក? ហើយតើលោកចំណាយពេលរយៈពេលប៉ុន្មានថ្ងៃក្នុងការចាត់ចែងការងាររបស់លោក? ហើយលោកចំណាយពេលរយៈពេលប៉ុន្មានក្នុងការធ្វើចំណារ និងធ្វើការបង្រៀនបុគ្គលិក?

សំណួរដំបូងរបស់ខ្ញុំ គឺនៅពេលដែលលោកមកស-២១ ឬក៏នៅពេលដែលត្រូវបានតែងតាំងជាអនុលេខា ស-២១ លោកនៅលីវ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ ។ ខ្ញុំនៅលីវរហូតដល់ថ្ងៃ២០ ធ្នូ ១៩៧៥ ទើបខ្ញុំរៀបការ ។

[១១:៣០:00]

**ស៖** នៅពេលដែលលោករៀបការ ឬក៏មុនពេលនោះ លោកដឹងថា លោកបានចូលរួមនៅក្នុងការសម្លាប់ដោយខុសច្បាប់ទៅលើខ្មាំងផ្សេងៗ ។ លោកដឹងដូច្នេះដោយសារតែលោកធ្វើការនៅម-១៣ ហើយលោកបានដឹងដោយសារតែលោកបានចាប់ផ្តើមធ្វើការងារនៅស-២១ ។ ហេតុអ្វីបានជាលោករៀបការនៅថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៧៥? ហេតុអ្វីបានជាលោកយកបុគ្គលម្នាក់ទៀត មកចូលរួមនៅក្នុងជីវិតរបស់លោក ដោយលោកបានដឹងអំពីការងារកិច្ចការទាំងឡាយដែលលោកបានប្រព្រឹត្តរួចហើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការងារដែលយើងខ្ញុំ ដែលខ្ញុំបាទធ្វើនៅម-១៣ ក៏ដូចជាធ្វើនៅ ស-២១ ទោះបីក្នុងឋានៈអាអនុប្រធានក៏ដោយ ក៏វាប៉ះពាល់ដល់ជីវិតមនុស្ស ។ អ៊ី បើតាមច្បាប់ព្រះពុទ្ធសាសនា ថាវាបាប ក៏ប៉ុន្តែពេលនោះ យើងខ្ញុំឃើញថា វាឧក្រិដ្ឋកម្មមួយ ខ្ញុំបាទក៏បញ្ជាក់ជាហូរហែមកហើយ មុននឹងទទួលភារកិច្ចជាប្រធានម-១៣ គេប្រាប់ថា នេះជាទស្សនៈវណ្ណៈ និងការតស៊ូវណ្ណៈ បក្សអំពាវនាវដល់កុលបុត្ររបស់ខ្លួនឲ្យបំពេញការងារនេះ ។ ត្រង់ដែលចាប់មនុស្សខាងទេជាអ្នកចាប់ ខាងលើកទេជាទទួលខុសត្រូវចំពោះប្រវត្តិសាស្ត្រ ដូច្នេះមិត្តត្រូវតែធ្វើ ។ នេះវាទៅអ៊ីចឹងដូច្នេះ រឿងយកប្រពន្ធ វាជាធម្មតាទេ ខ្ញុំបើតាមគោលគំនិតរបស់ខ្មែរក្រហមនៅឆ្នាំ១៩៧០ អ្នកណាមានអាយុ២៥ឆ្នាំ គេឲ្យរៀបការ ប៉ុន្តែ យើងខ្ញុំមិនទាន់រៀបការទេ ។ ដល់ថ្ងៃ១៧ មេសា ១៩៧៥ យើងខ្ញុំសុំទៅឧស្សាហកម្ម ទៅមិនបាន ក៏សុំរៀបការទៅ ។ ដូច្នេះ យើងខ្ញុំនិយាយពាក្យបារាំងមួយម៉ាត់ទៅចុះថា *ណែសេស៊ីទេ អ៊ុយមែន* វាខំឲ្យខ្ញុំទៅធ្វើរៀបការ ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមរំឭកដល់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិថា យើងកំពុងតែធ្វើសវនាការប្រតិបត្តិការនៅមជ្ឈមណ្ឌលស-២១ ភ្នំពេញ ហើយនិងវាលពិឃាតជើងឯក ។ អ៊ីចឹងសូមតំណាងសហព្រះរាជអាជ្ញាតម្រង់នៅសំណួររបស់ខ្លួនឲ្យចំអង្គហេតុ ដែលត្រូវធ្វើសវនាការការ ទីមួយ ។

ទីពីរ គណនារយៈពេលម៉ោង ដែលសម្រាប់សហព្រះរាជអាជ្ញា ក៏ដូចជាជិតអស់ហើយដែរ ។ ហើយមួយទៀតសូមរំឭកដែលថា បញ្ហាពាក់ព័ន្ធជាមួយនឹងជីវប្រវត្តិរបស់ជនល្មើស ជនជាប់ចោទ គឺយើងនឹងទុកពេលវេលាសមស្របមួយ នៅពេលដែលដំណើរការសវនាការដេញដោលអំពីអង្គហេតុដែលចោទប្រកាន់ចប់សព្វគ្រប់ហើយនោះ គឺនឹងមានឱកាសមួយ ដែលនឹងអង្គជំនុំជម្រះនឹងកំណត់កាលវិភាគ

សម្រាប់ស្តាប់ជីវប្រវត្តិរបស់ជនជាប់ចោទ តាំងពីកុមារភាពរហូតដល់ពេលនេះ ។

[១១:៣៣:៥៤]

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំនឹងមិនសួរសំណួរនេះទៀតទេ ហើយខ្ញុំនឹងសំណួរនេះនៅពេលក្រោយ ។

**ស៖** នៅពេលដែលលោកធ្វើការនៅស-២១ លោករៀបការ ហើយលោកមានពេលវេលា មានផ្ទះមួយចំនួន ។ ហើយផ្ទះចុងក្រោយនោះ គឺលោកស្នាក់នៅរយៈពេលពីរឆ្នាំ គឺចាប់ពីឆ្នាំ១៩៧៧ ដល់រហូតរយៈពេលឆ្នាំ១៩៧៩ ដែលលោកបានគេចចេញពីភ្នំពេញ? ត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះដែលខ្ញុំនៅយូរជាងគេ គឺផ្ទះដែលនៅផ្លូវលេខ--ផ្លូវព្រះមុនីវង្ស ត្រឹមត្រូវហើយ ។ ប្រហែលជាអាចលើសពីឆ្នាំក៏មិនដឹង ។

**ស៖** ដូច្នេះនៅក្នុងពេលហ្នឹង គឺលោកមានកូនពីរនាក់នៅពេលដែលលោកនៅស-២១ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! មុនថ្ងៃ៧មករា ដែលខ្ញុំរត់ចេញទៅ ខ្ញុំមានកូនពីរនាក់ ។

**ស៖** ដូច្នេះយើងដឹងអំពីការដឹកជញ្ជូនដែលលោកមាន គឺលោកមានម៉ូតូមួយ ហើយក៏លោកមានឡានមួយដែរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ជារបបកំណត់ អនុញ្ញាតឲ្យខ្ញុំម៉ូតូតែមួយទេ គឺម៉ូតូសេអ៊ិល៩០ ក៏ប៉ុន្តែវាចេះតែច្រឹមហើយ ខ្ញុំមានឡានពីរ ឡានហ្ស៊ីបនឹងមួយមិនដែលបានប្រើទេ ប្រើបានតែម្តងគត់ទៅឯកជើង ហើយនិងកូនឡានមួយដែលដាក់បានទម្ងន់ប្រាំរយគីឡូហ្នឹងមួយ ។ ដូច្នេះ ឡានទាំងពីរនេះក្រៅរបបកំណត់ទេ ។

**ស៖** គឺនៅពេលដែលលោកនិយាយថា មានការអនុញ្ញាតផ្លូវការពីអង្គការនោះ ថាតើគឺមានការចាត់តាំងរថយន្តសម្រាប់ថ្នាក់ដឹកនាំជាន់ខ្ពស់ ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា!

កម្មាភិបាលមជ្ឈិមបក្សមានកំណត់រថយន្តឲ្យៗ ឯចំណែកកម្មាភិបាលមធ្យមត្រឹមម៉ូតូសេអ៊ិល ។

លេខាធិការកងពល គេមានហ្ស៊ីប ប៉ុន្តែខ្ញុំមិនមែនលេខាកងពលហ្នឹងគេទេ ទុកហ្ស៊ីប ហ្ស៊ីបហ្នឹងកេរដំណែល ណាត ទុកឲ្យ ។

**ស៖** ដើម្បីឲ្យយើងយល់អំពីការងារប្រចាំថ្ងៃរបស់លោក លោកស្នាក់នៅក្នុងផ្ទះរបស់លោកនៅរៀងរាល់យប់ នៅពេលដែលលោកនៅស-២១ គឺលោកស្នាក់នៅជាមួយប្រពន្ធរបស់លោកឬយ៉ាងម៉េច?

**ឆ៖** ប្រពន្ធរបស់ខ្ញុំ មិនស្នាក់នៅជាមួយខ្ញុំរាល់យប់ទេៗ ។

**ស៖** ថាតើប្រពន្ធរបស់លោកនៅជាមួយលោកញឹកញយប៉ុនណា នៅពេលដែលលោកនៅស-២១ គឺគាត់ស្នាក់នៅឆ្ងាយពីលោក ឬមួយក៏គាត់នៅជាមួយលោកជាញឹកញាប់ ថាតើការរស់នៅជាមួយគ្នាហ្នឹង មានរយៈពេលញឹកញាប់ប៉ុនណាដែរ?

**ស៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ការហើយដំបូង ប្រពន្ធរបស់ខ្ញុំ គាត់នៅឯមន្ទីរកាត់ដេររបស់គាត់ឯលង្វែក ក្នុងខេត្តកំពង់ឆ្នាំង តាមដងផ្លូវលេខ៥ ។ ដល់ក្រោយមកបានលេខាបស្ចិមឲ្យគេបញ្ជូនប្រពន្ធខ្ញុំមកនៅជាមួយខ្ញុំ ។ មកដល់ខ្ញុំរាយការណ៍ជូនមេខ្ញុំ លោកគ្រូ សុន សេន គាត់ក៏យកប្រពន្ធខ្ញុំឲ្យទៅធ្វើការនៅមន្ទីរយោធា មន្ទីរពេទ្យ៩៨ នេះ ។ ប្រពន្ធខ្ញុំធ្វើការនៅមន្ទីរពេទ្យ៩៨ ។ ដប់ថ្ងៃជួបគ្នាម្តង ដប់ថ្ងៃជួបគ្នាមួយយប់ ។

**ស៖** ដូច្នេះ គឺប្រពន្ធរបស់លោក គឺកម្រស្នាក់នៅក្នុងផ្ទះជាមួយលោកណាស់? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ត្រឹមត្រូវហើយ ។

**ស៖** ដូច្នេះបើសិនជាយើងផ្តោតអារម្មណ៍ទៅលើផ្ទះដែលលោកស្នាក់នៅប្រហែលជាពីរឆ្នាំហ្នឹង តើមាននរណាគេផ្សេងទៀតរស់នៅក្នុងផ្ទះហ្នឹងទេ ក្រៅពីខ្លួនលោកផ្ទាល់ ហើយនិងម្តងកាលប្រពន្ធលោកមកលេងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ទាំងអស់មានគ្នាបួននាក់ ខ្ញុំមិននិយាយពីប្រពន្ធខ្ញុំទេ ។ នីរសារខ្ញុំបីនាក់ ម្នាក់កាន់កាប់ទូរស័ព្ទ ពីរនាក់ទៀតទទួលភារៈខាងវាយអង្គុលីលេខ ។ ដូច្នេះវាទៅជា ពីរនាក់នោះទៅជាស្មៀនរបស់ខ្ញុំទៅហើយ ។

[១១:៤០:១៥]

**ស៖** ហើយស្មៀន ឬក៏អ្នកទទួលបន្ទុកខាងទូរស័ព្ទថា តើពួកគេមានឈ្មោះអ្វីទៅ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! អ្នកដែលកាន់ទូរស័ព្ទហ្នឹងជាមនុស្សមកពីកងពល ៧០៣ កំបុតដៃស្ដាប់នេះម្ខាង ឈ្មោះ ភន, ម្នាក់ទៀតឈ្មោះ ឆេន ជាអ្នកវាយអង្គលីលេខ ហើយម្នាក់ទៀតឈ្មោះ ថាន់ ជាអ្នកវាយអង្គុយលីលេខដែរ ។ ទាំងអស់បីនាក់ ។

**ស៖** លោកបានប្រាប់សវនាការថា នៅពេលដែលលោករើទៅនៅផ្ទះថ្មី លោកក៏មានការិយាល័យមួយនៅក្បែរហ្នឹងដែរ? មានមន្ទីរមួយនៅក្បែរហ្នឹងដែរ ហើយសម្រាប់ផ្ទះចុងក្រោយរបស់លោកនៅ ស-២១ហ្នឹង លោកក៏មានការិយាល័យធ្វើការមួយ ដែលនៅភ្ជាប់នឹងផ្ទះហ្នឹងដែរ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះនៅរបស់ខ្ញុំបាទ ហើយនិងការិយាល័យនៅទល់ខ្នងគ្នាៗ ឆ្លងតែជញ្ជាំងកំផែងទៅ វាដល់ហើយ ។ ទម្លុះជញ្ជាំងឆ្លងចុះ ឆ្លងឡើង ទម្លុះកំផែងឆ្លងចុះ ឆ្លងឡើង ។

**ស៖** ហេតុអ្វីលោកមានផ្ទះផ្សេង ហើយការិយាល័យធ្វើការផ្សេងអ៊ីចឹង? ម៉េចក៏មិនព្រមដាក់នៅ កន្លែងតែមួយអ៊ីចឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះអាចមានប្រពន្ធមកលេង ដូច្នេះមិនចង់ឲ្យប្រពន្ធលូកលាន់នឹងឯកសារសម្ងាត់របស់សន្តិបាលទេ កុំឲ្យគេមើលមក ឃើញថាបែកការណ៍ដល់ប្រពន្ធ បែកការណ៍សម្ងាត់របស់បក្សដល់ប្រពន្ធ ។

**ស៖** សូមអរគុណ ។ ឥឡូវនិយាយអំពីមន្ទីរដែលលោកធ្វើការចុងក្រោយ ដែលមានរយៈពេលយូរជាងគេនោះ តើលោក ឬក៏អ្នកកាន់ទូរស័ព្ទ និងអ្នកវាយអង្គលីលេខទាំងអស់ហ្នឹង គឺធ្វើការនៅទីហ្នឹងដែរមែនទេ? ហើយតើមានអ្នកណាផ្សេងទៀតដែរ ធ្វើការនៅក្នុងមន្ទីរនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះនៅខាងមុខគឺនៅផ្លូវព្រះមុនីវង្សនុំង មាននីរសារខ្ញុំទាំងបីនាក់នៅជាប្រចាំ នៅជាប្រចាំ ឯចំណែកខ្ញុំ ខ្ញុំធ្វើការនៅខាងក្រោយទល់ខ្នងហ្នឹង ផ្លូវលេខ៩៥ មានតែខ្ញុំម្នាក់ឯងទេ ។ កន្លែងហ្នឹងហើយដែលខ្ញុំ មិត្តហ៊ី កន្លែងហ្នឹងហើយដែលខ្ញុំហៅ មិត្តប៉ុន មកជួបធ្វើការណែនាំ ហើយកន្លែងហ្នឹងហើយដែលអ្នកក្រោមខ្លះ គេមកសុំសេចក្ដីសម្រេចចិត្តពីខ្ញុំ ។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់នោះ អ្នកកាន់ទូរស័ព្ទវាយអង្គលីលេខរបស់លោកហ្នឹង គឺថាធ្វើការនៅក្នុងផ្ទះរបស់លោក ហើយលោកវិញ លោកធ្វើការនៅក្នុងប៊ុយរ៉ូរបស់លោកវិញ ហើយលោកក៏មានអនុប្រធានរបស់លោកហ្នឹង គឺមកមន្ទីរហ្នឹងឯង ដើម្បីមកជួបជាមួយលោក ហើយលោកក៏មាន

អ្នកប្រធានខាងសួរចម្លើយហ្នឹង ក៏មកមន្ទីររបស់លោកដែរ ដើម្បីមកសួរជួយជាមួយលោក គឺឈ្មោះប៉ុន នោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍ត្រឹមត្រូវៗ ។

**ស៖** ដូច្នេះក្រៅពីពេលដែល ហ៊ី មកជួបលោក ឬក៏ប៉ុន មកជួបលោក តើលោកគឺជាមនុស្សតែម្នាក់គត់ ដែលធ្វើការនៅក្នុងការិយាល័យនោះ ឬ?

**ឆ៖** ជម្រាបប្រសាសន៍ពិតមែន ខ្ញុំតែម្នាក់ឯងធ្វើការនៅនុ៎ង ។

**ស៖** តើជាការត្រឹមត្រូវទេ ក្នុងការនិយាយថាការិយាល័យនោះ គឺជាផ្ទះដែរ គឺជាផ្ទះដែលថ្ងៃធ្វើជាកន្លែងធ្វើការ ហើយមានពីរបីជាន់ ឬក៏យ៉ាងហោចណាស់ក៏ពីរជាន់ដែរ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះហ្នឹងបើខ្មែរយើងហៅពីរជាន់ ។ ខ្ញុំពេលណាប្រពន្ធមិនមកទេ ទៅដេកអាលើហ្នឹង ផ្ទះហ្នឹង នៅនឹងការិយាល័យធ្វើការហ្នឹង ។

[១១:៤៥:00]

**ស៖** ហើយលោកក៏បានប្រាប់ អង្គសវនាការដែរថា លោកមានទូរស័ព្ទពីរ គឺមួយជាទូរស័ព្ទភ្ជាប់ផ្ទាល់ទៅនឹងគណៈមជ្ឈិម គឺជាមួយ សុន សេន ឬក៏ នួន ជា ហើយលោកក៏មានទូរស័ព្ទមួយទៀតទៅតាមដែលោកប្រាប់ហ្នឹង គឺសម្រាប់ទៅផ្ទះរបស់ មិត្តហ៊ី គឺមានន័យថា ទូរស័ព្ទពីរខ្សែផ្សេងគ្នា ។

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ពិតមែន ទូរស័ព្ទខ្ញុំពីរ ពីរខ្សែផ្សេងគ្នា ។

**ស៖** ហើយទូរស័ព្ទទាំងពីរខ្សែនោះ តើភ្ជាប់មកនៅផ្ទះរបស់លោក ឬក៏ភ្ជាប់ទៅការិយាល័យដែលលោកធ្វើការ?

**ឆ៖** អរគុណលោកព្រះរាជអាជ្ញា ។ ទូរស័ព្ទទាក់ទងជាមួយ មិត្តហ៊ី នៅកន្លែងធ្វើការៗទេ ។ ឯចំណែក ទូរស័ព្ទភ្ជាប់ទៅជាមួយនឹងមេ នៅឯផ្ទះឯមុខណោះ មិត្តភន ជាអ្នកនៅចាំ ។

**ស៖** ហើយខ្សែទូរស័ព្ទ ដែលភ្ជាប់ផ្ទាល់ទៅ សុន សេន និង នួន ជា នោះ តើលោកមាននរណាគេម្នាក់ ដែលទទួលបន្ទុកដាក់លាក់ទេ? ហើយតើអ្នកដែលកាន់នោះឯងឈ្មោះ ផេង ឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! មិត្ត ផេង ជាអ្នកទទួលខុសត្រូវដាក់ខ្សែទូរស័ព្ទដាក់អីនៅរបស់ស-២១ ទេ ។ ឯចំណែក អ្នកកាន់ទូរស័ព្ទរបស់ខ្ញុំច្បាស់លាស់គឺ មិត្តភន ។ មិត្តភន ហ្នឹងកាន់ទូរស័ព្ទរបស់ខ្ញុំច្បាស់លាស់ កាលណាពីខាងលើហៅមក រត់ពីមុខ មកហៅខ្ញុំឲ្យខ្ញុំទៅនិយាយ ។

**ស៖** តើលោកទាក់ទងគ្នាច្រើនទេជាមួយ មិត្តហ៊ិ តាមទូរស័ព្ទនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! តាមទូរស័ព្ទជាមួយ មិត្តហ៊ិ ខ្ញុំអត់និយាយច្រើនទេ ។ ខ្ញុំហៅទូរស័ព្ទទៅគាត់ ឮគាត់ឆ្លើយ ខ្ញុំសួរថាទំនេរទេ គាត់ថា “បាទ ទំនេរបង” ខ្ញុំថា មកណេះមួយភ្លែត គាត់មកភ្លាម ខ្ញុំហៅតែប៉ុណ្ណឹងឯង ហើយក៏ឃើញគាត់មកដល់ យើងនិយាយគ្នាទៅ ។

**ស៖** អ៊ីចឹង ត្រឹមត្រូវទេ តើនៅពេលដែលយើងអាចនិយាយថា លោកមិនធ្វើការពិភាក្សាកិច្ចការប្រចាំថ្ងៃហ្នឹង តាមទូរស័ព្ទទេ ។ ជាទូទៅ ការពិភាក្សាគ្នាហ្នឹង គឺធ្វើឡើងដោយទល់មុខគ្នា ។ មែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បើខ្ញុំជាមួយនឹងមេខ្ញុំលោកគ្រូ សុន សេន ជាមួយតាមទូរស័ព្ទ ស្ទើរតែរាល់ថ្ងៃ ហ្នឹងមែន មួយថ្ងៃចំណាយពេល ប្រហែលជាអាចមួយម៉ោង ។ ដោយឡែកជាមួយ មិត្តហ៊ិ យើងខ្ញុំមិនដែលនិយាយគ្នាតាមទូរស័ព្ទទេ ហៅ មិត្តហ៊ិ មកជួប ។

[១១:៤៨:២៧]

**ស៖** ដើម្បីឲ្យពួកយើងបានយល់ដឹងឲ្យបានច្បាស់លាស់ អំពីការងារដែលនៅស-២១ ដែលអាចត្រូវធ្វើក្នុងរយៈពេលមួយថ្ងៃនោះ ពីព្រោះអីធម្មតាកិច្ចការប្រចាំថ្ងៃ គឺវាមិនដូចគ្នាទេ ។ ប៉ុន្តែ ជាទូទៅ តើម៉ោងប៉ុន្មានទៅដែលលោកក្រោកពីដំណេក? ហើយម៉ោងប៉ុន្មានទៅលោកចូលគេង នៅពេលដែលលោកធ្វើការនៅស-២១ នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ពេលព្រឹកអ៊ីចឹងយើងខ្ញុំចាប់ផ្ដើម-- ខ្ញុំបាទផ្ទាល់ខ្លួនចាប់ផ្ដើមធ្វើការងារម៉ោង៧ សម្រាកម៉ោង១១ ទៅទទួលទានបាយ មកវិញសម្រាកថ្ងៃត្រង់មួយភ្លែតងើបឡើងហូបផ្លែឈើបន្តិចបន្តួច ហើយចាប់ផ្ដើមការងារទៀតម៉ោងពីរដល់ម៉ោងប្រាំ ខ្ញុំឈប់ហើយទៅហូបបាយ ។ ហើយល្ងាចចាប់ផ្ដើមពីម៉ោងប្រាំពីរ ជួនអីដល់ម៉ោងដប់មួយ ជួនអីដល់ម៉ោងដប់ពីរពេលខ្លះ ការងារប្រញាប់ខ្លាំងតម្រូវឲ្យរហូតដល់ម៉ោងមួយម៉ោងអីក៏មានដែរ ។

**ស៖** ដូច្នេះ ជាមធ្យម ដើម្បីបំពេញការងារគ្រប់គ្រងរបស់លោក ការងារបណ្ដុះបណ្ដាល និងការងារធ្វើចំណារនោះ គឺលោកធ្វើការប្រហែលជាដប់ពីរម៉ោងក្នុងមួយថ្ងៃនៅលើកិច្ចការរបស់ស-២១ តើត្រឹមត្រូវដែរឬទេ?

[១១:៥០:០៨]

**ឆ៖** ជម្រាបប្រសាសន៍ប្រហែលជាប៉ុណ្ណឹង ។

**ស៖** ដើម្បីឲ្យយើងដឹងពីកិច្ចការប្រចាំថ្ងៃរបស់លោកឲ្យបានប្រសើរជាងនេះនោះ តើលោកអាចប្រាប់បានទេ នៅពេលដែលលោកពិសាអាហារនោះ លោកពិសានៅឯណា អាហារពេលព្រឹក អាហារថ្ងៃត្រង់ និងអាហារពេលល្ងាចនោះ? ពីមុននៅក្នុងចម្លើយរបស់លោក លោកបាននិយាយថា លោកមានរោងបាយរួម ហើយលោកពិសាអាហារនៅពេលនោះរួមគ្នា ។ អ៊ីចឹង លោកពិសាអាហារនៅកន្លែងណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះដែលយើងខ្ញុំទទួលទានបាយរួមជាមួយគ្នានុ៎ងនៅជ្រុងផ្លូវលេខ៣៦០ និងផ្លូវ៩៥ អ៎មើ!! និងផ្លូវ១១៣ ។

**ស៖** អ៊ីចឹង សម្រាប់អាហារពេលល្ងាច ដែលលោកពិសា គឺពិសារួមគ្នាជាមួយបុគ្គលិកទាំងអស់ ឬមួយក៏លោកពិសាអាហារថ្ងៃត្រង់ និងអាហារពេលព្រឹកជាមួយបុគ្គលិកទាំងអស់ដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម ។ បើតាមខ្ញុំចាំ ភ្លេចអស់ហើយ បើតាមខ្ញុំចាំ អាហារពេលព្រឹកដូចគ្មានទេ ។

យើងខ្ញុំទទួលទានតែអាហារថ្ងៃត្រង់ ហើយនិងអាហារពេលល្ងាច យើងខ្ញុំទទួលទាននៅរោងបាយ អ៎!ផ្ទះបាយរួម ជាមួយគ្នានោះទាំងអស់គ្នាដោយខានមិនបាន ។

[១១:៥២:00]

**ស៖** នៅពេលដែលលោកនិយាយថា អាហារពេលល្ងាចហ្នឹង គឺពិសាជាមួយបុគ្គលិកដទៃទាំងអស់ផ្សេងទៀតនៅកន្លែងរោងបាយរួមហ្នឹង ។ នៅក្នុងចម្លើយរបស់លោកមួយទៀត លោកនិយាយថា លោកពិសាអាហារពេលល្ងាច ជាមួយនឹងបង ម៉ម ណៃ ហើយនិង មិត្តហ៊ី ហើយនិង មិត្តប៉ុន តែមិត្តហ៊ីជួនកាលមក ជួនកាលអត់ទេ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! កន្លែងទទួលទានបាយហ្នឹងធំៗ មានតែជញ្ជាំងតឿទេ ព័ទ្ធជុំវិញ ហើយមានតុច្រើន តុមួយៗមានកៅអីប្រាំមួយ-ប្រាំពីរ ដូច្នេះនៅក្នុងតុរបស់ខ្ញុំភាគច្រើនបង ម៉ម ណៃ នៅជាមួយ ហើយនិង មិត្តប៉ុន មិត្តហ៊ី មិនសូវមកទេ ។

**ស៖** តើ មិត្តហ៊ី ហ្នឹងពិសាអាហារជាមួយនឹងលោកញឹកញាប់ប្រភេទណាដែរ ឧទាហរណ៍ក្នុងមួយអាទិត្យប៉ុន្មានដងដែរ អាហារពេលល្ងាចហ្នឹង ញឹកញាប់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍ ខ្ញុំមិនចាំទេ មិនអាចប៉ាន់ប្រមាណបានទេ ដូចជាយូរៗម្តងប៉ុននុ៎ង ។

**ស៖** តើបុគ្គលិកណាខ្លះ ដែលហូបអាហារនៅក្នុងផ្ទះបាយរួមហ្នឹង? ឧទាហរណ៍ លោកនិយាយថា ប៉ុន ដែលជាអ្នកសួរចម្លើយ លោកបាននិយាយអំពី ម៉ម ណៃ ហើយនិង ហ៊ី ជួនកាលម្តងម្កាលនោះ តើមានក្រុមណាផ្សេងទៀតដែលមក ហូបអាហារពេលល្ងាចដែរ នៅពេលសម្រាប់អាហារពេលល្ងាចនោះ តើអ្នកយាម ឬក៏អ្នកខាងព័ស្តុភារ? តើអ្នកណាខ្លះដែលមកពិសាអាហារពេលល្ងាចនៅកន្លែងនោះ?

**ឆ៖** សូមនិយាយជម្រាបថា យើងអាចនិយាយមួយម៉ាត់ថាទាំងអស់ លើកលែងតែកងការពារទេ ដែលត្រូវបែងចែកជាពីរពេលសម្រាប់មកហូប ។ កងការពារដាច់ខាតត្រូវតែបែងចែកហើយ ព្រោះបើវាមកទាំងអស់គ្នាមិនបានទេ ។

**ស៖** ដូច្នេះ នៅពេលខ្លះ គឺលោកមានអ្នកយាមខ្លះដែលអត់មាន អត់ត្រូវយាមនោះ បានមកហូបអាហារពេលល្ងាចនៅទីនុំង? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍ត្រឹមត្រូវហើយ ។

**ស៖** ដូច្នេះ ខ្ញុំអាចនិយាយថា ជួនកាលយើងប្រធានខាងផ្នែកអ្នកយាយមហ្នឹងឯង បានមកពិសាអាហារពេលល្ងាចនៅទីនោះដែរ? តើត្រឹមត្រូវដែរឬទេ?

[១១:៥៤:៥៨]

**ឆ៖** ជម្រាបប្រសាសន៍ត្រឹមត្រូវហើយ ។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ទៅ ដែលអាចអង្គុយបាននៅក្នុងផ្ទះបាយរួមហ្នឹង អាចដាក់បានប៉ុន្មាននាក់ទៅ?

**ឆ៖** ជម្រាបប្រសាសន៍! ពេលនោះ ខ្ញុំអត់មានយកចិត្តទុកដាក់គិតគូរ ដល់បញ្ហាអស់នេះទេ ។ អត់យកចិត្តទុកដាក់សោះ បើអាចអ្នកផ្សេងទៀត គេយល់បញ្ហានេះជាងខ្ញុំ ។ ខ្ញុំអត់យល់ដល់បញ្ហានេះទេ ហើយរហូតដល់ថ្ងៃនេះណ៎ា ក៏ប៉ាន់ប្រមាណទំហំទទឹងបណ្តោយនៃផ្ទះហូបបាយហ្នឹង មិនទាន់ ជូនមិនបាន ។

**ស៖** លោកនិយាយថា ផ្ទះបាយរួមហ្នឹង គឺជាផ្ទះបាយមួយធំណាស់ ។ តើលោកអាចធ្វើការប៉ាន់ស្មានទេ ដែលថា មនុស្សឧទាហរណ៍ថាម្ភៃនាក់ អាចចូលរួមបាន ឬក៏មនុស្សអាចពីររយនាក់ ឬក៏មួយរយនាក់អាចចូលរួមអង្គុយញាំរួមគ្នា អង្គុយបរិភោគរួមគ្នានៅក្នុងផ្ទះបាយនោះ?

**ឆ៖** ខ្ញុំសូមប៉ាន់ប្រមាណអ៊ីចេះទៅចុះ ប៉ុន្តែមិនត្រូវទេ សូមបញ្ជាក់ថា អាចមួយរយ ឬជាងមួយរយ តែអាចដូចមិនដល់ពីររយទេ ។ នេះខ្ញុំសូមប៉ាន់ប្រមាណទេ ប៉ុន្តែ ពិតជាមិនត្រូវទេ ប្រហែលជាគេអ្នកផ្សេងទៀតគេយល់ គេច្បាស់ជាងខ្ញុំ ។

**សៈ** ពីមុនលោកបាននិយាយថា លោកត្រូវពិសាអាហារហ្នឹងនៅក្នុងផ្ទះបាយរួមហ្នឹង ។ តើមានន័យថាបុគ្គលិកស-២១ ទាំងអស់ ដែលធ្វើការនៅក្នុងបរិវេណសាលាហ្នឹង គឺត្រូវតែមកពិសាអាហារនៅពេលនោះទាំងអស់ឬ? ឬក៏សម្រាប់តែអាហារពេលល្ងាចទេ ដែលនេះជាគោលការណ៍រួម?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បាយរួមគ្នាជាពីរពេល ពេលថ្ងៃត្រង់ និងពេលល្ងាច ទាំងអស់គ្នាត្រូវតែទៅហូបនៅហ្នឹង អត់មានហូបឯណាផ្សេងបានទេ ។

**សៈ** ដូច្នេះ មិនមានកន្លែងណាសម្រាប់-- ធំសម្រាប់ឲ្យបុគ្គលិកពិសាអាហារទេឬ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ផ្ទះបាយរួមនេះជាផ្ទះធ្វើថ្មីទេៗ ធ្វើអំពីឈើ ដូច្នេះធ្វើឲ្យធំ ល្មមដាក់មនុស្សចុះ ។ ដូច្នេះ មិនមែនជាផ្ទះចាស់ពីសង្គមមកទេ គឺយើងខ្ញុំរុះផ្ទះចាស់ដែលនៅចន្លោះកន្លែងហ្នឹង ហើយធ្វើផ្ទះថ្មី ធ្វើរោងបាយថ្មី ។

**សៈ** ដូច្នេះ យើងអាចនិយាយបានទេថា នៅពេលអាហារថ្ងៃត្រង់ និងពេលអាហារពេលល្ងាចនោះ គឺលោកអាចទាក់ទងជាមួយនឹងបុគ្គលិកស-២១ ភាគច្រើន ដែលធ្វើការនៅក្នុងបរិវេណសាលារៀននោះ ។ មែនទេ?

[១១:៥៨:២១]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បើសិនជា ខ្ញុំមានបំណងចង់និយាយលេងជាមួយនឹងបុគ្គលិកផ្សេងទៀតបាន តាមប្រាថ្នា ប៉ុន្តែយើងខ្ញុំធ្វើម៉េច ខំហូបបាយឲ្យឆាប់ ឆ្អាលនឹងត្រលប់មកផ្ទះវិញសម្រាក ។ អត់បាន និយាយជាមួយនឹងអ្នកណាទេ ។ នេះសូមជម្រាបបញ្ជាក់ប៉ុណ្ណេះ ។

**សៈ** ក៏ប៉ុន្តែនៅពេលដំណាលគ្នានោះដែរ ជាទូទៅគឺលោកតែងតែពិសាអាហារ ជាមួយនឹងប៉ុនដែលជាប្រធានអ្នកស៊ើបសួរនោះ ហើយនិងជាមួយនឹង ម៉ម ណៃ ដែលជាប្រធានអ្នកសួរចម្លើយមួយដែរ ហើយជួនកាលក៏ហូបជាមួយនឹង ហ៊ី ដែរ ។ មានន័យថា តើលោកធ្លាប់ទៅអង្គុយតែតុដដែលឬ នៅពេលពិសាអាហារនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា តុដដែលៗ ហើកន្លែងខ្ញុំ ក៏ដដែលដែរ ។

**ស៖** វាជាការត្រឹមត្រូវក្នុងការនិយាយដែរឬទេ អាហារដែលបុគ្គលិកហូបនៅផ្ទះបាយរួមនោះ គឺវាមានលក្ខណៈល្អជាអាហារ ដែលផ្តល់ជូនទៅដល់អ្នកជាប់ឃុំ គឺអ្នកទោសមែនដែរឬទេ?

**ឆ៖** ល្អ វាពិតជាល្អហើយ ប៉ុន្តែមិនដឹងជាប៉ុន្មានដងល្អជាទេ ច្រើនដងណាស់ ។

[១២:00:00]

**ស៖** លោកបាននិយាយថា របបសម្រាប់អ្នកទោសត្រូវបានសម្រេចដោយថ្នាក់លើរបស់លោក តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ប្រាកដ តែគ្រាន់ថាខ្ញុំមិនចាំ ។

**ស៖** ដោយចាំថាលោកជាប្រធានស-២១ ប្រសិនបើមេរបស់លោកសម្រេចទៅលើរបបអាហារ ដោយសារជាការអនុវត្តខាងផ្នែកយោធា គឺគេនឹងប្រាប់លោកអំពីរបបនោះ ឬក៏គោលការណ៍នោះហើយ ដើម្បីឲ្យលោកប្រាប់ទៅដល់ ហ៊ី ឬក៏បុគ្គលដែលគាត់ចាត់ចែង នៅក្នុងការផ្តល់របបអាហារនោះ តើលោកយល់ស្របដែរឬទេ?

**ឆ៖** បាទ យល់ស្រប ។

**ស៖** ប៉ុន្តែលោកមិនបានចាំការទូរស័ព្ទជាមួយលោកលោក នួន ជា និង សុន សេន ដែលប្រាប់លោកអំពីរបបអាហារនោះថាផ្តល់យ៉ាងម៉េច? តើលោកមិនអាចចាំទៅលើចំណុចនេះទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាប់ប្រសាសន៍លោកព្រះរាជអាជ្ញា! របបអាហារនេះវាកំណត់តាំងពីពេល ដែលខ្ញុំមិនទាន់ឈានជើងមកជាន់ស-២១ មិនទាន់ឈានជើងមកជាន់ភ្នំពេញម្ល៉េះ។ កំណត់ដោយ សុន សេន ទៅលើណាត ដូច្នេះក៏អនុវត្តតហូរហែមក ។

**ស៖** ក្នុងនាមជាប្រធានស-២១ គឺជាភារកិច្ចរបស់លោកក្នុងការធ្វើយ៉ាងណា គឺអនុវត្តទៅតាមរបបអាហារនោះ ហើយមិនមានការផ្លាស់ប្តូរទៅនឹងការកំណត់របបនោះ គឺថាក្នុងនាមលោកប្រធានគឺមិនត្រូវធ្វើយ៉ាងណាកំណត់ថា ពួកគេទទួលរបបមិនច្រើន ហើយក៏មិនតិចទៅតាមអ្វីដែលគេផ្តល់ឲ្យ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំអត់មានពុះពារកែប្រែរបប ដែលអង្គការកំណត់ពីរឿងហូបចុកទេ ។ អត់ប៉ាន១ ។

**ស៖** សូមអរគុណលោកប្រធាន ចំពោះប្រធានបទនេះ គឺខ្ញុំមានប្រហែលជាបន្តិចទៀត តែប៉ុណ្ណោះ ហើយចំណាយពេល រយៈពេលប្រាំនាទី គឺខ្ញុំសូមមើលឯកសារលេខ E63 នៅក្នុងសៀវភៅ

ដែលមានលេខ ERN005247 ហើយគឺ D16 គឺឯកសារនេះដូចគ្នាដែរ ។ គឺខ្ញុំសូមអនុញ្ញាតឲ្យធ្វើការដាក់ឯកសារនេះនៅក្នុងអេក្រង់ ។ សូមលោកប្រធាន សូមបង្គាប់ឲ្យខាងសោតទស្សន៍ធ្វើការភ្ជាប់រូបភាពអេក្រង់របស់សហព្រះរាជអាជ្ញា ។

លោក កាំង ហ្កេកអ៊ាវ តើលោកឃើញរូបភាពនេះ នៅចំពោះមុខរបស់លោក គឺមនុស្សដែលគាត់កំពុងហូបអាហារ ។ សូមលោករៀបរាប់អំពីអ្វី ដែលលោកបានឃើញនៅក្នុងរូបភាពនេះ ?

[១២:០៣:២៤]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះមិនមែននៅក្នុងផ្ទះបាយរួមរបស់ខ្ញុំទេ ។ គឺនៅក្នុងផ្ទះ នៅក្នុងការិយាល័យរបស់ខ្ញុំ ជ្រុងផ្លូវលេខ៩៥ ខាងកើតផ្លូវលេខ៩៥ និងខាងត្បូងផ្លូវលេខ៣១០ បើតាមខ្ញុំយល់ ខ្ញុំគិតថា នេះគឺជាថ្ងៃដែលយើងខ្ញុំរៀបការឲ្យ មិត្តខឿន និង មិត្តហ៊ុយ ព្រោះឃើញពីរនាក់ហ្នឹងអង្គុយជិតគ្នា ។ ដូច្នេះ មិនមែនជាថ្ងៃបរិភោគអាហារធម្មតាទេ ។ លោកមើលនៅក្នុងជួរខាងស្តាំដៃយើងអ្នកមើលទីមួយមនុស្សផ្សេងទេ មនុស្សប្រុសទីមួយនោះមនុស្សផ្សេងទេ មនុស្សប្រុសទីពីរ គឺមិត្តហ៊ុយ មនុស្សស្រីនៅអង្គុយទីបីនេះគឺ មិត្តខឿន ប្រពន្ធគាត់សក់រាងក្រញាញ់បន្តិច ។

**ស៖** នៅពេលដែលលោកនិយាយថា សមមិត្ត ហ៊ុយ គឺសមមិត្ត ហ៊ុយ ដែលជាប្រធានអ្នកយាម ឬក៏ ហ៊ុយ ជាអ្នកណាផ្សេងទៀត?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាអាជ្ញា! មិត្តហ៊ុយ អ្នកយាម មិត្តហ៊ុយ លេខាកងពិសេសនៅលើវទេ មុន ៧ មករា មិត្តហ៊ុយ កងពិសេស នៅលើវទេ ។ ឯកចំណែក មិត្ត ហ៊ុយ ស្រែនេះ ទើបនឹងការនេះ ។ នុន ហ៊ុយ គឺ ហ៊ុយ ព្រៃស ។

**ស៖** តើលោកអាចបញ្ជាក់ឡើងវិញដែរឬទេ? គឺអង្គភាពពិសេសនោះ ថាតើគេមានភារកិច្ចអ្វីនៅ ស-២១?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំសូមរក្សាសិទ្ធិមិននិយាយ អំពីអង្គភាពពិសេសនេះទេ ។

**ស៖** ហេតុអ្វីបានជាលោករក្សាសិទ្ធិនៅស្ងៀមមិននិយាយ អំពីអង្គភាពពិសេសនេះ?

**ឆ៖** ពីព្រោះខ្ញុំមិនមានអីបន្ថែមពីលើរឿងដែលខ្ញុំបានរាយការណ៍ជូនអង្គសវនាការនេះ ក៏ដូចជាបានរាយការណ៍ជូនលោកចៅក្រមស៊ើបអង្កេតរួចហើយ ។

[១២:០៦:០៩]

**ប្រធានអង្គជំនុំ៖**

អង្គភាពពិសេសហ្នឹង គឺអង្គជំនុំជម្រះបានសួរសព្វគ្រប់រួចហើយ លើកលែងតែចំណុចជាក់លាក់ណាមួយដែលមិនច្បាស់ទើបអាចសួរបាន ។ បើសិនជាសួរលក្ខណៈទូទៅវាជាសំណួរចំដែលមិនអនុញ្ញាតឲ្យសួរទៀតទេ ។

**លោក វីលៀម ស្មីត៖**

អរគុណលោកប្រធាន ខ្ញុំធ្វើយ៉ាងណា ចៀសវាងសំណួរដែលសួរពីមុនទៅលើអង្គហេតុនេះ ។

**ស៖** ប្រសិនបើយើងមើលរូបភាពនៅខាងឆ្វេង គឺជារូបលោក តើត្រឹមត្រូវដែរឬទេ លោក កាំង ហ្គេកអ៊ាវ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ត្រឹមត្រូវហើយរូបខ្ញុំ ។

**ស៖** នៅពេលដែលយើងមើលរូបភាពនេះ គឺវាហាក់ដូចជាលោកមិនបានចូលរួមក្នុងការពិសាអាហារនេះទេ គឺលោកធ្វើការគ្រប់គ្រងត្រួតត្រាទៅលើការហូបចុកនេះ គឺបានន័យថា នៅពេលនោះគឺលោកធ្វើការគ្រប់គ្រងទៅការហូបចុកនោះ ឬក៏លោកធ្វើការចូលរួមហូបចុកដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំទើបតែដើរចូលមកទេ ហើយដើម្បីបញ្ជាក់ថាពេលនេះជាពិធីមង្គលការ នេះមានជាងថតមួយនៅក្បែរនេះពីក្រោយខ្នងខ្ញុំ ។ បើពិធីហូបអាហារធម្មតាខ្ញុំជឿថា មិនមានជាងថតអ៊ីចឹងទេ ។ ហើយប្រហែលជាតុខ្ញុំ មានមួយកន្លែងផ្សេងទៀត សម្រាប់ខ្ញុំ ។

សូមបញ្ចប់ បញ្ជាក់ជូនប៉ុណ្ណេះ ។

[១២:០៧:៥៥]

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ខ្ញុំបញ្ចប់សំណួររបស់ខ្ញុំលើអង្គហេតុមួយនេះហើយ ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដល់ម៉ោងត្រូវពិសាអាហារថ្ងៃត្រង់ហើយ ។ អង្គជំនុំជម្រះប្រកាស ផ្អាកសវនាការសម្រាប់ព្រឹកនេះ ត្រឹមនេះសិន ។ ហើយលើកបន្តទៅរសៀល ចាប់ពីម៉ោងមួយសាមសិបនាទី សូមអញ្ជើញភាគីចូលរួម ដើម្បីដំណើរការតាមម៉ោងកំណត់នេះ ។

អនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់មកវិញមកកាន់ទីនេះ ឲ្យបានមុនម៉ោងមួយសាមសិបរសៀលល្ងាចនេះ ។

*[សវនាការសម្រាកពីម៉ោង ១២:០៩នាទី ដល់ម៉ោង ១៣:៣០នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោល ហើយក៏សូមប្រគល់វេទិកានេះទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិដើម្បីបន្តសំណួរដេញដោលដល់ជនចាប់ចោទ ។ សូមអញ្ជើញ ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** សូមអរគុណលោកប្រធាន! លោកប្រធាន ខ្ញុំដឹងថាខ្ញុំនៅសល់រយៈពេលសែសិបនាទីទៀតក្នុងការសួរដេញដោល ប៉ុន្តែខ្ញុំក៏ចង់សុំដែរ ដោយសារតែរយៈពេលនៃការឆ្លើយរបស់ជនជាប់ចោទនោះ ខ្ញុំនឹងផ្តោតសំណួររបស់ខ្ញុំឲ្យបានជាក់ ហើយខ្ញុំសុំការអនុញ្ញាតទៅលើចំណុចនេះក្នុងការតាំងសំណួរ។ ហើយគឺថាខ្ញុំនឹងធ្វើការស្នើសុំទៅដល់អង្គសវនាការប្រសិនបើមានការចាំបាច់ណាមួយទៅលើការដេញដោលនេះ ។ លោក កាំង ហ្គេកអ៊ាវ សូមអរគុណច្រើនចំពោះការឆ្លើយរបស់លោកនៅព្រឹកមិញ ហើយវាជួយឲ្យយើងយល់ថា តើលោករស់នៅក្នុងជីវិតប្រចាំថ្ងៃរបស់លោកយ៉ាងម៉េចក្នុងនាមជាប្រធាន ស-២១? ខ្ញុំគិតថា យើងសន្និដ្ឋានថាលោកធ្វើការដប់ពីរម៉ោងក្នុងមួយថ្ងៃ ហើយតាមអ្វីដែលលោកបានឆ្លើយជូនអង្គសវនាការ គឺលោកបានបែងចែកពេលវេលារបស់លោក គឺមួយភាគបីលើការចារ មួយភាគបីទៀតលើការចាត់ចែងការងារ និងមួយភាគបីទៀតលើការបណ្តុះបណ្តាល ។ ហើយជាមធ្យមនោះ គឺលោកចំណាយពេល រយៈពេលបួនម៉ោងក្នុងមួយថ្ងៃនៅក្នុងភារកិច្ចនីមួយៗ ។ ថាតើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា មិនត្រឹមត្រូវទាំងស្រុងទេ ។ ខ្ញុំចំណាយពេលលើការចារនុ៎ង ស្ទើរតែទាំងស្រុង ស្ទើរតែទាំងស្រុងនៅលើការចារ ។

**ស៖** តើហេតុអ្វីបានជាលោកជម្រាបជូនមេធាវីដើមបណ្តឹងរដ្ឋប្បវេណីថា មួយភាគបីនៃពេលវេលារបស់លោកដោះស្រាយបញ្ហាផ្សេងៗ មួយភាគបីទៀតនៃពេលវេលានោះគឺក្នុងការបណ្តុះបណ្តាល

ហើយមួយភាគបីទៀត គឺការឆ្លើយតបទៅនឹងថ្នាក់លើចំពោះចំណាររបស់លោក ។ ហេតុអ្វីបានជាជម្រាបមេធាវីដើមបណ្តឹងរដ្ឋប្បវេណីទៅលើការបែងចែកដូច្នោះ?

[១៣:៣៣:៣៥]

**ឆ៖** ខ្ញុំគិតថាជារឿងបកប្រែទេដឹង ឬយ៉ាងម៉េច? ខ្ញុំដូចមិនប៉ាន់បែងចែកអីច្បាស់អ៊ីចឹងទេ ។

**ស៖** ប្រហែល ខ្ញុំសូមអានទៅលើការដកស្រង់សម្តីរបស់លោកជូនឲ្យលោកស្តាប់ ហើយខ្ញុំទុកវាសិនលើករណីនេះដើម្បីឲ្យអង្គចៅក្រមធ្វើការមើលប្រតិចារឹកហើយសម្រេចទៅលើបញ្ហានេះ។ ហើយប្រសិនបើយើងចូលទៅដល់កិច្ចប្រជុំគណៈកម្មាធិការរបស់មន្ទីរស-២១ លោកបានជម្រាបអង្គសវនាការថា លោកមានការប្រជុំពីរបីដងក្នុងមួយថ្ងៃ ហើយការប្រជុំនោះគឺជាមួយនឹងលោកសមមិត្ត ហ៊ី តើលោកចាំទៅលើការលើកឡើងរបស់លោកដូច្នេះដែរឬទេ?

**ឆ៖** មានការអី ខ្ញុំហៅ មិត្តហ៊ី មកប្រាប់ហើយពិគ្រោះគ្នា ។ អានេះវាជាការពិគ្រោះដើម្បីសម្រេចរួមជាមួយគ្នា ថាប្រជុំក៏ថាបានដែរ ញឹកញាប់ណាស់ ។

**ស៖** ហើយតើត្រឹមត្រូវដែរក្នុងការលើកឡើងដែរឬទេ ដោយសារតែ ហ៊ុយ នៅព្រៃស គឺលោកជួបជាមួយសមមិត្តហ៊ី ញឹកញាប់ជាង ហ៊ុយ ស្រែ ដោយសារតែចម្ងាយពីព្រៃសទៅ ស-២១ វាមានលក្ខណៈឆ្ងាយ ។

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! មិនត្រឹមត្រូវទាំងស្រុងទេ ។ ការងារៗខ្ញុំជាប់ជាមួយ មិត្តហ៊ុយ ជាងការងារការពារ ការងារស្អីៗហ្នឹង វាជាប់គ្នាជាងជាមួយនឹងការងារនៅស្រែការអប់រំសាថ្មីមិនជាប់ប៉ុន្មានទេ មិនជាប់គ្នាប៉ុន្មានទេ ។

**ស៖** នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់លោកស្រីចៅក្រម ខាតរ៉ាយថ៍ ដែលលោកស្រីសួរថាស-២១ គឺមានតួនាទីយ៉ាងច្រើននិងទូលាយដូចដែលលោកបានរៀបរាប់នៅពេលនោះ ។ វាមានន័យថា ថាតើស-២១ នោះ ក្នុងការងារប្រចាំថ្ងៃរបស់លោកគឺវាមានការកើតឡើងជាក់លាក់នៅ ស-២១ ដែរឬទេ? ហើយលោកបានឆ្លើយតបទៅនឹងលោកស្រីចៅក្រមថា ត្រឹមត្រូវ ។ ដូច្នេះ ក្នុងកិច្ចប្រជុំគណៈកម្មាធិការរបស់ស-២១ ជាមួយ ហ៊ី នោះ លោកបានដឹងអំពីចំនួនអ្នកជាប់ឃុំ លោកដឹងអំពីស្ថានភាពផ្សេងៗ ហើយលោកដឹងអំពីទារុណកម្ម ហើយលោកបានដឹងអំពីការសម្លាប់ផងដែរ ។តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំដឹងកិច្ចការអស់នេះ ជាគោលការណ៍គឺជារួម ។ ឯចំណែក គេៗជាអ្នកអនុវត្ត គេដឹងល្អិតជាងខ្ញុំ ។

[១៣:៣៧:១៨]

**ស៖** លោកជាអ្នកគ្រប់គ្រង លោកធ្វើការប្រតិភូៗកាន់អំណាចទៅលើក្រោយគាត់ ថាលោកមិនអាចធ្វើអ្វីគ្រប់យ៉ាងទេ? តើត្រឹមត្រូវដែរឬទេ?

**ឆ៖** មិនមែនថា មិនអាចធ្វើអ្វីគ្រប់យ៉ាងទេ ពេលវេលាមិនអនុញ្ញាតឲ្យខ្ញុំធ្វើទាំងអស់បានទេ ។ ដូច្នេះ ត្រូវប្រគល់ការងារខ្លះទៅឲ្យគេ ។

**ស៖** ខ្ញុំមិនមានន័យថា លោកមិនមានសមត្ថភាពនោះទេ គឺលោកមិនមានពេលវេលាគ្រប់គ្រាន់ក្នុងការចាត់ចែងទៅលើការងារទាំងអស់នោះ ។ ថាតើលោកជួបសមមិត្តហ៊ំ នៅឯណានៅពេលដែលលោកជួបជាញឹកញាប់នោះ ។ តើទីកន្លែងជួបគ្នានោះនៅកន្លែងណាដែរ?

**ឆ៖** ខ្ញុំហៅមកផ្ទះ ការិយាល័យរបស់ខ្ញុំនៅផ្លូវលេខ៩៥ ខ្ញុំហៅ ហ៊ំ ឲ្យមកផ្ទះការិយាល័យរបស់ខ្ញុំនៅផ្លូវលេខ៩៥ ។

**ស៖** ហើយលោកក៏បានទៅរោងផ្កាក់ដែលស្ថិតនៅក្នុងបរិវេណសាលារៀននោះផងដែរ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ក្រោយពីអស់សង្ឃឹមក្នុងជីវិត ។ ក្រោយពេលដែលគេចាប់បង ង៉ែត យូ ហៅ ហុង ។ ខ្ញុំទៅនឹងរោងផ្កាក់នោះសឹងរាល់ថ្ងៃ ។

**ស៖** រោងផ្កាក់គឺស្ថិតនៅក្នុងអគារ “ង” នៅក្នុងផែនទីរបស់យើងដែលមាននៅក្នុងរូបភាព គឺនៅក្នុងអគារកណ្តាលនៅក្នុងបរិវេណសាលានោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយ ។

**ស៖** គឺអគារដូចគ្នាដែលអ្នកទោសត្រូវបានថតរូបនិងចុះឈ្មោះ ហើយកត់ប្រវត្តិរូប ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវ ។

**ស៖** ខ្ញុំចង់សួរសំណួរមួយចំនួនទៀតអំពីថា តើលោកដឹងយ៉ាងម៉េច ដឹងអំពីស្ថានភាពឃុំខ្លួន ការសម្លាប់ និងការធ្វើទារុណកម្មយ៉ាងម៉េច? តាមរយៈគណៈកម្មាធិការស-២១ លោកបាននិយាយថាលោកដឹង ហើយមានភស្តុតាងបញ្ជាក់ថា លោកបានចូលរួមនៅក្នុងការងារនោះ ។ ថាតើគណៈកម្មាធិ

ការនេះ វាដំណើរការយ៉ាងម៉េច? ហើយសមមិត្តហ៊ិ ហ្នឹង ប្រាប់លោកទៅលើការងារប្រចាំថ្ងៃនោះយ៉ាងម៉េច? ថាតើលោកបានពិភាក្សាទៅលើប្រភេទការងារនោះយ៉ាងម៉េចខ្លះ?

[១៣:៤០:២៩]

**ឆ៖** ការងារខាងឃុំឃាំង ការងារខាងកម្ទេច យើងទុកឲ្យគេធ្វើការទាំងស្រុង ។ ។ ឯចំណែកមានបាតុភាពអីពិសេសខ្លះ អាហ្នឹងបានៗគេរាយការណ៍បន្ទាន់ឲ្យខ្ញុំ ។ ឧទាហរណ៍ដូចជា អាចារ្យ កង យកអាវុធបាន អាហ្នឹងគេរាយការណ៍បន្ទាប់ឲ្យខ្ញុំ ខ្ញុំរាយការណ៍បន្ទាប់ទៅលើទៀត ។ មេដឹងភ្លាមនៅពេលដែលអាចារ្យ កង យកអាវុធបាន ។ ដូច្នេះការងារពិសេសហ្នឹងមកដល់ខ្ញុំភ្លាម ។ ការងារពិសេសដូចជាអារឿងក្មេងម្នាក់វាទៅធ្វើបាបអ្នកគ្រូ ដឹងដល់ខ្ញុំភ្លាម ខ្ញុំរាយការណ៍ទៅនៅពេលដែលជួបមេ ។ ដូច្នេះ ការងារពិសេសដឹងភ្លាម ឯចំណែកការងារជាទូទៅ គេត្រូវតែធានាចំពោះមុខខ្ញុំថា គ្មានអ្នកណារត់រួច ថាគេអត់ប៉ាានដោះលែងអ្នកណា ថាមនុស្សដែលចូលមកស-២១ ពិតជាត្រូវកម្ទេច អត់មានប៉ាានដោះលែងអ្នកណាទេ ។ នេះគឺ ខ្ញុំក្តាប់រួមអ៊ីចឹង ។

**ស៖** គឺការគ្រប់គ្រងមិនមែនចាំបញ្ហាកើតឡើងនោះទេ គឺការគ្រប់គ្រងនោះ គឺវាអាចធ្វើឡើងនៅពេលដែលលោកធ្វើការទស្សន៍ទាយទៅលើបញ្ហាដែលនឹងកើតឡើង ហើយលោកអនុវត្តវិធីសាស្ត្រក្នុងការដោះស្រាយ ។ ដូច្នេះ ខ្ញុំសន្និដ្ឋានថា ដោយសារបញ្ហានេះហើយទើបលោកជួបញឹកញាប់ជាមួយនឹងហ៊ិ គឺក្នុងរយៈពេលពីរទៅបីដងក្នុងមួយថ្ងៃ ដើម្បីធានាយ៉ាងណាប្រព័ន្ធអនុវត្តការងាររបស់លោកអនុវត្តនៅស-២១ ។ ដោយសារតែមូលហេតុទាំងអស់នេះហើយ ទើបលោកបានជួបញឹកញយជាមួយនឹងហ៊ិ ។ តើត្រឹមត្រូវដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! បើលោកសន្និដ្ឋានអ៊ីចឹង ក៏មិនខុសទេ ក៏ប៉ុន្តែខ្ញុំសូមរាយការណ៍ជូនអំពីការដែលខ្ញុំហៅ ហ៊ិ មកជួប ។ កាលណាចាំបាច់ ខ្ញុំត្រូវការបញ្ហាទៅឲ្យគេ អាហ្នឹងខ្ញុំហៅគេមកជួបដើម្បីណែនាំបញ្ហាផ្សេង ។ ការងារខាងសួរហ្នឹងក៏ដោយ ក៏ខ្ញុំហៅ ហ៊ិ មកប្រាប់ដែរ ។ ថានេះសួរ អានេះឆ្លើយ សួរមនុស្សដូចរាងរាលដាលហើយ មិត្តមើលផង ។ អានេះខ្ញុំហៅគេមកជួបមិនមែនគេៗរត់មករកខ្ញុំទេ ខ្ញុំណែនាំទៅគេ ក៏ប៉ុន្តែ ករណីពិសេសខ្លះគេរត់មករកខ្ញុំ ។ ដូច្នេះ ជាទូទៅគឺខ្ញុំគេមកដើម្បីចេញបញ្ហាថ្មី ។

**ស៖** ដូច្នេះ វាត្រឹមត្រូវក្នុងការលើកឡើងដែរឬទេ? ថាវាមានបញ្ហាតិចតែប៉ុណ្ណោះ វាលេចឡើងគ្រប់ពេលទាំងអស់ថានរណាគេត្រូវតែសម្លាប់? ហើយសម្លាប់នៅពេលណា? ហើយអ្នកទោសហ្នឹងចូល

មកនៅពេលណា? ដោយសារតែលោកបានជួបជាមួយនឹងហ៊ ញឹកញយ មានបញ្ហាកើតឡើងច្រើនណាស់លើការងារប្រចាំថ្ងៃ ។ តើត្រឹមត្រូវដែរឬទេ? ដូច្នេះហើយ ទើបលោកជួបជាមួយ ហ៊ នោះ?

[១៣:៤៣:៣៥]

**ឆ៖** ត្រូវហើយ ។ មានរឿងច្រើណាស់ដែលត្រូវជួបជាមួយ ហ៊ ដោយសារការងារប្រចាំថ្ងៃ ។ ឧទាហរណ៍ ខាងលើប្រគល់អ្នកទោសឲ្យប៉ុន្មាននាក់? ខ្ញុំត្រូវប្រាប់គេភ្លាមថា ចាំទទួលថាម៉ោងប៉ុណ្ណេះមកដល់ហើយ ។ ហ្នឹងហៅគេមកជួប ប្រាប់ភ្លាម ។

**ស៖** ដូច្នេះ នៅពេលដែលលោកដោះស្រាយការងារទាំងអស់នោះ លោកព្យាយាមធ្វើយ៉ាងណាមន្ទីរសន្តិសុខរបស់លោកដំណើរការទៅដោយរលូន?

**ឆ៖** ត្រូវហើយ ខ្ញុំខំពុះពារយ៉ាងនេះឯង ។

**ស៖** ប្រហែលជានៅពេលនេះយើងអាចចូលដល់អង្គហេតុទាក់ទងឆ្នាំ១៩៧៨ ។ លោកបានផ្តល់សក្ខីកម្មនៅថ្ងៃទី៨ ខែមិថុនា នៅទំព័រទី៥២ និង៥៣ ថា នៅក្នុងឆ្នាំ១៩៧៨ លោករវល់ខ្លាំងណាស់បើប្រៀបធៀបទៅឆ្នាំមុនៗ ដោយសារតែបក្សត្រូវការយើងច្រើន ហើយយើងត្រូវការបង្ហាត់មនុស្សជាច្រើនទៀត ហើយនិងធ្វើការដុះខាត់អ្នកទាំងអស់នោះ ។ ហេតុអ្វីបានជាបក្សត្រូវការលោកជាងពេលមុននៅក្នុងឆ្នាំ១៩៧៨?

[១៣:៤៥:០០]

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នៅឆ្នាំ១៩៧៦, ១៩៧៧ ខ្ញុំរវល់ណាស់និងចារឯកសារ ។ មួយថ្ងៃៗស្ទើរតែវាល់ល្ងាចនឹងរឿងចារឯកសារ។ ដូចជាខ្ញុំបានបញ្ជាក់ជូនលោកចៅក្រមស៊ើបអង្កេតហូរហែមកហើយថា ក៏ដូចជម្រាបអង្គសវនាការនេះដែរផងយ៉ាងមើលទៅថា ការងារចារឯកសារនេះមកដល់សម័យ ពួនួន ខ្ញុំចារបានតែមួយរយៈទេ ដល់ក្រោយមកឃើញគាត់មិនសូវយកចិត្តទុកដាក់ ខ្ញុំក៏លែងគិតគូររឿងចារឯកសារទៅ ។ ក៏ប៉ុន្តែ ខ្ញុំបែរជាត្រូវរត់ទៅអប់រំកម្មាភិបាលសួរចម្លើយ អប់រំភ្លាមបញ្ចេញឲ្យគេទៅធ្វើការហ្នឹងភ្លាម ឃើញមិនស្រួលហៅយកមកអប់រំទៀត អាហ្នឹងខ្ញុំធ្វើការអប់រំនេះញឹកញាប់នៅ១៩៧៨ ដូច្នេះ ៧៦ ៧៧ ដើម៧៨ យើងខ្ញុំចារឯកសារជាមូលដ្ឋាន ។ ដល់ពីចុង៧៨មក យើងខ្ញុំអប់រំជាមូលដ្ឋាន ហើយមានពេលទៅអង្គុយដកដង្ហើមបន្ធូរអារម្មណ៍នៅកន្លែងគូរផ្លាក់ដើម្បីកុំឲ្យវាស្ទុះគនឹងជីវិតពេក ។

**សៈ** ប៉ុន្តែ បើសិនជាលោកអាចឆ្លើយសំណួររបស់ខ្ញុំ។ ហេតុអ្វីបានជាបក្សនោះត្រូវការលោកត្រូវការស-២១ ច្រើនជាងមុននៅឆ្នាំ១៩៧៨ នោះ?

**ឆៈ** បក្សត្រូវការស-២១ ច្រើនជាងមុនក្នុងឆ្នាំ១៩៧៨ ព្រោះមនុស្សចូលមកកាន់តែច្រើន ម៉្លោះហើយឲ្យខ្ញុំអប់រំកម្មាភិបាលសួរចម្លើយឲ្យជាប់លាប់ជាប្រចាំ ។

**លោក វីលៀម ស្មីតៈ**

សូមអរគុណ។ លោកប្រធានប្រសិនបើខ្ញុំអាចផ្តល់ឯកសារ65 ឧបសម្ព័ន្ធលេខ4 គឺវាបង្ហាញអំពីតារាងនៃការចាប់ខ្លួននៅស-២១ ដោយគិតជាខែ ។

**ប្រធានអង្គជំនុំៈ**

មន្ត្រីនៅខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធរូបភាពទៅកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ។

**សួរដោយលោក វីលៀម ស្មីតៈ**

**សៈ** លោក កាំង ហ្គេកអ៊ាវ ប្រសិនបើលោកមើលតារាងនេះនៅលើអេក្រង់របស់លោក លោកបានឃើញថាចាប់ពីខែមេសា ឆ្នាំ១៩៧៧ ដល់ ខែមិថុនា ឆ្នាំ១៩៧៨ គឺជាពេលវេលាមួយដ៏មមារញឹកនៅស-២១ ទាក់ទងនឹងចំនួននៃការចាប់ខ្លួនដែលត្រូវបាននាំមកចូលមកមន្ទីរនេះ ។ តើលោកយល់ស្របដែរឬទេ?

[១៣:៤៨:២៤]

**ឆៈ** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំយល់ស្រប ។

**សៈ** ដូច្នេះ វាត្រឹមត្រូវក្នុងការនិយាយដែរឬទេថាចំនួនបុគ្គលដែលត្រូវបាននាំចូលមកស-២១ គឺវាប៉ះពាល់ទៅនឹងភាពមមារញឹករបស់លោកដោយផ្ទាល់ទាក់ទងទៅនឹងការឃុំខ្លួននិងការសម្លាប់ ។ តើលោកយល់ស្របទៅលើចំណុចនេះដែរឬទេ?

**ឆៈ** យល់ស្រប ។

**សៈ** នៅពេលនេះយើងអាចធ្វើការពិនិត្យទៅលើឯកសារលេខ E68 ឧបសម្ព័ន្ធ40 គឺជាតារាងដែលបង្ហាញអំពីចំនួនបុគ្គលិកស-២១ គឺបុគ្គលិករបស់លោកដែលត្រូវបានគេឃុំខ្លួននៅ ស-២១ ហើយក្រោយមកអ្នកទាំងអស់នោះត្រូវបានគេសម្លាប់ចោល។ ប្រសិនបើយើងមើលទៅលើអង្គភាពសួរចម្លើយនេះគឺដកស្រង់ចេញពីបញ្ជីអ្នកទោសដែលបានកែប្រែរួចគឺវាមានអ្នកសួរចម្លើយសែសិបបួននាក់ ដែល

មានសរសេរក្នុងនេះនឹងត្រូវបានសម្លាប់ហើយឃុំខ្លួន និងក្រោយមកត្រូវបានសម្លាប់នៅស-២១ ។ អ្នកស្ទួរចម្លើយទាំងអស់នោះ គឺអ្នកស្ទួរចម្លើយរបស់លោកដែលបានធ្វើទារុណកម្មលើបុគ្គលផ្សេងៗ ។ ថាតើត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំជឿថា ការិយាល័យសហព្រះរាជអាជ្ញាមានតួលេខប៉ុណ្ណោះ គឺពិតជាធ្វើការត្រឹមត្រូវហើយ។

**ស៖** តើចំនួនសាមសិបប្អូននាក់ ដែលជាអ្នកស្ទួរចម្លើយនៅក្រុមអ្នកស្ទួរចម្លើយនៅស-២១ តើយល់ថា តួលេខចំនួនហ្នឹងវាដូចជាត្រឹមត្រូវទេទាក់ទងទៅនឹងការចងចាំរបស់លោក គឺថាចំនួនអ្នកស្ទួរចម្លើយដែល ត្រូវបានគេចាប់ហើយនិងសម្លាប់ចោលនោះ ?

**ឆ៖** ខ្ញុំជឿថា ត្រឹមត្រូវហើយ ។

**ស៖** ទាក់ទងទៅនឹងបុគ្គលិកស-២១ ដែលត្រូវបានសម្លាប់នោះ ។ តើជាការត្រឹមត្រូវទេ ដែលថាលោកត្រូវជូនដំណឹងទៅឲ្យមេរបស់លោកចំពោះការសម្លាប់នោះ ដែលថាត្រូវទទួលការឯកភាពពីមេខាងលើ? តើត្រឹមត្រូវដែរឬទេ?

[១៣:៥១:០៦]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! មិនមែនជាការជូនដំណឹងទេ គឺការរាយការណ៍ហើយសុំសេចក្ដីសម្រេចចិត្ត ដូច្នេះខុសគ្នាពីជូនដំណឹង ។ ជូនដំណឹង យើងខ្ញុំទាំងពីរនាក់សម្រេចហើយបានប្រាប់ទៅខាងលើ ។ នេះគឺយើងខ្ញុំរាយការណ៍ទៅខាងលើសុំសេចក្ដីសម្រេចចិត្ត ។ ទាំងអស់នេះសុទ្ធតែបានសុំសេចក្ដីសម្រេចចិត្តពីខាងលើ ។

**ស៖** ដើម្បីស្វែងរកការព្រមព្រៀងទៅលើសំណើនោះ ដើម្បីធ្វើការសម្លាប់ពួកគេនោះ ដែលជាបុគ្គលិករបស់លោកនោះមែនទេ?

**ឆ៖** ត្រឹមត្រូវ ។

**ស៖** ទាក់ទងទៅនឹងចម្លើយរបស់លោកនៅចំពោះសហចៅក្រមស៊ើបអង្កេតនៅD71 ដែលមានលេខ 00185499 លោកនិយាយអំពីការសម្រិតសម្រាំងនៅស-២១។ លោកបាននិយាយថា បើសិនជាខ្ញុំចងចាំច្បាស់លាស់នោះនៅក្នុងករណីដែលមិនមែនជាការលើកលែងនោះ គឺខ្ញុំតែងតែរាយការណ៍ទៅថ្នាក់លើ ហើយពួកគេតែងតែគាំទ្រចំពោះការចាប់ខ្លួនអ្នកដែលត្រូវបានគេឆ្លើយដាក់នោះ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! នេះខ្ញុំមិននិយាយអំពីការបកប្រែដែលឃ្លាតន័យបន្តិចបន្តួចនោះទេ ។ ខ្ញុំបានបញ្ជាក់ជូនព្រះរាជអាជ្ញាអម្បាញ់មិញហើយ គឺមុននឹងចាប់ខ្លួនទាល់តែខាងលើសម្រេច ។ ខ្ញុំរាយការណ៍បាតុភាពទៅគេ ខាងលើគេសម្រេចហើយបានៗខ្ញុំចាប់ ។ ធ្វើដូច្នេះបានយើងខ្ញុំមិនមានកំហុស ។

**ស៖** ប៉ុន្តែគឺថាលោកសប្បាយចិត្តណាស់ក្នុងការបញ្ជូនបុគ្គលិករបស់លោកឲ្យទៅជួបសេចក្តីស្លាប់នោះ មែនទេ?

**ឆ៖** អ្ហឺ!លោកមានប្រសាសន៍អ៊ីចឹង វាមិនកើតទេ ខ្ញុំអត់សប្បាយចិត្តអីទេ។ ប៉ុន្តែបើយើងមិនធ្វើវាគ្រោះថ្នាក់ដល់ខ្លួនយើង ជីវិតយើង ។ បើមានបាតុភាពនៅក្នុងអង្គភាពហ្នឹងខុសមាគ៌ាណាមួយដែលយើងមិនធ្វើវាគ្រោះថ្នាក់ដល់ខ្លួនយើង ។ លោក លោកព្រះរាជអាជ្ញា លោកក្រឡេកមើលបញ្ហាដែលកើតមកជាក់ស្តែង ។ ឧទាហរណ៍ បញ្ហាដែលអាក្មេងម្នាក់ វាទៅធ្វើបាបអ្នកគ្រូ បើសិនបើខ្ញុំដឹងថាអាហ្នឹងវាជាឧក្រិដ្ឋកម្ម ខ្ញុំអត់ទុកទេ ។ ដូច្នេះ សប្បាយចិត្ត ឬមិនសប្បាយចិត្ត? បញ្ហាវាកើតមកហើយយើងត្រូវដោះស្រាយ ។ ដូច្នេះ វារឿងដោះស្រាយទេ វាមិនមែនរឿងសប្បាយចិត្ត ដោយចង់សម្លាប់គេទេ ។ នេះគឺរឿងពិត ។

[១៣:៥៤:១៣]

**ស៖** លោកបាននិយាយជាច្រើនដងមកហើយថា តួនាទីរបស់ស-២១ គឺមិនមែនជាតួនាទីមួយដែលយើងសប្បាយចិត្តនោះទេ ។ លោកបាននិយាយប្រាប់សហចៅក្រមស៊ើបអង្កេតថា លោកបានប្រព្រឹត្តនូវអំពើឧក្រិដ្ឋអស់ទាំងហ្នឹងដោយសារតែការភ័យខ្លាចរបស់លោក ឬក៏ជាបច្ច័យ ដែលថាលោកមិនបានអនុវត្តឲ្យបានដិតដល់នោះ ។ ក៏ប៉ុន្តែ លោកបានផ្តល់សក្ខីកម្មនៅថ្ងៃទី២៧ ខែមេសា នៅទំព័រ៨៦ និង៨៧ លោកបាននិយាយថា ខ្លួនលោកផ្ទាល់មានការភ័យខ្លាចនៅពេលដែល វន វ៉េត ត្រូវបានចាប់ខ្លួន ។ហេតុអ្វីបានជាខ្ញុំមិនឃើញមានសភាពបែបនេះនៅពេលដែលអ្នកដទៃទៀត ជាពិសេសថ្នាក់ក្រោមរបស់លោកដែលត្រូវបានចាប់ខ្លួននោះ ។ លោកបាននិយាយថា ខ្ញុំមិនបានគិតអំពីរឿងនោះទេ ។ ខ្ញុំឲ្យតម្លៃខ្លួនខ្ញុំខ្ពស់ជាងអ្នកដទៃទៀតនៅពេលនោះ ។ សំណួររបស់ខ្ញុំសម្រាប់លោកនៅពេលនេះ គឺថា វន វ៉េត ត្រូវបានចាប់ខ្លួននៅថ្ងៃទី២ ខែវិច្ឆិកា ឆ្នាំ១៩៧៨ មានន័យថា គឺនៅចុងឆ្នាំ១៩៧៨ តើលោកឯកភាពនឹងកាលបរិច្ឆេទនេះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំចាំកាលបរិច្ឆេទនេះ បើលោកមិនមានប្រសាសន៍មុន ក៏ខ្ញុំអាចជូនលោកបានដែរ ។ ខ្ញុំចាំ ។

**សៈ** តើលោកអាចប្រាប់ដល់អង្គសវនាការទាំងមូលអំពីហេតុផលថា ហេតុអ្វីពីមុន មុនពេលដែល វន វ៉េត ត្រូវបានចាប់ខ្លួន ។ ហេតុអ្វីបានជាលោក ខ្លួនឯងផ្ទាល់មិនមានការភ័យខ្លាចនៅពេលដែលថ្នាក់ក្រោមរបស់លោកត្រូវបានគេចាប់ខ្លួននោះ? នេះគឺជាពាក្យដែលលោកបានប្រើនៅពេលនោះ ។

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ថ្នាក់ក្រោមនៅមន្ទីរស-២១ គឺជាសមាសភាពដែលមានជាប់ជំពាក់ជំពិនជាមួយនឹងកម្មាភិបាលម្នាក់ឈ្មោះ នៅ ផន ហៅ សុខ អតីតលេខាកងពល ៧០៣ ។ ដូច្នេះ វាជាអង្គភាពមួយដាច់ដោយឡែកពីម-១៣ ។ វាសមាសភាពនៅក្នុងមន្ទីរស-២១ មែនក៏ប៉ុន្តែវា ដាច់ដោយឡែកពីម-១៣ ។ បើសិនជាគេចាប់អតីតយុទ្ធជនម-១៣ច្រើន ពិតជាថ្ងៃណាមួយចៀសមិនរួចធ្លាក់មកដល់ខ្ញុំទេ។ ដូច្នេះបានជាខ្ញុំមិនសូវបារម្ភនឹងសុវត្ថិភាពរបស់ខ្លួនឯង ។ តែបារម្ភហើយតក់ ស្លុតនៅពេលដែលគេចាប់កម្មាភិបាលខាងឧត្តរ ពីព្រោះប្រវត្តិខ្ញុំមានជំពាក់ជំពិននៅខាងឧត្តរយូរដែរ ។ នេះជាបញ្ហា ដែលសូមលើកបញ្ជាក់ជូនព្រះរាជអាជ្ញាប៉ុណ្ណោះ ពីរឿងចាប់ខាងក្រោម ពីរឿងដែលអង្គការគេចាប់អ្នកខាងក្រោមខ្ញុំ ។

[១៣:៥៧:៣៥]

**សៈ** ហើយលោកខ្លួនឯងផ្ទាល់ហ្នឹងមានការភ័យខ្លាចនៅពេលដែល វន វ៉េត ត្រូវបានចាប់ខ្លួនពីព្រោះគាត់គឺជាមេរបស់លោកនៅម-១៣ នោះមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ខ្ញុំបានជម្រាបលោកចៅក្រមស៊ើបអង្កេតមកហើយច្បាស់លាស់ នៅពេលដែលខ្ញុំភ័យមែនទែន ចាប់ផ្ដើមភ័យមែនទែន។ គឺនៅពេលដែលគេចាប់ ង៉ែត យូ ហៅ ហុង អាណិកជនចិនម្នាក់ដែលឧបត្ថម្ភបដិវត្តន៍ហើយដែលបដិវត្តន៍ជឿទុកចិត្តយូរហើយ ។ ហើយថ្ងៃខែដែលចាប់អាណិកជនចិន ឈ្មោះ ង៉ែត យូ ហៅ ហុង នេះខ្ញុំភ្លេចបាត់ទៀតហើយ ដូចជានៅដើម ១៩៧៨ ។ នេះខ្ញុំចាប់ផ្ដើមអស់សង្ឃឹមនៅក្នុងជីវិតហើយ ។ ហើយដល់ចាប់ វន វ៉េត, ឆាយ គឹមហ៊ មកទៀត ធ្វើឲ្យខ្ញុំអស់សង្ឃឹមមែនទែន ហើយអស់សង្ឃឹមរហូតទាល់ទន់ជើងទន់ដៃធ្វើការអីមិនកើតនៅពេលថ្ងៃ២ ថ្ងៃ៣ មករា ឆ្នាំ១៩៧៩ ដែលគេឲ្យដកមនុស្សចេញឲ្យអស់ ដកអ្នកទោសចេញឲ្យអស់ ។ នុំងខ្ញុំភ័យទន់ជើងទន់ដៃហើយ ។

**ស៖** លោកនិយាយថា គឺថាលោកអស់សង្ឃឹមមែនទែន ហើយអស់កម្លាំងមែនទែន ក៏ប៉ុន្តែហេតុអ្វីបានជារហូតដល់ចុងបញ្ចប់នៅមុនពេលដែលវៀតណាមចូលមកដល់ភ្នំពេញ លោករវល់មមារញឹកយ៉ាងខ្លាំងជាមួយនឹងភារកិច្ចរបស់លោកក្នុងការចុះចំណារ ក្នុងការគ្រប់គ្រង ហើយនិងក្នុងការសួរចម្លើយនៅស-២១ នោះ ។ តើលោកឯកភាពទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំអត់មានរវល់ទេ ។ ចំណារដូចខ្ញុំបានជម្រាបលោកព្រះរាជអាជ្ញារួចមកហើយថា ខ្ញុំឈប់ចារយូរហើយ នេះចំណារ ។ ឯចំណែកការរៀនសូត្រគេបង្ខំឲ្យធ្វើដោយខានមិនបាន ។ នេះការរៀនសូត្រឲ្យកម្មាភិបាល។ ឯចំណែក ខាងការពារ ខាងបញ្ចេញអី គេទេគេធ្វើ គ្រាន់តែខ្ញុំធ្វើម៉េចឲ្យច្បាស់លាស់ថាគេមិនលួចដោះលែង មនុស្សដែលបញ្ជូនមកពិតជាគេត្រូវយកទៅកម្ទេច នេះគឺប៉ុណ្ណឹង ។ ឯចំណែក ដែលអស់សង្ឃឹមមែនទែនធ្វើការអីមិនកើតនោះ គឺក្រោយថ្ងៃ២ ឬថ្ងៃ៣ មករា ១៩៧៩ ។ នេះអស់សង្ឃឹមមែនទែនធ្វើការអីអត់កើតទេ ដេកទាំងយប់ ដេកទាំងថ្ងៃ ប្រពន្ធដាស់ក៏មិនព្រមដែរពេលនុ៎ង ។

**ស៖** ដូច្នេះ ដើម្បីបញ្ជាក់ឲ្យបានច្បាស់នោះ គឺថ្ងៃខែដែលលោកអស់សង្ឃឹមមែនទែននោះ គឺនៅក្នុងឆ្នាំ៧៩ មែនទេ?

**ឆ៖** សង្ឃឹមដេកទាំងយប់ ទាំងថ្ងៃ គឺឆ្នាំ១៩៧៩ ថាដល់ម៉ោងហើយ រង់ចាំតែពេលម៉ោងនេះ ។

**ស៖** ខ្ញុំចង់ឲ្យលោកគិតឡើងវិញអំពីចម្លើយចុងក្រោយដែលលោកបានលើកឡើងនេះ គឺទាក់ទងទៅនឹងឯកសារមួយ គឺ E52.52 ខ្មែរមានលេខ 00226779 និងអង់គ្លេស គឺមានលេខ 00284080 និងបារាំង មានលេខ 00294526 សូមឲ្យធ្វើការបញ្ចាំងឯកសារនេះនៅលើអេក្រង់ ។

លោក កាំង ហ្កេកអ៊ាវ តើលោកអាចពិនិត្យមើលកំណត់សម្គាល់ដែលមាននៅលើចម្លើយសារភាពរបស់ គីម សុខ នេះ បានដែរឬទេ? តើលោកអាចបញ្ជាក់ថា នេះគឺជាចំណារផ្ទាល់ដៃរបស់លោកបានដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា នេះគឺជាចំណារផ្ទាល់ដៃរបស់ខ្ញុំ ។

**ស៖** តើលោកអាចបញ្ជាក់បានទេ ថាកាលបរិច្ឆេទនៅលើចំណារនេះ គឺថ្ងៃ២៣ ខែធ្នូ ឆ្នាំ៧៨ ?

**ឆ៖** ទទួលស្គាល់ថាពិត ។

**ស៖** ពីមុនខ្ញុំគិតថា លោកបាននិយាយថាលោកបានឈប់ចុះចំណារៗតាំងពីយូរមកហើយ ក៏ប៉ុន្តែបើយើងមើលទៅប្រហែលជាពីរសប្តាហ៍មុនវៀតណាម បានចូលមកទីក្រុងភ្នំពេញ លោកនៅតែរវល់ធ្វើ

ចំណារនៅចម្លើយសារភាព ហើយបើសិនជាលោកមើលចំណារមួយនេះ ចំណារនេះគឺត្រូវបានបញ្ជូនទៅ "បងជាទីគោរព" ទាក់ទងទៅនឹងបញ្ហាលាក់យួន ។ ហើយលោកបានសួរ "សូមអនុញ្ញាតឲ្យខ្ញុំធ្វើការចាប់ខ្លួន ដើម្បីកុំគាត់រត់រួចនាពេលបច្ចុប្បន្ននេះ ដោយគោរព" ។ នៅក្នុងចំណារនេះ គឺលោកបានស្នើទៅបុគ្គលម្នាក់ ឲ្យធ្វើការចាប់ជនជាតិវៀតណាមម្នាក់ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! មនុស្សនេះ ឈ្មោះ ទ្រឹង នៅក្នុងក្របខ័ណ្ឌមន្ទីរស-២១ ។ បាតុភាពមាន យើងខ្ញុំរាយការណ៍ទៅខាងលើ ដូច្នេះ វា១មិនមែនជាចំណារទូទៅទេ វាជាបាតុភាពដែលមាននៅក្នុងអង្គភាពស-២១ ដែលត្រូវតែម្ចាស់ការកុំឲ្យគេបំផ្លាញបាន កុំឲ្យគេរត់រួច តែកាលណាបើទុកបណ្តោយឲ្យគេរួច ឬគេបំផ្លាញស-២១ បានមួយផ្នែកណា គឺយើងខ្ញុំត្រូវទទួលខុសត្រូវ ។

**ស៖** បើយើងមើលលើកចំណារនេះ យើងមើលទៅហាក់បីដូចជា បានថាបុគ្គលនេះមិនត្រូវបានឃុំឃាំងខ្លួននៅស-២១ ទេ ប៉ុន្តែគឺលោកបានស្នើឲ្យចាប់ខ្លួនបុគ្គលនេះ?

**ឆ៖** មនុស្សសំខាន់ដែលនៅសល់ គឺ ទ្រឹង នេះឯង កំពុងតាមដានសកម្មភាពវាជាប់លាប់ជាងគេ ។ ដូច្នេះ យើងខ្ញុំមិនមានលទ្ធភាពទៅតាមដានអ្នកណានៅក្រៅអង្គភាពទេ វាមានលទ្ធភាពតែការតាមដានមនុស្សនៅក្នុងអង្គភាពរបស់ខ្លួន កុំឲ្យគេបំផ្លាញអង្គភាពប៉ុនទ្មឹង ។ ប៉ុន្តែ ឥឡូវនេះ ខាងក្រោមនេះ តាមផ្ទៀងជាក់ស្តែង តាមផ្ទៀងផ្ទាត់ និងជាក់ស្តែងឯកសារនេះខុស ព្រោះខែ០៨ ឆ្នាំ៧៨ វានៅកំពង់ឆ្នាំង គ្មានហេតុផលអ្វីទេ និយាយបង្វែងដានគឺ--

*(អ្នកបកប្រែ៖ សូមឲ្យជនជាប់ចោទនិយាយម្តងទៀត ។)*

[១៤:០៥:៤៣]

**ឆ៖** ឯកសារនេះ ខ្ញុំរកពន្យល់មិនកើតទេណាមួយកំណាត់អ៊ីចឹង ។ "បងជាទីគោរព បញ្ហាលាក់យួននេះ វាជាប់ដល់មូលដ្ឋានតំបន់២៥ ឪពុករបស់ អៀង នីរសារ ហ៊ុយ" ។ អៀង នេះជានីរសាររបស់មិត្តហ៊ុយ ។ មិត្តហ៊ុយ បើតាមខ្ញុំចាំចាប់នៅថ្ងៃ០៦ នុន ហ៊ុយ នៅស្រែហ្នឹង គឺចាប់នៅថ្ងៃ០៦ ខែ១២ ១៩៧៨ ។ ដូច្នេះ អៀង នេះ ប្រហែលជាចាប់រួចទៅហើយ ព្រោះកាលណាចាប់មេ គឺចាប់នីរសារហើយខ្ញុំមិនដឹងជាចារលើចម្លើយអ្នកណា អីអ្នកណាទេ នេះរក១ដើមរកចុងមិនឃើញទេ ។ រួច ទ្រឹង នេះមិនដឹងជានៅក្នុងអង្គភាពណា ។ រួចដល់ក្រោយពីឯកសារនេះ ខ្ញុំមកចារនែ៎ តាមផ្ទៀងផ្ទាត់ និងជាក់ស្តែងឯកសារនេះខុស១ ព្រោះខែ០៨ ៧៨ វានៅកំពង់ឆ្នាំង ។ "វាគ្មានហេតុផលអ្វីទេ និយាយបង្វែង

ដាន" ដូច្នេះ ក៏ស៊ីសួរ-- ឲ្យសួរតទៅទៀត ។ គាត់ប្រុងឲ្យសួរតទៅទៀត-- មិនដឹងទេ មើលមិនច្បាស់ ។ សូមបញ្ជាក់ជូនប៉ុណ្ណឹង ឯកសារនេះរកពន្យល់អីឲ្យច្បាស់ប្រាកដប្រជាមិនបានទេ ។ ពិបាកយល់ វង្វេងអស់ហើយ ទ្រឹង នេះ ក៏មិនដឹងនៅឯណាមែនទែន ។ តាមខ្លឹមដំបូង វាហាក់ដូចជាមនុស្សរបស់ស-២១ ដល់ក្រោយមក សល់តែខែ០៨ ៧៨ នៅកំពង់ឆ្នាំង អត់យល់ ។ ប៉ុន្តែ ទោះបីអត់យល់យ៉ាងណាក៏ដោយ ក៏ខ្ញុំមិនបដិសេធថា ឯកសារនេះក្លែងក្លាយ ពិតជាឯកសាររបស់ស-២១ ។ បើព្រះរាជអាជ្ញាចង់នេះ ឲ្យខ្ញុំសុំអ្នែងចម្លើយសារភាពទាំងខាងក្នុង ឲ្យៗខ្ញុំមើលឲ្យអស់ ។

**ស៖** សូមអរគុណ ។ តើនរណាគេជានិរសាររបស់ប្រធានអ្នកយាមនោះ គឺនរណាគេជានីរសាររបស់ហ៊ុយ?

**ឆ៖** លោកព្រះរាជអាជ្ញា ហ៊ុយ នេះ មិនមែនហ៊ុយ ន៉ែ នេះទេ មិនមែន-- មិនមែនន៉ែ ហ៊ឹមហ៊ុយទេ មិនមានហ៊ឹម ហ៊ុយ ទេគឺ នុន ហ៊ុយ ។ នុន ហ៊ុយ ស-២១ មជ្ឈមណ្ឌលព្រៃស មិត្តអៀង នេះ ពិតជានីរសារគាត់ ខ្ញុំស្គាល់មុខ ខ្ញុំចាំមុខទល់ឥឡូវ ។

**លោក វីលៀម ស្មីត៖**

សូមឲ្យដកឯកសារចេញពីលើអេក្រង់វិញ ។ លោកប្រធាន ខ្ញុំបានសួរនូវសំណួរដែលខ្ញុំមានហើយៗខ្ញុំមានរយៈពេលប្រហែលជាម្ភៃនាទីទៀត ខ្ញុំចង់លើកនូវសំណួរមួយចំនួនសម្រាប់ឲ្យខាងជនជាប់ចោទ ហើយដែលនឹងស៊ីពេលម្ភៃនាទី ហើយនេះគឺជាផ្នែកមួយដ៏សំខាន់នៃសំណុំរឿង ។ ហើយគឺខ្ញុំយល់ថាជាការប្រសើរណាស់ បើសិនជាយើងខ្ញុំអាចទទួលបាននូវចម្លើយពីជនជាប់ចោទ ។

[១៤:០៩:០២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន ចំនួនពេលដែលបានកំណត់បីម៉ោង ត្រូវបានប្រើអស់ហើយ ដោយខាងការិយាល័យសហព្រះរាជអាជ្ញា ក្នុងការសួរសំណួរទៅលើជនជាប់ចោទ គឺថាសំណួរមួយចំនួនដែលត្រូវបានសួរ ។ នៅក្នុងអំឡុងពេលបីឆ្នាំ ឬក៏សំណួរណាដែលថាបានសួរអស់ ឬក៏មិនអស់នោះ គឺជាការជ្រើសរើសខាងសហព្រះរាជអាជ្ញា ថាតើសំណួរដែលបានសួរនោះពាក់ព័ន្ធ ឬក៏មិនពាក់ព័ន្ធ ទាក់ទងទៅនឹងការកំណត់ពេលវេលារយៈពេលបីម៉ោងនោះ?

ពេលដែលខ្ញុំនឹងសួរនោះ គឺអាស្រ័យទៅលើការឆ្លើយរបស់ខាងជនជាប់ចោទ ដូចដែលខាងសហព្រះរាជអាជ្ញាបានលើកកាលពីព្រឹកមិញនេះ ។ ក៏ប៉ុន្តែ ទៅតាមការសម្គាល់មើល គឺខាងជនជាប់ចោទបានឆ្លើយខ្លីៗ ដូច្នេះ ខាងសហព្រះរាជអាជ្ញា មិនអាចរអ៊ូរទាំនិងការកំណត់ពេលវេលានេះបានទេ ។ ថាពេលវេលា មិនអាចនិយាយថាជនជាប់ចោទបានផ្តល់ចម្លើយ ដែលជាចម្លើយវែងៗនោះ ។ ដូច្នេះ លោកប្រធាន ខ្ញុំលើកឡើងថា បើសិនជាមានសំណួរពីខាងសហព្រះរាជអាជ្ញា គឺថាទុកឲ្យពួកគាត់ធ្វើការសួរសំណួរនៅពេលនេះតែម្តង ។

**លោក វីលៀម ស្មីត៖**

លោកប្រធាន ប្រសិនបើខ្ញុំសុំឆ្លើយតបដោយខ្លី ។ លោក លោកស្រីចៅក្រម ជាទីគោរព! នៅផ្នែកនៃរឿងក្តីទាក់ទងទៅនឹងប្រតិបត្តិការស-២១ នេះ គឺជាផ្នែកមួយដ៏សំខាន់នៅក្នុងរឿងក្តីនេះ ។ វាជាបញ្ហាមួយដែលថាជនជាប់ចោទ គាត់មានការភ័យខ្លាចដែរឬទេ? នៅពេលគាត់ធ្វើការនៅស-២១ ហើយគាត់ធ្វើការក្រោមការបង្ខិតបង្ខំ ឬក៏គាត់មានជម្រើសដែរឬទេ? ចំណុចនេះ គឺវាជាផ្នែកសំខាន់នៃរឿងក្តីរបស់យើង ។ សហព្រះរាជអាជ្ញាមានការស្វាគមន៍ចំពោះការណែនាំទៅលើការរៀបចំសវនាការ ហើយខ្ញុំស្នើសុំឲ្យសហព្រះរាជអាជ្ញាធ្វើការសួរសំណួរ សំណួរមួយចំនួនទៀតក្នុងរយៈពេលម្ភៃនាទី ដោយយើងចាំថាពេលវេលាច្រើន ហើយនិងថវិការជាច្រើនដែលបានចំណាយលើតុលាការនេះ ហើយដូច្នេះខ្ញុំសូមលើកឡើងទៅលើគោលគំនិតផ្សេងៗ ថាតើជនជាប់ចោទយល់យ៉ាងម៉េច?

លោកប្រធាន! ប្រសិនជាជនជាប់ចោទគឺគាត់ចង់មកចូលរួមនៅក្នុងតុលាការនេះមែននោះដោយមានគោលគំនិតក្នុងចិត្តថា នឹងប្រាប់សេចក្តីការពិតទៅដល់បញ្ហាផ្សេងៗ ហើយការដូច្នេះប្រសិនជាបញ្ហាដូច្នេះ គឺថាការជំទាស់នេះ គឺវាហាក់ដូចជាមិនមានអ្វីពាក់ព័ន្ធនោះទេ ។

[១៤:១២:៣២]

**លោក ហ្វ្រង់ស្វ័រ រូ៖**

លោកប្រធាន! នៅពេលដែលសំណួរទាំងឡាយ វាជាបញ្ហាសំខាន់នោះ យើងមិនចាំបាច់រង់ចាំសំណួរនៅចុងក្រោយ ដើម្បីសួរសំណួរថាវាជាផ្នែកសំខាន់នោះទេ ។ លោកលើកឡើងត្រឹមត្រូវហើយសំណួរដែលលោកលើកឡើងនេះ វាភាពចាំបាច់ ហេតុអ្វីបានជាលោកទុកសំណួរនេះនៅចុងក្រោយ? ហើយស្នើសុំការអនុញ្ញាតពីប្រធាន ហើយនិងអង្គចៅក្រម សួរសំណួរបន្ថែមទៀតនោះ?

*(ចៅក្រមពិភាក្សាគ្នា)*

[១៤:១៤:១៧]

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអន្តរជាតិ លោកបញ្ជាក់ដោយខ្លីមើល ថាតើការប៉ុនប៉ងនៃការតាំងសំណួរដេញដោលដល់ជនជាប់ចោទទៅមុខទៀតហ្នឹង វាមានខ្លឹមសារសង្កត់ធ្ងន់ទៅលើចំណុចណាខ្លះទៅ? ពីព្រោះលទ្ធភាពនៃការកត់សម្គាល់របស់មេធាវី ហ្វ្រង់ស្វ័រ រូ ដែលបានលើកឡើងជាការត្រឹមត្រូវសមរម្យណាស់ គួរតែត្រូវបានជ្រើសរើសនូវសំណួរណាដែលសំខាន់ៗ ដែលស៊ីជម្រៅពាក់ព័ន្ធទៅនឹងប្រតិបត្តិការជាក់លាក់នៃស-២១ នៅមន្ទីរស-២១ ហើយនិងជើងឯក ។ ចំណែក ឯសំណួរផ្សេងទៀតកម្រិតនៃស៊ីជម្រៅកម្រិតណាហ្នឹង យើងជឿថា លោកយល់ហើយពីព្រោះលោកសិក្សាសំណុំរឿងនេះច្រើនឆ្នាំហើយ ។ ឥឡូវលោកបញ្ជាក់បានទេ ថាតើប៉ុនប៉ងនៃការស្នើសុំម្តៃមីនុតនេះ សួរបញ្ហាអីដែលច្បាស់លាស់ ដើម្បីយើងក្នុងសម្រេចវាជាក់លាក់ វាស្រួលជាង ។

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ។ សំណួរមួយចំនួនទាំងអស់នោះ គឺវាពាក់ព័ន្ធទៅនឹងអង្គហេតុដែលថា ជនជាប់ចោទ គឺមិនស្ថិតនៅក្នុងស្ថានភាពនៃការភ័យខ្លាចដូចដែលគាត់បានលើកឡើងនៅចំពោះមុខអង្គ ឬក៏សហចៅក្រមស៊ើបអង្កេតនោះទេ ។ ហើយខ្ញុំចង់សួរអំពីអង្គហេតុមួយចំនួនដែលគូសបញ្ជាក់ទៅលើអង្គហេតុ ហើយឲ្យគាត់ធ្វើការពន្យល់ទៅលើអង្គហេតុទាំងអស់នោះ ។

លោក លោកស្រីចៅក្រម វាជាការពិបាកៗក្នុងការកំណត់ថា នៅពេលណាដែលគួរតែសួរសំណួរនោះ សំណួរទាំងអស់នោះអាចសួរនៅពេលនេះ ឬក៏យើងអាចសួរនៅពេលក្រោយនៃរឿងក្តីនៅពេលដែលយើងនិយាយអំពីបុគ្គលិកលក្ខណៈរបស់ជនជាប់ចោទ ។ ដូច្នេះ ជាការសម្រេចរបស់អង្គសវនាការថា តើខ្ញុំសួរសំណួរនេះនៅពេលណា? ប៉ុន្តែ សំណួរទោះបីយ៉ាងណាក៏ដោយយើងគួរតែសួរនៅក្នុងដំណាក់កាលណាមួយ ។

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះ យើងកំណត់អនុញ្ញាតយល់ព្រមឲ្យលោកសួរសំណួរម្តៃមីនុតនេះ ហើយសំណួរនេះមិនអនុញ្ញាតឲ្យលោកសួរនៅក្នុងការតាំងសំណួរចំពោះជនជាប់ចោទអំពីប្រវត្តិសាវតារ ជីវប្រវត្តិរបស់ជនជាប់ចោទទៀតទេ លើកលែងតែចំណុចណាដែលមិនជាន់គ្នានៅត្រង់ជីវប្រវត្តិដែលលោកបានសួរនូវពេលនេះ ។

**សួរដោយលោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន ហើយខ្ញុំទទួលយកនូវការលើកឡើងរបស់លោកប្រធាន ។

**ស៖** លោក កាំង ហ្គេកអ៊ាវ ប្រហែលខ្ញុំអាចផ្តល់នូវហេតុផលមួយចំនួនដែលខ្ញុំសូមឲ្យលោកផ្តល់យោបល់ ។ ហេតុអ្វីបានជាលោកខ្លួនឯងមិនមានការភ័យខ្លាចនៅពេលដែលមានការចាប់ខ្លួនបុគ្គលិកថ្នាក់ក្រោមមុនពេលដែលមានការចាប់ខ្លួន វន វ៉េត ។ ខ្ញុំសូមលើកឡើងថា លោកមិនមានការភ័យខ្លាចដោយខ្លួនឯងនោះទេ ដោយសារតែលោកមានការបំពេញការងារល្អ ហើយលោកមានផលប្រយោជន៍ចំពោះបក្សកុម្មុយនីស្តកម្ពុជា តើលោកយល់ស្របដែរឬទេ?

[១៤:១៧:៤៨]

**ឆ៖** បំពេញការងារល្អឲ្យគេ ពិត ។ ផលប្រយោជន៍ឲ្យគេ ក៏ពិតដែរ ។

**ស៖** យើងចូលបន្តទៅលើចំណុចនេះ មេរបស់លោក សុន សេន, នួន ជា ហើយនិង ប៉ុល ពត គឺមានការពេញចិត្តជាមួយនឹងការងាររបស់លោក ហើយមិនមានការរអ៊ូទៅលើបញ្ហាសន្តិសុខផ្សេងៗ ។ ហើយគេយល់ថា លោកជាអ្នកគ្រប់គ្រងមួយដែលមានលក្ខណៈចាត់វិធានការជាមុនក្នុងការដោះស្រាយនិងគ្រប់គ្រងទៅលើគោលនយោបាយ ។ តើលោកយល់ស្របទៅលើចំណុចនេះដែរឬទេ?

**ឆ៖** ខ្ញុំជម្រាបលោកសហព្រះរាជអាជ្ញាដោយត្រង់ ការងារគិតដល់សន្តិសុខប្រទេសជាតិ ក៏ដូចជាការងារគិតដល់សន្តិសុខរបស់អចិន្ត្រៃយ៍មជ្ឈិមគេៗគិតគូរ ។ គេឃើញអ្វីចន្លោះប្រហោងដែលត្រូវឲ្យយើងខ្ញុំធ្វើ ខ្ញុំពុះពាររត់ទាំងយប់ ទាំងថ្ងៃ គ្មានឲ្យខ្វះខាតទេ ។ ដូច្នេះ រឿងគិតគូរដល់សន្តិសុខរបស់គេ រឿងគិតគូរដល់សន្តិសុខរបស់បក្សទាំងមូល គឺគេជាអ្នកគិត ។ គេបញ្ជាមកឲ្យយើងខ្ញុំបំពេញ ដូច្នេះ តែកាលណាបញ្ជាមកហើយ យើងខ្ញុំបំពេញហើយ មិនដែលឲ្យខ្ជោះទេ ។ ថាឲ្យខ្ញុំម្ចាស់ការលើកមាគ៌ាអ៊ីចេះ លើកមាគ៌ាអ៊ីចុះគ្មានទេ មិនមែនតួនាទីរបស់ខ្ញុំទេ ។

**ស៖** ខ្ញុំលើកឡើងថា លោកមិនមានការភ័យខ្លាចមុនពេលដែលមានការចាប់ខ្លួន វន វ៉េត នោះទេ ដូចដែលលោកបានលើកឡើងថា លោកត្រូវបានគេចាត់ទុកដូចឆ្កែប៉ែស្សេ ដូច្នេះហើយទើបគេជឿជាក់លើលោក ហើយលោកជឿថា មេរបស់លោកមានការជឿជាក់លើលោក ដោយសារតែការជឿជាក់ហ្នឹងហើយ ទើបលោកមិនមានការភ័យខ្លាច ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ភ័យវាមានកម្រិតរបស់វា ចាប់តាំងពីចាប់ពួកឧត្តរមក ភ័យតិច ឈានទៅភ័យច្រើនរហូតតទៅ រហូតដល់អស់ជើងអស់ដៃគិតតែពីដេក ។ ដូច្នេះ វាភ័យវាមានកម្រិតរបស់វាទៅអ៊ីចឹង ហើយជឿ

ទុកចិត្តម្យ៉ាងទៀត វាមានទិដ្ឋភាពជឿទុកចិត្តថា ខំធ្វើការឲ្យគេ គេបញ្ជាឆ្វេងៗ គេបញ្ជាស្តាំៗ ទៅទាំងយប់ ទៅទាំងថ្ងៃ តាមចិត្តគេចង់ ។ ដូច្នេះ វាមានការជឿទុកចិត្តថាមិនអី ក៏ប៉ុន្តែ វាមិនឈ្នះការភ័យទេ ។ វាភ័យវាចេះតែឡើងកម្រិត សូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** ខ្ញុំសូមលើកឡើងថា លោកមិនមានការភ័យខ្លាចដោយសារតែលោកមានមោទនភាពចំពោះការងាររបស់លោក និងទិចនិចដែលលោកអនុវត្តទាក់ទងទៅនឹងការធ្វើទារុណកម្មផ្សេងៗ ។ លោកមានមោទនភាពចំពោះបច្ចេកទេសរបស់លោកក្នុងការបណ្តុះបណ្តាលផ្សេងៗ ។ លោកមានមោទនភាពចំពោះតួនាទីរបស់លោកនៅស-២១ ដែលតួនាទីនេះជាផ្នែកមួយនៃការអនុវត្តគោលនយោបាយក្នុងនាមជាអ្នកបណ្តុះបណ្តាល ហើយតួនាទីទាំងអស់នេះហើយ គឺលោកមានមោទនភាព ហើយត្រូវបានផ្តល់តួនាទីទាំងអស់នោះឲ្យធ្វើ ។

[១៤:២១:៤៦]

**ឆ៖** ខ្ញុំសូមជម្រាបលោកព្រះរាជអាជ្ញាដោយត្រង់ថា រឿងដែលខ្ញុំសង្ឃឹមចេះតែសង្ឃឹមថាអាចរស់នឹងគេ គឺរឿងខ្ញុំត្រង់នឹងគេ មិនដែលហ៊ានលាក់ស្អីទាំងអស់ ហ្នឹងជាកត្តាចម្បងគន្លឹះ ។ ឯចំណែកបញ្ហាផ្សេងទៀត ដូចជាខាងការពូកែអប់រំ ជាបញ្ហាបន្ទាប់បន្សំទេ រួមផ្សំទេ ។ អ្នកផ្សេងទៀត គេអាចធ្វើបាន ក៏ប៉ុន្តែ បញ្ហាធាតុពិតមួយដែលគេត្រូវការចាំបាច់ ហើយគេរកចោលខ្ញុំមិនកើត គឺយើងខ្ញុំត្រង់នឹងគេ ។ នេះជាបញ្ហាសំខាន់ ។

**ស៖** ដោយសារបញ្ហានេះហើយ ខ្ញុំគិតថា លោកបាននិយាយនៅក្នុងតុលាការថ្មីៗថា នៅពេលដែលលោកមាន លោក ប៉ុល ពត អមជាមួយលោកនៅក្នុងឆ្នាំ១៩៧៨ លោកមានអារម្មណ៍ចម្លែកមួយ ហើយវាធ្វើឲ្យលោកនឹងមានអារម្មណ៍ស្រួលណាស់ នៅពេលដែលលោកនៅអមជាមួយនឹង ប៉ុល ពត ។ លោកចាំថាលោកបានលើកឡើងចំណុចនេះដែរឬទេ?

**ឆ៖** ជម្រាបលោកព្រះរាជអាជ្ញា! ខ្ញុំអត់ដែលបានទៅអមលោក ប៉ុល ពត ទេ ។ ខ្ញុំទៅរៀនៗ ប៉ុលពត ជាគ្រូបង្រៀននៅពេលនោះ ខ្ញុំអរពិតមែន ពីព្រោះគ្រូខ្ញុំពីលើកមុន គឺលោកគ្រូ សុន សេន ជាអ្នកបង្រៀននយោបាយ ។ សុន សេន ជាបុគ្គលទីប្រាំពីរ ឯចំណែកដល់ឆ្នាំនេះ ខ្ញុំបានឡើងទៅរៀនជាមួយបុគ្គលទីមួយ ខ្ញុំអរ ។ វាមានចិត្ត វាដេករៀងធូរទ្រូងបន្តិច មិនថាធូរទ្រូងទេ ដូចជា វាដូចជាត្រង់ណាម៉េចទេ វាមានការអរបន្តិចខុសពីមុន ។ ដូច្នេះ ខ្ញុំប្រៀបធៀបអ៊ីចឹងទេៗ ពីមុនខ្ញុំរៀនជាមួយបុគ្គលទីប្រាំពីរ ឥឡូវទៅរៀនជាមួយបុគ្គលទីមួយ វាមានការ--

**ស៖** ខ្ញុំលើកឡើងថា លោកមិនមានការភ័យខ្លាចដោយសារតែលោកជាប់ពាក់ព័ន្ធក្នុងលក្ខណ: ខ្ពស់ជាមួយបក្សកុម្មុយនីស្តកម្ពុជា ។ លោកជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹង សុន សេន, នួន ជា ហើយលោកមានការការពារពីពួកគេ មិនមាននរណាប៉ះលោកបាន ។ ដូច្នេះ ហើយលោកមិនមានការភ័យខ្លាច មុនពេលដែល វន វ៉េត ចាប់ខ្លួន ។ តើលោកយល់ស្របដែរឬទេ?

**ឆ៖** រឿងនេះ ខ្ញុំពិបាកកំណត់ខ្លួនឯងណាស់ ។ រឿងខ្ញុំភ័យ ខ្ញុំភ័យមែន ។ រឿងខ្ញុំសង្ឃឹមគេ សង្ឃឹមតិចដែរ តិចដែរអីតិចណាស់ ។ ដូច្នេះហើយបានជាខ្ញុំភ័យ ។

[១៤:២៥:០១]

**ស៖** លោក កាំង ហ្គេកអ៊ាវ តើត្រឹមត្រូវក្នុងការលើកឡើងដែរឬទេ? លោកបានដឹង និងមានចេតនា និងមានឆន្ទ: ហើយធ្វើការបញ្ជាជាបន្តបន្ទាប់ទៅលើការរំលោភបំពានផ្សេងៗ ហើយធ្វើការឲ្យបង្កើតឲ្យមានការភ័យខ្លាចទៅលើប្រជាជនកម្ពុជា?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! បញ្ហានេះការភ័យខ្លាចនៅក្នុងជួរ ការភ័យខ្លាចនៅក្នុងប្រជាជនកម្ពុជាទូទាំងប្រទេស វាពិតជាភ័យនោះវាណាស់ទៅហើយ ។ មិនមែនភ័យខ្លាចតែអ្នកទាំងអស់នោះទេ ខ្ញុំផ្ទាល់ខ្លួនឯងក៏ភ័យណាស់ដែរ ។ ក៏ប៉ុន្តែ អ្នកណាបង្កើតឲ្យមានសភាពការណ៍ភ័យខ្លាចនេះ គឺអចិន្ត្រៃយ៍មជ្ឈិម ។ យើងខ្ញុំជាឧបករណ៍ដែលគេប្រើ ដូច្នេះ វាពិតជាជះឥទ្ធិពលទៅលើសតិអារម្មណ៍ប្រជាជនកម្ពុជា វាពិតជាជះឥទ្ធិពលទៅលើក្នុងជួរចៀសមិនរួច ។ ក៏ប៉ុន្តែ អគ្គបញ្ជាការនៅពីលើខ្ញុំ គឺអចិន្ត្រៃយ៍មជ្ឈិម បើយើងខ្ញុំមិនធ្វើតាមគេ ឆ្វេងៗ ស្តាំៗ ទេ ខ្ញុំកំបុតក ។ នេះសូមជម្រាបអ៊ីចឹង ។

**ស៖** លោក កាំង ហ្គេកអ៊ាវ ខ្ញុំចង់ឲ្យលោកពិនិត្យមើលឯកសារមួយដែលខ្ញុំនឹងបង្ហាញជូនលោក គឺឯកសារ P00515319 គឺឯកសារលេខ D69 ។ លោក កាំង ហ្គេកអ៊ាវ តើលោកអាចមើលឃើញរូបភាពនៅលើអេក្រង់របស់លោកដែរឬទេ?

**ឆ៖** ឃើញ ។

**ស៖** នេះគឺជារូបភាពនេះកូនក្មេងមួយ ហើយប្រហែលជាម្តាយរបស់គេនៅទីនេះ ដែលមានការឃុំខ្លួននៅក្នុងបន្ទប់តូចមួយ ហើយគឺជាបន្ទប់ដែលលោកបានរៀបចំឡើងនោះ ។ នៅក្នុងលក្ខណ:ល្អឆន្ទ:របស់លោកដែលល្អនោះ ហេតុអ្វីបានជាលោកកំណត់ថា បុគ្គលនេះគឺជាសត្រូវឬខ្មាំងនោះ?

**ឆ៖** បញ្ហានេះ អ្នកណាក៏ឆ្លើយមិនរួចដែរ ។ អ្នកដែលគេកំណត់ថា ជាខ្មាំង គឺអចិន្ត្រៃយ៍មជ្ឈិម ហើយនិងពួកបួនក្រុមដែលគេផ្ទេរសិទ្ធិអំណាចឲ្យមានសិទ្ធិសម្រេចកម្ទេច ។ តែពួកម្នាក់ណា អាម្នាក់

ណាក្នុងចំណោមអាពួកបួនក្រុមហ្នឹងវាសម្រេចហើយ សន្តិបាលចាំតែរត់ទៅធ្វើតាមតែគេទេ ។ ដូច្នេះ អ្នកសម្រេចថា បុគ្គលនេះ ហើយនិងកុមារនេះជាខ្មាំងមិនមែនស-២១ សម្រេច មិនមែនខ្ញុំបាទអ្នកសម្រេចទេ គឺពួកអាខាងលើនោះវាសម្រេច ។ បើកាលវាសម្រេចហើយ ស-២១ ត្រូវតែធ្វើតាមវា មិនធ្វើកំបុតក ។

[១៤:២៨:៤៥]

**លោក វីលៀម ស្មីត៖**

ខ្ញុំអស់សំណួរទៀត ហើយលោកចៅក្រម ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្ត គឺវេទិកាទៅមេធាវីអ្នកតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីទាំងបួនក្រុម ហើយសំណួរមុននឹងចាប់ផ្តើមថា តើមានការស្រុះស្រួលគ្នាយ៉ាងម៉េចរវាងរយៈពេលនៃ-- បានបែងចែករួចហើយ បីម៉ោង ហើយបួនក្រុមនេះគឺធ្វើដាច់ដោយឡែកពីគ្នា ឬក៏មានចាត់តាំងតំណាង ដើម្បីធ្វើការដេញដោលចំពោះអង្គហេតុនេះ?

[១៤:៣០:០០]

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមជូនដំណឹងដល់អង្គសវនាការថា មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី យល់ថាការធ្វើតំណាងសម្រាប់បួនក្រុមនោះ គឺមិនអាចធ្វើបានទេរហូតដល់សវនាការថ្ងៃស្អែក ។ ដូច្នេះ យើងខ្ញុំសូមស្នើឡើងថា ក្រុមបួនចាប់ផ្តើមមុនគេ បន្ទាប់មកទៀតក្រុមបី ហើយក្រុមមួយនិងក្រុមពីរ ។ យើងបានឯកភាពធ្វើការបែងចែកពេលវេលាក្នុងចំណោមទាំងបួនក្រុម ហើយសម្រាប់ក្រុមនីមួយៗ គឺមានអ្នកតំណាងតែម្នាក់ដែលនឹងសួរសំណួរដល់ជនជាប់ចោទ ។ សូមអរគុណលោកប្រធាន ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមបួន ហើយតំណាងតែម្នាក់សូមឡើងធ្វើសំណួរពាក់ព័ន្ធជាមួយនឹងការដេញដោលដល់ជនជាប់ចោទលើអង្គហេតុប្រតិបត្តិការស-២១ ហើយនិងជើងឯកផង ហើយសូមបញ្ជាក់ថា រយៈពេលគឺដេញដោលនេះ សរុបមានសែសិបប្រាំមីនុត ។ សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំបាទ សូមគោរពលោកប្រធានអង្គជំនុំជម្រះ លោកស្រី លោកចៅក្រមនៃអង្គជំនុំជម្រះ ព្រមទាំងអង្គសវនាការជាទីគោរព ។ ដើម្បីឲ្យទាន់ពេលវេលា ខ្ញុំបាទសូមចាប់ផ្តើមសួរសំណួរត្រង់ទៅលោក កាំង ហ្កេកអ៊ាវ ហៅឌុច តែម្តងទាក់ទងទៅនឹងប្រតិបត្តិការនៅមន្ទីរ ស-២១ ព្រមទាំងវាលពិឃាតជើងឯក ។

**ស៖** សំណួរទីមួយ ខ្ញុំសូមសួរថា កាលដែលលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច បានធ្វើជាប្រធាននៃមន្ទីរស-២១ រហូតដល់គាត់រៀបការនៅចុងឆ្នាំ១៩៧៥ ឬក៏ជិតចុងឆ្នាំ១៩៧៥ ហើយចន្លោះនោះមកទល់នឹងឆ្នាំ១៩៧៦ ឬ១៩៧៧ ភរិយារបស់លោកមានគភ៌ ឬប្រសូត្របានកុមារតូច ។ តើអ៊ីចឹងមែនទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី រឿងនេះពិត ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសូមភ្ជាប់អ៊ីចេះថា ក្នុងអំឡុងដល់ឆ្នាំ១៩៧៧នោះ គឺចន្លោះដែលលោកឡើងជាប្រធានមន្ទីរស-២១ លោកបានជម្រាបអង្គសវនាការជាច្រើនហើយថា ពេលនោះមានកុមារជាច្រើន ដែលត្រូវបានបញ្ជូនខ្លួនមកមន្ទីរស-២១ ជាមួយនឹងម្តាយរបស់គេ ។ នេះគ្រាន់តែជាការបញ្ជាក់ថា នៅពេលដែលលោកបានដឹងថាកុមារទាំងនោះខ្លះត្រូវបានសាកសួរយកចម្លើយ ខ្លះមិនសួរទេ មុននឹងយកទៅកម្ទេច ។ អ៊ីចឹងចង់សួរថា ពេលលោកត្រឡប់មកផ្ទះវិញ ថ្ងៃលោកធ្វើការនោះអារម្មណ៍របស់លោកជាមួយនឹងឃើញកូនតូចរបស់លោកនិងកុមារដែលបានសម្រេចកម្ទេចនោះ តើអារម្មណ៍លោកយ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! កុមារទាំងអស់នោះ ជាគោលការណ៍យើងណែនាំទៅគេក៏ប៉ុន្តែឲ្យទៅឃើញ ខ្ញុំអត់ឃើញទេ ។ ក៏ប៉ុន្តែ ខ្ញុំមិនយកលេសនេះ ដើម្បីដោះស្រាយបញ្ហានេះទេ ។ កូនរបស់ខ្ញុំ ខ្ញុំជឿថា វាមានជីវិតរស់នៅក៏អាស្រ័យដោយសារខ្ញុំមានជីវិតរស់នៅដែរ បើខ្ញុំត្រូវបក្សសម្រេចចាប់ គឺត្រូវចាប់ទាំងប្រពន្ធ កូនរបស់ខ្ញុំក៏ត្រូវស្លាប់ ។ អាហ្នឹងនិយាយដោយឡែកចំពោះគ្រួសារខ្ញុំទៀត។ អស់ខ្ញុំមួយ ជីដូនខ្ញុំក៏ត្រូវគេចាប់ ឪពុកម្តាយខ្ញុំក៏ត្រូវគេចាប់ ប្អូនខ្ញុំ ប្អូនស្រីទាំងបួននាក់ក៏ពិតជាត្រូវគេចាប់ ។ ដូច្នេះវាអស់ទាំងអស់ ដូច្នេះឃើញគេវាផ្សេង ។ ឯចំណែក ខ្លួនឯងមានកូនត្រូវគិតថាបើចង់ឲ្យកូនហ្នឹងរស់តទៅទៀត ត្រូវខ្លួនឯងរស់ ។ នេះជាទិដ្ឋភាពនៃចិត្តអារម្មណ៍នៅពេលនោះ ។

**ស៖** សូមអរគុណ ។ ខ្ញុំសូមសួរលោកបន្តទៅទៀត ទាក់ទងនឹងជនរងគ្រោះឬដែលនៅមន្ទីរស-២១ ហៅថាអ្នកទោសនោះ លោកតែងតែជម្រាបអង្គសវនាការថា ជនទាំងឡាយដែលបញ្ជូនមកឃុំ

ខ្លួន ឬក៏បញ្ជូលមកស-២១ ចាត់ទុកថាស្លាប់រួចទៅហើយ ក៏ប៉ុន្តែលោកក៏បានជម្រាបជូនសវនាការថា របបហូប ឬម្ហូបអាហារចំពោះអ្នកទោសនោះ គឺមានតិចតួចស្តួចស្តើងណាស់ នេះខ្ញុំបានឮច្បាស់ ។ សំណួររបស់ខ្ញុំ សួរថាតើលោកបានដឹងរបៀបនៃការចែករបបហូប ឬម្ហូបអាហារឲ្យអ្នកទោសដែលមិនទាន់យកទៅកម្ទេចចោលនោះ ដោយវិធីណា ឬរបៀបណា? ឧទាហរណ៍តើចែកកូនចានម្នាក់មួយ ឬដួសជាមួយវែក ជាបបរ ឬក៏ជាបាយ ហើយចែកដូចម្តេច? មានន័យថា ខ្ញុំសូមជម្រាបថា ដោយសារខ្ញុំឃើញរូបភាព ដែលគូរឡើងដាក់អ្នកទោសឲ្យដេកជាប់ខ្នោះជារនង ។ អ៊ីចឹង តើរបៀបនៃចែកម្ហូបអាហារនោះ ចែករបៀបណា ឬក៏ដួសវែកឲ្យហុតជាបបរម្នាក់បន្តិចៗម្តងមួយ? នេះខ្ញុំចង់ដឹង សូមឲ្យលោកមានជាការពន្យល់កន្លែងនេះ?

**ឌ៖** ជម្រាបប្រសាសន៍លោកមេធាវី! សំណួររបស់លោក វាពាក់ព័ន្ធដល់ច្បាប់មនុស្សជាតិ ច្បាប់មនុស្សធម៌ជ្រាលជ្រៅណាស់ ។ ក៏ប៉ុន្តែ ផ្ទាល់ខ្ញុំ ខ្ញុំឆ្លើយមិនរួចទេ ព្រោះខ្ញុំអត់បានទៅមើល ទៅដោះស្រាយបញ្ហានេះដោយផ្ទាល់ ។ ខ្ញុំនិយាយនេះ មិនមែនខ្ញុំគេចពីឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ នៅក្នុងការឃុំឃាំង ក្នុងការផ្តល់របបអាហារ ក្នុងការធ្វើបាបទារុណកម្មខាងផ្លូវចិត្តនៅពេលឃុំឃាំង គឺខ្ញុំទទួលទាំងអស់ ក៏ប៉ុន្តែគ្រាន់តែខ្ញុំមិនបានចុះទៅជាក់ស្តែង ឃើញនឹងភ្នែក ពន្យល់មិនកើត គ្រាន់តែសុំនិយាយថា ស-២១ គុក ស-២១ ហ្នឹងមិនមែនជាគុក ដូចគុកប្រទេសនីតិរដ្ឋទេ គេហៅថា កន្លែងសម្រាប់ទុកមនុស្សមុននឹងយកទៅប្រហារជីវិត ។ បើពាក្យនៅគុកធំ ជំនាន់ដែលខ្ញុំទៅជាប់គុក ហៅថា *សែឡឺ* ប្រហារ ។ នេះគឺវាអ៊ីចឹង ដូច្នេះបើនិយាយអំពីច្បាស់មនុស្សធម៌ ច្បាស់មនុស្សជាតិ វាខុសនោះ វាខុសណាស់ហើយ ។ រួចខ្ញុំនិយាយនេះ មិនមែនថាខុសតែកូនចៅខ្ញុំទេ ខ្ញុំទទួលខុសត្រូវទាំងស្រុងលើបញ្ហានេះ គ្រាន់តែតាមពិតខ្ញុំអត់បានទៅមើលឃើញ ពន្យល់មិនកើត តែទទួលឧក្រិដ្ឋកកម្មនេះ វាមហាឧក្រិដ្ឋហើយទទួល ។

[១៤:៣៨:១២]

**ស៖** សូមអរគុណ ។ សំណួរបន្តទៅទៀត ទាក់ទងនឹងការធ្វើទារុណកម្ម ឬក៏ការសាកសួរយកចម្លើយ ។ លោកបានធ្លាប់ជម្រាបជូនអង្គសវនាការពេលមុនហើយថា មន្ទីរស-២១ គ្មានការចិញ្ចឹមសត្វក្អែប ឬសត្វខ្ទួយ ឬយកម្តុលខ្ទាស់ចាក់ទៅក្នុងក្រចកដៃជើងទេ ។ ប៉ុន្តែ សំណួរដែលខ្ញុំសួរថា តើលោកបានដឹងអំពីការសួរយកចម្លើយអ្នករងគ្រោះ ឬអ្នកទោសដោយការដកក្រចកដៃ ក្រចកជើងប៉ុន្មាននាក់ឬទេ?

**ឆ៖** ដោយឡែក រឿងដកក្រចកដៃក្រចកជើងមាន មិត្តហ៊ី ស្ទុះមករាយការណ៍ឲ្យខ្ញុំ ខ្ញុំថាឈប់ឲ្យឆាប់ ប្រយ័ត្នរាយការណ៍ ។ នេះដឹងដល់ខ្ញុំ ហើយសម្តីមិត្តហ៊ី គាត់និយាយពាក់កណ្តាលទេ គាត់មិនហ៊ានឲ្យចំទេ ។ គាត់ថា អ្ហឺ! ពួកនោះឥឡូវស្រួលណាស់ ទាញ គាត់ប្រើពាក្យទាញ ទាញក្រចកអង្កាល់ហ្នឹងដកក្រចកគេហ្នឹង ប្រយ័ត្នណ៎ារាយការណ៍ណ៎ា ។ ដូច្នេះ ខ្ញុំដឹងថា អ៊ូ! មានឧក្រិដ្ឋកម្មក្នុងរឿងដកក្រចកនេះហើយស្រាប់ហើយ ប៉ះលើប៉ុន្មាននាក់ ខ្ញុំអត់ច្បាស់ទេ ។ ដូច្នេះ ជនរងគ្រោះណាដែលមានប្រសាសន៍ថា គាត់ត្រូវគេដកក្រចក ខ្ញុំអត់ប្រកែកទេ ទទួល ហើយមិនដឹងប៉ុន្មាននាក់ទេ អត់ហ៊ានសន្និដ្ឋានចំពោះមុខអង្គសវនាការយើងទេ ។ ក៏ប៉ុន្តែជឿថា ឧក្រិដ្ឋកម្មនេះវាមាន ។

**ស៖** សូមអរគុណ ។ តើលោកបានដឹងថា ឬលោកជឿថា បន្ទាប់ពីលោកហាមឃាត់បុគ្គលិកក្រោមឱវាទរបស់លោកទាំងនោះ បញ្ឈប់ការធ្វើទារុណកម្ម ដោយការដកក្រចក ឬដុត មានន័យថាដូចជាអុជបារីទៅលើក្រចក ឬក៏អុជលើសាច់គេ បញ្ឈប់តាមរបៀបណា?

**ឆ៖** ខ្ញុំសូមជម្រាបដោយស្មោះត្រង់ថា រឿងដុតអីៗហ្នឹង ខ្ញុំមិនច្បាស់ទេណ៎ា ។ ខ្ញុំទុករឿងហ្នឹងដោយឡែក និយាយមួយម៉ាត់ទៀត ក៏ប៉ុន្តែរឿងដកក្រចក ខ្ញុំជឿថាគេបញ្ឈប់ក្រោយពីខ្ញុំបញ្ជាក់ម៉ឺងម៉ាត់ជាមួយ មិត្តហ៊ី ។ គ្រាន់តែខ្ញុំមិនបានដេញដោលរកអ្នកណា ដែលដកក្រចកហ្នឹងយកមកដាក់ទោស ពិតជាអត់បានដេញដោលមែន ។ នេះរឿងដកក្រចក ។ ក៏ប៉ុន្តែខ្ញុំជឿថាគេបញ្ឈប់ បើគេមិនបញ្ឈប់ទេថ្ងៃក្រោយតែបែកដល់ខ្ញុំ មិត្តហ៊ី ខ្លួនឯងហ្នឹងត្រូវមានទោសចំពោះមុខបក្សហើយ ខ្ញុំរាយការណ៍ណ៎ា ។ ឯចំណែក រឿងដុតបារីទៅលើក្រចកអីៗហ្នឹង ខ្ញុំជឿថា អាចមានខ្លះធ្វើៗ ជឿ ដោយ មិត្តហ៊ី ក៏មិនឃើញភ្លាត់ពេល ឬក៏គេមិនរាយការណ៍ឲ្យខ្ញុំ ក៏ភ្លាត់ពេល គេណែនាំ គ្នាគេស្ងាត់ៗ អាហ្នឹងមាន ខ្ញុំជឿ ។ នេះសូមបញ្ចប់ត្រឹមណេះ ។

**ស៖** សូមអរគុណ ។ លោក ឌុច លោកធ្លាប់មានប្រសាសន៍ ជូនលោកប្រធាន ឬក៏អង្គសវនាការអំពី (សុំទោស) ការដែលលោកថា មិនចង់ធ្វើការងារជាសន្តិបាល ឬនគរបាលទេ ពីមុនមក ដោយលោកចង់ធ្វើការនៅខាងឧស្សាហកម្ម ក៏ប៉ុន្តែដោយសារមេរបស់លោក ឬក៏ សុន សេន មិនអនុញ្ញាតទើបលោកបន្តការងារនេះទៀត ។ អ៊ីចឹងរបៀបនៃការឃុំឃាំង ឬក៏សួរចម្លើយអ្នកទោសនៅមន្ទីរស-២១ ក៏លោកមានប្រសាសន៍ថា មិនខុសគ្នាប៉ុន្មានពីមន្ទីរម-១៣ ។ ដូច្នេះការធ្វើទារុណកម្មទាក់ទងនឹងផ្លូវកាយដូចជាខ្ញុំបាទ និយាយអម្បាញ់មិញថា មានការវ៉ៃដំ ឬក៏ដកក្រចក ឬក៏អុជជាដើមទៅលើសាច់ ទៅលើខ្លួននោះបណ្តាលឲ្យឈឺចាប់ ។ នេះជាការធ្វើទារុណកម្មលើផ្លូវកាយ តាមការយល់របស់ខ្ញុំ ។ តើក្នុងការ

ឲ្យសំពះសត្វឆ្កែ ឬក៏ឲ្យអ្នកទោស យើងប្រើពាក្យថា ស៊ីលាមក ឬស៊ីអាចម៍នោះ ជាការធ្វើទារុណកម្មផ្លូវចិត្តដែរឬទេ?

**ឆ៖** ទារុណកម្មខាងផ្លូវកាយកំណត់បួនដូចខ្ញុំបានជម្រាបអ៊ីចឹង ។ ឯចំណែកទារុណកម្មខាងផ្លូវចិត្តរឿងស៊ីលាមកនេះ ជាបទល្មើសខាងទារុណកម្ម ដូចគ្នានឹងបទល្មើសផ្សេងទៀតដែរ មានដកក្រចកជាដើម ។ ឯចំណែក សំពះរូបឆ្កែ មុនដំបូងគេធ្វើមែន ។ ដល់ក្រោយមកខ្ញុំឃើញ ខ្ញុំអនុម័តទទួលយករបៀបទារុណកម្មនេះមួយទៀត ។ នេះជារឿងពិត។ ត្រង់ផ្លូវកាយ ឬត្រង់ផ្លូវចិត្ត អង្កាល់នោះខ្ញុំគិតថាវាធ្ងរដែរគ្នាវាមិនសូវត្រូវដំបង ។ ប៉ុន្តែ ដល់លោក គឹមសួន លោកមានប្រសាសន៍អ៊ីចឹង ខ្ញុំជឿថាអានេះទារុណកម្មខាងផ្លូវចិត្តហើយ ទទួលអារឿងសំពះរូបឆ្កែហ្នឹង មិនមែនគេសំពះម្តង ខ្ញុំដឹងហើយ ឲ្យឈប់ទេ ខ្ញុំឲ្យបន្ត ហ្នឹងសំពះរូបឆ្កែ ។

**ស៖** សូមអរគុណ ។ ចុះសំណួរទាក់ទងនឹងសំណួរនេះ ថាតើដែលការបន្តឲ្យធ្វើដូច្នេះតទៅទៀត លទ្ធផលដែលចង់បាន ឬក៏ដែលបានមកនោះ គាប់ប្រសើរដូចការសាកសួរ ឬធ្វើទារុណកម្មផ្លូវកាយដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ។ ខ្ញុំអត់មានបានសិក្សាប្រៀបធៀបបញ្ហានេះទេ ។

**ស៖** សូមអរគុណ ។ ទាក់ទងជាមួយនឹងការឆ្លើយជាមួយនឹងអង្គសវនាការ ឬលោកប្រធាន ពីសប្តាហ៍មុន នួន ជា បានប្រើថ្នាំសាកពិសោធ ឬក៏ឲ្យថ្នាំពុលតាមរយៈលោក សាកទៅលើជនរងគ្រោះ ឬអ្នកទោស ហើយលោកបានឆ្លើយថ្ងៃនេះក៏បានឆ្លើយដែរ ជាមួយនឹងសំណួរលោកព្រះរាជអាជ្ញាថា លោកបានប្តូរថ្នាំ*ប៉ារ៉ាសេតាម៉ុល* ចេញដោយដឹងតែម្នាក់ឯង គ្មានអ្នកណាដឹងក្រៅពីលោកទេ ។ សំណួរខ្ញុំសួរថា ដែលលោកប៊ានសម្រេចធ្វើបំពានបទបញ្ជា ឬការដាក់ទិសរបស់មេ ជាឆន្ទៈរបស់លោកអាណិតអាសូរ ឬក៏លោកគិតយ៉ាងម៉េចបានប៊ានធ្វើដូច្នេះ?

[១៤:៤៥:៥៩]

**ឆ៖** បញ្ហានេះ ខ្ញុំសូមបញ្ជាក់ឡើងវិញថា វាមានពីរបញ្ហារួមផ្សំគ្នា ។ បញ្ហាទីមួយ ថាបញ្ហាអាណិតអាសូរ វាមានកម្រិតណាមួយនៅក្នុងខ្លួនខ្ញុំហើយ តែបញ្ហាមួយទៀតដែលសំខាន់ គឺរឿងខ្ញុំដែលមិនលូកដៃទៅសម្លាប់ដោយផ្ទាល់ដៃទេ ដូចខ្ញុំបានជម្រាបបញ្ជាក់ជូនលោកចៅក្រម ឡានវែន៍ អ៊ីចឹង ខ្ញុំអត់លូកដៃទៅសម្លាប់មនុស្សដោយផ្ទាល់ដៃទេ ។ នេះជាបញ្ហាពីរហ្នឹងផ្គុំគ្នា ។

**ស៖** សូមអរគុណ ។ អ៊ីចឹងខ្ញុំចង់ភ្ជាប់នឹងសំណួរនេះបន្តិច ខ្ញុំសួរថា ពេល នួន ជា ឲ្យថ្នាំនោះមកលោក ថ្នាំប្រភេទជាថ្នាំ គ្រាប់ ថ្នាំទឹក ថ្នាំម្សៅ យើងហៅថា *កាប់ស៊ុល* នោះណា! តើប្រភេទថ្នាំយ៉ាងម៉េច? ហើយឲ្យនោះ គាត់នៅទីនោះចាំមើលដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ពូនួន គាត់មិនដែលចូលស-២១ទេ ។ ពូនួន ហៅខ្ញុំទៅធ្វើការនៅពុទ្ធិកវិទ្យាព្រះសុរាម្រិត ។ ថ្នាំហ្នឹងប្រភេទ *កាប់ស៊ុល* ថ្នាំដូចជា *ខ្លាក់ជ័រ* អ៊ីចឹង យើងដកចេញមកចាក់ម្សៅចោលទៅ ដាក់*ប៉ារ៉ាសេតាម៉ុល*ចូល ប្រភេទ *កាប់ស៊ុល* ។

**ស៖** អរគុណ ។ លោកអាចបញ្ជាក់បានទេថា នៅក្នុងខែណា ឬឆ្នាំណា ដែលលោកពិសោធ ឬក៏ដាក់ថ្នាំនោះ?

**ឆ៖** ខ្ញុំមិនចាំទេ ប៉ុន្តែខ្ញុំជឿថា ឯកសារអាចឲ្យតម្រុយយើងខ្លះ ។ ឯកសារដែលខ្ញុំដឹកនាំរៀនសូត្រហ្នឹង វាមានរយៈកាលមួយនោះ ខ្ញុំណែនាំក្នុងអង្គភាពថា វាមានរឿងលាក់អាវុធ វាមានអារឿងបំពុលថ្នាំដូច្នេះក្នុងរយៈកាលហ្នឹងៗ នេះខ្ញុំមិនចាំថ្ងៃខែទេ ។ នេះសូមបញ្ជាក់ជូនប៉ុណ្ណេះ ។

**ស៖** អរគុណ ។ សូមសួរទាក់ទងនឹងសំណួរនេះទៀតដែរ ថាតើថ្នាំដែលលោកឲ្យទៅគេអំមិញថា*កាប់ស៊ុល*ហ្នឹងជាសំបកខាងក្រៅ ។

ថ្នាំដែលលោកយកទៅបន្ថំ ឬប្តូររបស់ នួន ជា ចេញនោះ ជាឈ្មោះថ្នាំអ្វី ដែលភាសាពេទ្យនោះណា ថ្នាំពេទ្យផ្ទាល់ឈ្មោះអីដែលលោកប្តូរឲ្យនោះ?

[១៤:៤៨:៥៦]

**ឆ៖** ខ្ញុំសូមជម្រាបប្រសាសន៍លោក គីមសួន! ខ្ញុំអត់ដឹងថា អាថ្នាំហ្នឹងគេហៅឈ្មោះថ្នាំអីទេក៏ប៉ុន្តែខ្ញុំនៅចាំច្បាស់ *កាប់ស៊ុល* នោះមួយកំណាត់បៃតងចាស់ ហើយមួយកំណាត់ទៀតបៃតងខ្ចី ហើយបើក*កាប់ស៊ុល*នោះទៅ ឃើញម្សៅ ។ ក្នុងម្សៅហ្នឹង ដូចមានស្អីដើម ស្អីវល្លិ៍ ស្អីមួយតូចនៅហ្នឹង ។ ហ្នឹងខ្ញុំដកអាថ្នាំពិតប្រាកដគេចោលវិញ ពុលក៏ដោយ មិនពុលក៏ដោយ ខ្ញុំអត់និយាយទេ ខ្ញុំជូត*កាប់*ស៊ុលឲ្យស្អាត ខ្ញុំដាក់ម្សៅ*ប៉ារ៉ាសេតាម៉ុល*ទៅក្នុងហ្នឹង ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះប្រកាសសម្រាកដប់ប្រាំនាទី រហូតដល់ម៉ោងបីនិងប្រាំនាទី សូមអញ្ជើញចូលវិញហើយបន្តដេញដោលតទៀត ។

*[សវនាការសម្រាកពីម៉ោង ១៤:៥០ នាទី ដល់ម៉ោង ១៥:០៥នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ សូមជូនវេទិកានេះទៅលោកមេធាវី ហុង គីមសួន ហើយដោយសារមានការសុំដោយមេធាវីការពារក្តី អ៊ីចឹង លោក ហុង គីមសួន កុំអាលចាំស្តាប់មេធាវីការពារក្តីសិន ។ សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រ៉ូ ។

**លោក ហ្វ្រង់ស្វ័រ រ៉ូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំមិនមានបំណងធ្វើការអន្តរាគមន៍នៅក្នុងនេះទេ ប៉ុន្តែ ពេលដែលសម្រាកវាចំពេលមុននោះ ។ ប៉ុន្តែ ខ្ញុំមានការចាប់អារម្មណ៍ទៅលើលក្ខណៈនៃសំណួរដែលបានតាំងនៅពេលនេះ ។ ខ្ញុំជឿថា ចំណុចនេះវាជាចំណុចមួយដែលត្រូវបំភ្លឺជាថ្មីម្តងទៀត អំពីតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណី ។ ខ្ញុំមិនយល់ថា តើដើមបណ្តឹងរដ្ឋប្បវេណីមានភាពពាក់ព័ន្ធដោយផ្ទាល់ តាមរបៀបណាចំពោះបញ្ហាដែលលើកឡើងនៅពេលនេះ ។

ដោយសារតែជាការពិតទៅ នៅពេលដែលជនជាប់ចោទបានរារាំងនូវអ្វីដែលទាមទារពីខ្លួននោះ គឺអត់មានជនរងគ្រោះនៅក្នុងដំណាកកាលនោះទេ ។ សហព្រះរាជអាជ្ញា បានតាំងសំណួរអំពីអង្គហេតុទូទៅ ហើយដើមបណ្តឹងរដ្ឋប្បវេណីមានតួនាទីក្នុងការលើកឡើងអំពីការឈឺចាប់របស់ខ្លួន អ្វីដែលខ្លួនបានឆ្លងកាត់ ។ ភារកិច្ចរបស់ដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមែនធ្វើការចោទប្រកាន់ចំពោះជនជាប់ចោទនោះទេ ខ្ញុំបានឮពីខាងសហព្រះរាជអាជ្ញា ហើយនិងដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងអំពីភាពខុសគ្នារវាងតួនាទីរបស់ភាគីទាំងពីរ ។

ដូច្នេះ ខ្ញុំសូមជំរុញឲ្យដើមបណ្តឹងរដ្ឋប្បវេណីមិនធ្វើការបើកកកាយអំពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញាឡើងវិញនោះទេ ។ ដូច្នេះ ខ្ញុំសូមឲ្យ ជំរុញឲ្យដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងនូវអ្វីដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងជនរងគ្រោះ ហើយខ្ញុំជឿថា បញ្ហានេះដែលបានលើកឡើងដោយមេធាវីមួយក្នុងចំណោមមេធាវីដើមបណ្តឹងរដ្ឋប្បវេណីនោះ គឺវាមិនមែនជាតម្លៃមួយដែលជនរងគ្រោះចូលរួមក្នុងដំណើរការក្តីនោះទេ ដើម្បីបង្ហាញអំពីបញ្ហានិងសំណួរពីមេធាវី និងដើមបណ្តឹងរដ្ឋប្បវេណី ។ ប៉ុន្តែយ៉ាងណាក៏ដោយគឺមិនត្រូវធ្វើលើកឡើងអំពីតួនាទីដែលអនុវត្តដោយអង្គសវនាការ និងសហព្រះរាជ

អាជ្ញានោះទេ ។ ហើយខ្ញុំចង់ឲ្យតួនាទីដែលបានលើកឡើងបញ្ជាក់នៅក្នុងទីនេះ មានលក្ខណៈឲ្យបានធ្វើឡើងឲ្យបានច្បាស់លាស់ ។

[១៥:០៩:៤២]

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោកស្រី ស៊ីលឃីស្ទុត ហ្សីនស្តី៖**

លោកប្រធាន! ខ្ញុំចង់ស្នើសុំសេចក្តីណែនាំពីអង្គសវនាការក្នុងការអនុញ្ញាតឲ្យមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្នុងការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋាននឹងការលើកឡើងសំខាន់របស់មេធាវីការពារក្តីស្នើសុំឲ្យយើងលើកឡើងនៅពេលនេះ ឬក៏នៅពេលក្រោយ? ដើម្បីឲ្យអង្គសវនាការនោះធ្វើការសម្រេចទៅលើការអនុញ្ញាតឲ្យយើងលើកឡើង ដែលពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីក្នុងការតាំងសំណួរផ្សេងៗ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ ។

**លោក អាឡាំង វ៉ែនណឺ៖**

លោកចៅក្រមខ្ញុំនឹងលើកឡើងដោយសង្ខេប ។ ខ្ញុំមានការភ្ញាក់ផ្អើលចំពោះការលើកឡើងរបស់មេធាវីការពារក្តីយើងមានកិច្ចរៀបចំសវនាការកាលពីដប់ថ្ងៃមុន គឺជាពេលវេលាដែលយើងអាចលើកឡើងនៅពេលនោះ ហើយយើងៗមានវិធាន២៩.១ និង "ខ" ដែលយើងនឹងធ្វើការគាំទ្រទៅលើការចោទប្រកាន់ ហើយការកម្រិតនោះ គឺមិនសួរដដែលៗ ឬក៏សំណួរដែលវានៅក្រៅវង្វង់នៃអង្គហេតុ ។ ហើយមេធាវីការពារក្តីលើកឡើងថា យើងមិនសួរសំណួរដដែលនោះទេ យើងយល់ស្របទៅលើចំណុចនេះ ។ ហើយប្រសិនបើគាត់ជំទាស់ទៅលើអ្វីដែលអនុវត្តតាំងពីមុនមក ហើយយើងផ្តោតតែលើតួនាទីរបស់យើងនោះ យើងសូមលើកឡើងការលើកឡើងរបស់យើង ហើយវិធានរបស់យើងចែងយ៉ាងច្បាស់យើងមិនសួរសំណួរដដែលៗទេ ។ ហើយយើងសួរសំណួរនៅក្នុងរង្វង់នៃអង្គហេតុ ។ ដូច្នេះហើយយើងគួរតែត្រូវបានអនុញ្ញាតឲ្យសួរទាំងអស់នោះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ពាក់ព័ន្ធនឹងបញ្ហាលើកឡើងរបស់មេធាវីការពារក្តីទេ លោកមេធាវី ហុង គឹមសួន? រឿងមួយជាការប៉ុនប៉ងដើម្បីតាំងសំណួរ ឬក៏ពាក់ព័ន្ធជានឹងការលើកឡើងកត់សម្គាល់របស់មេធាវីការពារក្តី?

[១៥:១២:៣៣]

**លោក ហុង គីមសួន៖**

សូមអរគុណលោកប្រធាន ។ ដោយសារជាពេលវេលាខ្ញុំបាទត្រូវសាកសួរ ។ ខ្ញុំបាទគិតថា ខ្ញុំនឹងសួរក្នុងចម្លោះពេលវេលាដែលលោកប្រធានអនុញ្ញាតបន្តទៅទៀត ប្រសិនបើលោកប្រធានអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

មានពាក់ព័ន្ធទៅនឹង?

**លោក ហុង គីមសួន៖**

មិនតទល់ទេ ឥឡូវនេះបាទ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ហ្វ្រង់ស្វ័រ រូ ។

**លោក ហ្វ្រង់ស្វ័រ រូ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំគិតថា យើងកំពុងតែដោះស្រាយលើបញ្ហាដែលវាមានលក្ខណៈសំខាន់ខ្លាំងណាស់ ហើយខ្ញុំមិនមានបំណងក្នុងការកម្រិតតួនាទីដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ខ្ញុំព្យាយាមធ្វើយ៉ាងណាឲ្យអនុវត្តតួនាទីនោះក្នុងលក្ខណៈមួយមានប្រយោជន៍ ហើយខ្ញុំបានលើកឡើងហើយថាមិនមានបុគ្គលណានៅទីនេះគាត់ពេញចិត្តទាំងស្រុងនោះទេ ។ ប្រសិនបើ បន្ទាប់ពីចៅក្រមប្រាំរូបបានតាំងសំណួរជនជាប់ចោទហើយ ហើយបន្ទាប់មកសហព្រះរាជអាជ្ញាពីរនាក់គាត់បានតាំងសំណួរជនជាប់ចោទហើយនោះ ។

ហើយនៅចំពោះមុខយើង ប្រសិនបើយើងមានសហព្រះរាជអាជ្ញាប្អូនទៀតគាត់សួរសំណួរនោះគឺវាមិនមែនជាចំណុចមួយដែលយើងពេញចិត្តនោះទេ ។ គឺជាការជំនុំជម្រះដែលថា ជនជាប់ចោទទទួលការតាំងសំណួរពីសហព្រះរាជអាជ្ញាទាំងប្រាំមួយ ហើយអ៊ីចឹងយើងត្រូវរំឭកឡើងវិញថា តួនាទីរបស់យើងនីមួយៗយ៉ាងម៉េច? ចៅក្រមប្រាំរូបនៅក្នុងនេះ បានតាំងសំណួរទៅកាន់ជនជាប់ចោទទាំងលើភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក ហើយសហព្រះរាជអាជ្ញាបានតាំងសំណួរដាក់បន្ទុកដែលជាតួនាទីរបស់គាត់ ។

ដូច្នេះ ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់មិនមានតួនាទីអនុវត្តដូចគ្នាទៅនឹងតួនាទីរបស់សហព្រះរាជអាជ្ញានោះទេ ។ តួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីគឺមានលក្ខណៈខុសគ្នា ។

ខ្ញុំសូមបញ្ជាក់ការងារនឹងស្នាដៃរបស់ ហ្សាក វែកហ្សេស អំពីនីតិវិធីព្រហ្មទណ្ឌ ។ នេះគឺជានីតិវិធីនៅក្នុងទំព័រ៥៣៦ នៃសៀវភៅនេះ ក្នុងកថាខណ្ឌ៩៤៧ បានចែងថា ខ្ញុំសូមដកស្រង់នៅសម្តីនេះ នៅក្នុងនីតិវិធីចម្រុះនិងរបបច្បាប់ចំរុះរបស់យើងដែលមានលក្ខណៈតទល់គ្នា គឺវាអាស្រ័យទៅលើអង្គចៅក្រមក្នុងការអនុវត្តទៅលើនីតិវិធី ជនរងគ្រោះតាមលក្ខណៈជាក់ស្តែងគឺមិនមានតួនាទីច្រើនជាងតួនាទីបន្ទាប់បន្សំរបស់ខ្លួននោះទេ ។ ប៉ុន្តែ យ៉ាងណាក៏ដោយជនរងគ្រោះ គឺមិនត្រូវមានតួនាទីជាចម្បងនៅក្នុងនេះទេ" ។ សៀវភៅនេះក៏បាន ចែងឡើងផងដែរថា "ដើមបណ្តឹងរដ្ឋប្បវេណី គឺគាត់ការពារផលប្រយោជន៍និងតួនាទីរបស់ខ្លួនអំពីការរងគ្រោះនឹងការឈឺចាប់របស់ខ្លួនចំពោះព្យសនកម្មដែលខ្លួនទទួល ។ ប៉ុន្តែដើមបណ្តឹងរដ្ឋប្បវេណី គឺមិនមានតួនាទីធ្វើការចោទប្រកាន់នោះទេ" ។

[១៥:១៦:៣០]

នៅទីនេះយើងនៅក្នុងការតទល់គ្នានិងជជែកវែកញែក ដែលបង្ហាញដល់មេធាវីរបស់យើងគឺធ្វើយ៉ាងណាតាំងសំណួរទូទៅ ។ ដែលសំណួរទាំងអស់នោះ គឺវាមិនមែនពាក់ព័ន្ធផលប្រយោជន៍ផ្ទាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី នេះជាចំណុចចម្បងនៅទីនេះ ។

លោកប្រធាន លោក លោកស្រីចៅក្រមជាទីគោរព! ខ្ញុំសូមធ្វើការបំភ្លឺទៅលើចំណុចនេះ ដែលវាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងបញ្ហានៃការតាំងសំណួរដែលបានលើកឡើងដោយដើមបណ្តឹងរដ្ឋប្បវេណី នៅក្នុងសេចក្តីសន្និដ្ឋានរបស់ពួកគេទាក់ទងទៅនឹងការដាក់ទោស ។ ប្រសិនបើយើងត្រឡប់ទៅលើសៀវភៅប្រព័ន្ធច្បាប់ស៊ីវិលដែលទើបតែខ្ញុំដកស្រង់នៅក្នុងកថាខណ្ឌ៩១២ ខ្ញុំសូមលើកឡើងថា ខ្ញុំសូមដកស្រង់នូវសម្តី សូមស្តាប់ដោយត្រង់ត្រាប់ ។ វិធានជាក់ស្តែងនៃនីតិវិធីតទល់ គឺបានពន្យល់ហេតុអ្វីបានជាដើមរដ្ឋប្បវេណីគាត់ធ្វើតួនាទីរបស់ខ្លួន? គឺគាត់ធ្វើឡើងក្នុងតួនាទីនៃការដាក់ទោសនោះ គឺជាតួនាទីរបស់សហព្រះរាជអាជ្ញា ។ ហើយតួនាទីដាក់ទោសនេះមិនមែនតួនាទីរបស់ដើមបណ្តឹងរដ្ឋប្បវេណីនោះទេ ។ ចំណុចនេះគឺជាការលើកឡើងនៅក្នុងអត្ថបទ ហើយលោកលោកស្រីអាចធ្វើការពិនិត្យនៅក្នុងចំណុចយោងទៅលើមូលដ្ឋានផ្លូវច្បាប់ផ្សេងៗ ដែលវាមានការគាំទ្រទៅលើការចោទប្រកាន់របស់សហព្រះរាជអាជ្ញា ដែលបង្ហាញអំពីពិរុទ្ធភាព ។ ហើយពិរុទ្ធភាពនោះគឺវាក៏ទាក់ទងទៅនឹងការឈឺចាប់របស់ជនរងគ្រោះ ។

[១៥:១៨:៥០]

ជាថ្មីម្តងទៀត គឺយើងត្រូវតែគោរពទៅតាមតួនាទីរបស់យើងរៀងៗខ្លួននិងលក្ខខណ្ឌផ្សេងដើម្បីអនុញ្ញាតឲ្យអង្គជំនុំជម្រះរបស់យើងអនុវត្តដោយរលូនហើយគោរពទៅលើសិទ្ធិរបស់ជនជាប់ចោទ ។

ហើយវាគឺវិធានដែលយើងមាន ហើយប្រសិនបើយើងគោរពតាមតួនាទីនីមួយៗរបស់យើងៗស្ថិតនៅក្នុងជំហររបស់យើងក្នុងការគោរពតួនាទីនេះ ដើម្បីធ្វើយ៉ាងណាអនុវត្តការជំនុំជម្រះរបស់យើងឲ្យបានដំណើរការដោយរលូន ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី ហុង គឹមសួន ។ អញ្ជើញលោកមេធាវី ហុង គឹមសួន ។

**លោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន ។ អំមិញនេះ ខ្ញុំបាទថាមិនមានអ្វីនឹងចង់អូសបន្លាយពេលវេលានាំខាតពេលទេ ព្រោះយើងទាំងអស់គ្នាបានទទួលការណែនាំនិងការសម្រេចពីអង្គជំនុំជម្រះទាំងការមិនឲ្យសួរច្រំដែលនេះមួយ ទាំងការប្រើមិនឲ្យលើសពេលវេលានៃការកំណត់នេះពីរ ។ អ៊ីចឹង ខាងយើងខ្ញុំគឺដឹងច្បាស់ហើយថា ការគោរពសិទ្ធិដល់ជនជាប់ចោទ គឺជាសិទ្ធិដែលច្បាប់ដែលទទួលស្គាល់ ឬក៏ឲ្យចែងទៅក្នុងច្បាប់ ។ ប៉ុន្តែ សិទ្ធិរបស់ជនរងគ្រោះក្នុងរបបវាលពិឃាត ដែលសព្វថ្ងៃតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ក៏វិធានផ្ទៃក្នុងនៃអង្គជំនុំជម្រះវិសាមញ្ញាបានចែងថា មេធាវីរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណីជាភាគីមួយ។ ដូច្នេះ នៅក្នុងអង្គជំនុំជម្រះនេះភាគីមានបី ។ ភាគីសហព្រះរាជអាជ្ញា ភាគីជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ ភាគីដើមដើមបណ្តឹងរដ្ឋប្បវេណី។ ដូច្នេះ នៅក្នុងច្បាប់ ឬវិធានផ្ទៃក្នុងនេះបានឲ្យសិទ្ធិ ឲ្យអំណាច មកភាគីដើមបណ្តឹងរដ្ឋប្បវេណីបានដែលមានមេធាវីជាតំណាងហើយដែរ ។ ដូច្នេះ ត្រង់ចំណុចទាំងអស់នេះ ខ្ញុំបាទមិនមើលឃើញថាមានកំណត់មិនឲ្យមេធាវីរដ្ឋប្ប-វេណីសាកសួរ ដែលលោកប្រធានបានសម្រេចហើយនោះទេ ។ ដូច្នេះ យើងចៀសវាងការសួរសំណួរច្រំដែលតែប៉ុណ្ណោះ ។

បើសិនជាលោកមេធាវីការពារចង់ឲ្យយើងនិយាយពីភាពឈឺចាប់ ឬការទាមទារសំណងតែមួយមុខនោះ ។ អ៊ីចឹងសួរថា ជនរងគ្រោះដែលដើមបណ្តឹងរដ្ឋប្បវេណីរាប់រយនាក់ទាំងអស់នោះ យើងនឹងលើកយកមកនិយាយម្តងមួយៗបង្ហាញភាពឈឺចាប់ មិនមែនតែមួយ ឬពីរម៉ោងនោះទេ ។ នេះគឺជាការអូសបន្លាយពេលកាន់តែច្រើនទៅទៀត ។ យើងធ្វើការប្រជុំរៀបចំបច្ចេកទេសដើម្បីកាត់បន្ថយការចោទប្រកាន់ពីមតិដែលមិនយល់ពីនីតិវិធីនេះឲ្យសមស្របហើយនិងឲ្យបានលឿន ។ ហេតុនេះ ខ្ញុំបាទយល់ឃើញថាសិទ្ធិរបស់ជនរងគ្រោះជាដើមបណ្តឹងរដ្ឋប្បវេណី ក៏ជាសិទ្ធិមួយច្បាប់ឲ្យតម្លៃ និងគោរពផងដែរ មិនមែនមានតែជនជាប់ចោទមួយនោះទេ ។ ហើយដែលលោកអំពីលោក ហ្សាក វែកហ្សេស មកជា

គំរូនៅក្នុងពេលនេះ លោក ហ្សាក វែកហ្សេស គឺជាមេធាវីរបស់ជនត្រូវនៅ *អ៊ីស៊ីស៊ីស៊ី* នេះដែរ ។ ដូច្នេះ យើងមិនអាចទទួលយកបានទេ ។ យើងគោរពតែច្បាប់ដែល *អ៊ីស៊ីស៊ីស៊ី* បង្កើតឡើង និងនីតិវិធីឲ្យយើងធ្វើតាមតែប៉ុណ្ណោះ ។ ទីបី វិធានផ្ទៃក្នុងមាត្រាទីម្ភៃ-- វិធានទី២៣ គឺបានឲ្យតម្លៃនិងសិទ្ធិមកលើដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏ជនរងគ្រោះដើមបណ្ដឹងរដ្ឋប្បវេណីតាមផ្លូវច្បាប់និងសិទ្ធិចែងរួចរាល់អស់ហើយ ។ ដូច្នេះអ្វីដែលខ្ញុំបាទគោរព គឺគោរពហើយសិទ្ធិរបស់ជនត្រូវចោទ ក៏លោកមេធាវីត្រូវគោរពដល់សិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីជាជនរងគ្រោះផងដែរ ។ ហើយខ្ញុំបាទក៏សូមឲ្យលោកប្រធានសម្រេចពេលនេះតែម្ដងថា យើងជាភាគីមួយមានសិទ្ធិ កុំឲ្យតែបំពានសិទ្ធិ ឬកុំឲ្យបំពានច្បាប់តែប៉ុណ្ណោះនៅពេលនេះ ។ សូមអរគុណ ។

[១៥:២៣:៥៤]

**ប្រធានអង្គជំនុំ៖**

បានស្ដាប់មតិកត់សម្គាល់របស់មេធាវី ហ្វ្រង់ស្វ័រ រូ ដែលជាមេធាវីការពារក្ដីជនជាប់ចោទ បានស្ដាប់មតិលើកឡើងតបទៅនឹងការកត់សម្គាល់របស់មេធាវីការពារក្ដី ដោយមេធាវីតំណាងឲ្យដើមបណ្ដឹងរដ្ឋប្បវេណី បានពិនិត្យនូវវិធាន២៣.១ ដែលចែងអំពីគោរពបំណងនៃបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ គឺដើម្បីក៏ចូលរួមក្នុងដំណើរការនីតិវិធីព្រហ្មទណ្ឌប្រឆាំងនឹងអ្នកដែលទទួលខុសត្រូវចំពោះបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់អង្គជំនុំជម្រះវិសាមញ្ញ ដោយគាំទ្រដល់ការចោទប្រកាន់ ហេតុដូច្នេះអង្គជំនុំជម្រះអនុញ្ញាតឲ្យធ្វើការដេញដោលសួរពាក់ព័ន្ធជាមួយនឹងសំណួរផ្សេងដែលមានការប៉ុនប៉ងដោយក្នុងន័យគាំទ្រដល់បទចោទប្រកាន់ ។ អង្គជំនុំជម្រះគ្រាន់តែរំលឹកដល់មេធាវីការពារក្ដីជ្រាបថា ទីមួយគឺរំឭកឡើងវិញចៀសវាងនូវការតាំងសំណួរច្រំដែលក្នុងករណីសំណួរណាមួយដែលអង្គជំនុំជម្រះ ឬក៏សហព្រះរាជអាជ្ញាបានសួររួចហើយ ហើយមិនច្បាស់កន្លែងណាដោយហៅសួរបញ្ជាក់ទៀតមិនបាច់រំឭកពីដើមកំណើតនៃសំណួរនោះទេ សួរតែម្ដងទៅថាអ្វីដែលសេសសល់ជាមែកធាងដែលចង់ច្បាស់នោះ ។

ទីពីរ គឺចៀសវាងក្នុងការតាំងសំណួរវែងរហូតដល់ជនជាប់ចោទពិបាកនឹងយល់ម្ដងហើយម្ដងទៀត អង្គជំនុំជម្រះដូចជារំឭកច្រើនដងហើយ ។ ទីបី សូមរំឭកឡើងវិញ ចៀសវាងក្នុងការតាំងសំណួរក្រៅអង្គហេតុដែលបានលើកមកដេញដោលនេះ ។ អង្គហេតុដេញដោលគឺប្រតិបត្តិការស-២១ ជើងឯកហើយមានអង្គហេតុតូចៗ មានការចាប់ខ្លួន ការបញ្ជូនខ្លួន ការឃុំឃាំង ទារុណកម្ម សួរចម្លើយហើយ

និងកម្ទេច ឬក៏សម្លាប់ ។ សម្លាប់មាននៅក្នុង ស-២១ មាននៅតំបន់ជុំវិញស-២១ ហើយនិងជើងឯក ។ នេះគឺអង្គជំនុំជម្រះបានកក្តាប់ហើយជម្រាបភាគីម្តងហើយម្តងទៀត ប៉ុន្តែ នៅក្នុងការដេញដោលនៅតែមានបញ្ហា ទោះបីយើងបានរំឭកហើយក៏ដោយ ។ ឥឡូវនេះ យើងរំឭកម្តងទៀត គឺសូមឲ្យការជជែកដេញដោលគឺចៀសវាងឲ្យផុតពីអ្វីដែលយើងបានលើកឡើងនេះ ។ អញ្ជើញលោកមេធាវី ហុង គឹមសួន បន្តសំណួរ មិញលោកនៅសល់ម្ភៃប្រាំប្រាំមីនុតទៀតនេះ អ៊ីចឹង រហូតដល់ម៉ោងបួនខ្វះប្រាំនាទី ។ សូមអញ្ជើញ ។

[១៥:២៦:៤២]

**សួរដោយលោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកប្រធាន ។ ខ្ញុំបាទសូមបន្តសំណួររបស់ខ្ញុំបាទអម្បាញ់មិញ មុនពេលសម្រាកខ្ញុំបានសួរលោក កាំង ហ្គេកអ៊ាវ ហៅ ឌុច ទាក់ទងជាមួយនឹងការសាកល្បងប្រើថ្នាំដែល នួន ជា បានឲ្យទៅលោកសាកទៅលើអ្នកទោសនៅមន្ទីរស-២១ ។ សំណួរខ្ញុំសួរតទៅទៀតថា តើនៅពេលនោះ មិញលោកឆ្លើយថាអត់ដឹងពេលវេលាជាក់លាក់ទេ ខ្ញុំគ្រាន់តែសួរថា ពេលដែលលោកទទួលថ្នាំពី នួន ជា មកនោះ តើលោកដឹងទេថាថ្នាំនោះជាថ្នាំយកមកពីណា? ឬទាក់ទងនឹងថ្នាំដែលបំពុល ប៉ុល ពត ដែរឬទេ?

**ឆ៖** ថ្នាំនេះយកពីទីណាខ្ញុំអត់ដឹងទេ ។ ថ្នាំនេះទាក់ទងនឹងថ្នាំបំពុល បងប៉ុល ដែរឬអត់? ខ្ញុំក៏មិនដឹង ។ តែ ពូនួន គាត់អាចសង្ស័យ តាមចម្លើយសារភាព នេះខ្ញុំសូមឆ្លើយប៉ុណ្ណេះ ។

**ស៖** សូមអរគុណ ។ ខ្ញុំសួរទាក់ទងមកការសម្លាប់ផងដែរ លោកបានឆ្លើយជាមួយអង្គសវនាការអំពីការសម្លាប់ ឬកម្ទេចជនបរទេសដែលនៅក្នុងមន្ទីរស-២១ នោះ ខ្ញុំមិនចាំឈ្មោះទេ ពីរសប្តាហ៍មុនបានឆ្លើយហើយ ។ តើមុននឹងយកទៅកម្ទេច ឬយកទៅសម្លាប់លោកបានដឹងទេថា ការសម្លាប់ហើយទើបដុតកម្ទេចចោល ឬចងជនរងគ្រោះទាំងរស់ហើយដុត?

**ប្រធានអង្គជំនុំ៖**

សំណួរនេះមិនបាច់ឆ្លើយទេ ព្រោះអង្គជំនុំជម្រះបានសួររួចហើយទាំងពីរបញ្ហានេះ ។ លោកមេធាវីអាចសួរសំណួរផ្សេង សំណួរនេះច្រំដែល ។

**លោក ហុង គឹមសួន៖**

**ស៖** សូមអរគុណលោកប្រធាន ។ សំណួរមួយទៀតទាក់ទងជាមួយនឹង លោកបានឆ្លើយទាក់ទងជាមួយនៅពីសប្តាហ៍មុនៗទៀតអំពីការដឹកឈ្លើយសឹក ឬអ្នកទោសតាមរថយន្តមកឈប់នៅច្រកចូលដែលលោកបាននិយាយថា សព្វថ្ងៃនៅម្តុំវិទ្យុ១០៥ ឬវិទ្យុសំបុកឃ្មុំ ។ នេះទាក់ទងជាមួយនឹងការប្រើប្រាស់វិទ្យុទាក់ទងជាមួយលោក ជាមួយនឹងមេរបស់លោក ។ តើការបញ្ជូនមនុស្ស ឬអ្នកទោសមកឈប់នៅចំណុចវិទ្យុ១០៥ ឬវិទ្យុសំបុកឃ្មុំនេះជាមណ្ឌលទាក់ទងទៅមជ្ឈដ្ឋាននៃស-២១ ឬគ្រាន់តែបញ្ជូនសារពីចំណុចដាក់អ្នកទោសមកឲ្យលោក?

[១៥:៣០:២០]

**ឆ៖** ស-២១គ្មានសិទ្ធិទាក់ទងទៅអង្គភាពណាតាមអាកាសទេ។ តេអូនៅហ្នឹងកន្លែងដែលខ្ញុំដាក់ថាអក្សរ “R” ដែលឥឡូវនេះគេទៅជាវិទ្យុសំបុត្រឃ្មុំស្អីគេនោះ មានតេអូមួយគ្រឿងមែនសម្រាប់ទាក់ទងពីស-២១ ទៅស្រែ ។ ដូច្នេះ ពីស-២១ភ្នំពេញ ទៅស-២១ព្រៃស ។ ឯចំណែក កន្លែងដែលខ្ញុំសរសេរអក្សរ “R” នេះជាកន្លែងសម្រាប់ទទួលអ្នកទោសដែលអង្គភាពផ្សេងទៀតដែលគេយកមកឲ្យ ។ គេយកមកយប់ថ្មើណាក៏ដោយ ក៏កន្លែងអក្សរ “R” នេះមានមនុស្សចាំទទួល ។ ប៉ុន្មានៗមេឲ្យដំណឹងមកខ្ញុំមុនខ្ញុំអ្នកប្រាប់ឲ្យគេនៅរង់ចាំទទួល ដូច្នេះសូមបញ្ជាក់ខ្លីប៉ុណ្ណោះ ទីមួយអាអក្សរ “R” នេះវាគ្មានសិទ្ធិទាក់ទងទៅក្នុងអង្គភាពណាតាមអាកាសទេ ។

**ស៖** សូមអរគុណ។ បន្តទៅទៀត ទាក់ទងជាមួយនឹងអ្នកទោសបញ្ចូលទៅមន្ទីរស-២១ ដដែលសំណួរខ្ញុំសួរថា អ្នកទោសដែលដឹកមកដល់ស-២១ ឬបញ្ចូលទៅដល់ក្នុងបរិវេណនៃ-- បរិវេណដែលលោកហៅថា បរិវេណនៃវិទ្យាល័យពញាយ៉ាត បើយើងនិយាយពីស-២១ វាធំពេក ។ អ៊ីចឹងមួយផ្នែកនៃវិទ្យាល័យពញាយ៉ាតនេះ អ្នកទោសមកដល់ពេលព្រលប់ តើឲ្យម្ហូបអាហារអ្នកទាំងអស់នោះហូបដែរ ឬទេ?

**ឆ៖** ខ្ញុំមិនច្បាស់ទេៗ ។

**ស៖** សូមអរគុណ ។ ទាក់ទងជាមួយនឹងការបង្រៀននៅក្នុងប្រតិចារឹកពីសប្តាហ៍មុនលោកបានជម្រាបអង្គសវនាការអំពីរបៀបបច្ចេកទេសនៃការសួរចម្លើយ ។ អ៊ីចឹង ខ្ញុំមិនចង់សួរលម្អិតឡើងវិញទេគ្រាន់ថា បច្ចេកទេសនៃការសួរចម្លើយទាំងអស់នោះ រួមបញ្ចូលជាមួយផ្នែកសួរចម្លើយត្រជាក់ ក្តៅ

អង្កៀម តើបច្ចេកទេសនោះនិងបច្ចេកទេសពួកអ្នកទោសលោកហៅពិសេសនោះ លោកបង្រៀនដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំបង្រៀនបច្ចេកទេសសួរចម្លើយសុទ្ធសាធនៅដើមៗនៃដំណាក់កាលដែលខ្ញុំចូលកាន់កាប់ស-២១ គឺនៅពេលដែលខ្ញុំធ្វើអនុប្រធាន ។ ក្រោយមក ដែលខ្ញុំបង្រៀនជាប់លាប់គឺខ្ញុំបង្រៀនអំពីសភាពការណ៍ វាចោទស្អីខ្លាំង? ត្រូវសួរត្រង់ណា? ទិសដៅរកស្អី? កំណត់នៅក្នុងសៀវភៅដែលខ្ញុំបានជម្រាបលោកពីថ្ងៃមុនលោកអាចមើលឃើញ ។

**ស៖** សូមអរគុណ ។ ទាក់ទងនឹងចម្លើយសារភាពមកវិញ មិញពីមុននេះខ្ញុំបានសួរលោកទាក់ទងជាមួយនឹងសំណួរទណ្ឌកម្មខាងផ្លូវចិត្ត ហើយលោកក៏បានធ្លាប់មានប្រសាសន៍ហើយថា ទាំងផ្លូវកាយផ្លូវចិត្តលោកតែងតែថា មិនមែនជាការពិតមួយរយភាគរយនោះទេ ។ គឺវាមិនពិតលើសពីហាសិបភាគរយទៅហើយ ។

ដូច្នេះ ក្នុងការសួរយកចម្លើយទីមួយ ឧទាហរណ៍ បើជនម្នាក់ឆ្លើយ ឬអ្នកទោសឆ្លើយទម្លាក់ឈ្មោះអ្នកដទៃគឺលោកបញ្ជូនរបាយការណ៍សារភាពទៅខាងលើដើម្បីសម្រេច ។ អ៊ីចឹង ដែលលោកមានប្រសាសន៍ថា ចម្លើយនោះលោកមិនជឿទាំងស្រុងទេ ។ តើការឆ្លើយទម្លាក់ដល់ឈ្មោះដទៃទៀតហើយត្រូវបានថ្នាក់លើ ឬខាងណាផ្សេងទៀតនោះចាប់មក ។ អ៊ីចឹងការសួរចម្លើយអ្នកក្រោយបន្តទៅទៀតនេះលោកនៅតែគិតថាមិនពិតទាំងស្រុងទៀតដែរឬទេ?

[១៥:៣៥:០០]

**ឆ៖** រឿងនៅតែគិតថាចម្លើយនោះមិនពិត ។ នៅតែគិតៗ ។ តែមិនដឹងធ្វើម៉េច គោលការណ៍អីក៏ដោយឲ្យតែបក្សគេចាត់មកហើយ យើងត្រូវតែសួរឲ្យចេញ ។ ចេញក៏ដោយមិនចេញ ក៏ដោយត្រូវតែដាក់គុក ហើយនិងយកទៅកម្ទេចឲ្យគេ ។ ដោះលែងមិនបាន ។ នេះជារឿងពិត ។

**ស៖** សូមអរគុណ ។ ទាក់ទងនឹងសំណួរនេះដដែល ក្នុងអារម្មណ៍របស់លោកគិតថាវាមិនពិតទៅហើយ តែថាគេចមិនផុត ឬគេចមិនរួច ។ ប៉ុន្តែ លោកបានពិនិត្យចម្លើយសារភាពមុនហ្នឹងបញ្ជូនទៅឲ្យមេ ឬថ្នាក់លើ។ តើលោកធ្វើបានរបៀបបញ្ជូនកុមារមួយផ្នែកដូចជា កុមារមួយផ្នែកទៅមន្ទីរព្រៃស ដូច្នេះ តើខុសគ្នាយ៉ាងម៉េចដែលលោកអាចបំបែកកុមារទៅនៅព្រៃសបាន ហើយចំពោះមនុស្សពេញវ័យ លោកបំបែកទៅនៅព្រៃសមិនបាន?

**ឆ៖** កុមារយើងស្រួលគ្រប់គ្រងមិនឱ្យគេរត់ជាង ឯចំណែកមនុស្សពេញវ័យច្បាប់ហាមឃាត់អ្ហេ! មិនមែនយើងនិយាយច្បាប់ហ្នឹងខុសហើយ ។ គោលការណ៍របស់បក្សកុម្មុយនីស្តកម្ពុជាហាមឃាត់ដាច់ខាតគ្មានច្រេចច្រូចទេ។ ចាប់មកហើយត្រូវតែដាក់ខ្នោះវាយសួរចម្លើយ។ ដូច្នេះ គ្មានមនោសញ្ចេតនាទេណ៎ា ។ នេះគោលការណ៍ដែលបក្សគេកំណត់មកឱ្យស-២១ ក៏ដូចជាខ្ញុំជឿថាមន្ទីរនគរបាលទូទាំងប្រទេសគឺអ៊ីចឹង ។ សូមបញ្ជាក់ប៉ុណ្ណេះ។

**ស៖** សូមអរគុណ។ សំណួរចុងក្រោយគឺខ្ញុំសួរទាក់ទងជាមួយនឹងអ្នកទោសនៅក្នុងមន្ទីរស-២១ដែរ បើលោកចាំបានលោកគ្រាន់ឆ្លើយទៅចុះ ព្រោះនេះគ្រាន់តែចង់សួរថាដោយសារមានក្នុងនេះឈ្មោះលោក ។ លោកស្គាល់អ្នកទោសដែលជាវិស្វករមកពីប្រទេសសូវៀត ឈ្មោះ ជា ខន ហៅ ជិន ដែលជាមិត្តភក្តិលោក?

**ឆ៖** ជា ខន ហៅ ជិន រៀននៅជាមួយខ្ញុំថ្នាក់ទីបញ្ចប់ ហើយគាត់ទៅដល់នុ៎ង ។ ហើយខ្ញុំសូមជម្រាបលោកដោយត្រង់ណ៎ា មិត្តភក្តិទៅច្រើនណាស់ ខ្ញុំអត់ប៉ានទៅជួបទេ ព្រោះទៅជួបមិនដឹងនិយាយពាក្យថាម៉េច? តើយើងត្រូវជេរគេ ឬយើងត្រូវធានាខ្លួនជួយដោះស្រាយ? អត់ប៉ាន១ ទៅជួបអត់ប៉ានទៅឃើញមុខ។ យូរ១ទៅអ្នកណាចូលប៉ុន្មាននាក់ក៏ខ្ញុំអត់ដឹង ។ ជា ខន ពិតជាស្គាល់ ។ និយាយពេលណាខ្ញុំឃើញមាឌគាត់ធំនៅមុខខ្ញុំ ។ នេះខ្ញុំស្គាល់។

[១៥:៣៨:១៥]

**លោក ហុង គីមសួន៖**

សូមអរគុណ។ សូមអរគុណ លោកប្រធាន ខ្ញុំអស់សំណួរត្រឹមនេះ ។

**ប្រធានអង្គជំនុំ៖**

ជាបន្តសូមប្រគល់វេទិកានេះជូនទៅមេធាវីក្រុមបី តំណាងក្រុមបី បើមានសំណួរសូមអញ្ជើញ។

**សួរដោយកញ្ញា ម៉ុច សុវណ្ណារី៖**

**ស៖** ជាដំបូងនាងខ្ញុំសូមគោរពដល់លោកប្រធាននិងអង្គជំនុំជម្រះសាលាដំបូង ។ ហើយសូមអរគុណដែលបានផ្តល់ឱកាសឱ្យក្រុមយើងខ្ញុំសួរនូវសំណួរមួយចំនួនទៅដល់ជនជាប់ចោទ ។ មុននឹងចាប់ផ្តើមសំណួរជាបន្តបន្ទាប់នេះ នាងខ្ញុំសុំឱ្យជនជាប់ចោទធ្វើការបញ្ជាក់បន្តិចទាក់ទងជាមួយនឹងភាពមិនស៊ីចង្វាក់គ្នានៃចម្លើយដែលគាត់បានឆ្លើយកាលពីសវនាការថ្ងៃទី១៦ ខែ៦ ហ្នឹង ។ ប្រសិនបើយើងក្រឡេកមើលនៅក្នុងប្រតិចារឹកនៃសវនាការនៅក្នុងជាភាសាអង់គ្លេស យើងមើលនៅក្នុងទំព័រទី២៤ ហើយនៅ

ក្នុងបន្ទាត់ទី១២ ទាក់ទងជាមួយនឹងសំណួរដែលលោកប្រធានបានសួរ ទាក់ទងជាមួយនឹងការបង្រៀនអំពីបច្ចេកទេសនៃការសួរចម្លើយ។ ពេលនោះលោកបានឆ្លើយថា បន្ទាប់ពីលោកបានបង្រៀន ហើយលោកបានចុះទៅធ្វើការត្រួតពិនិត្យនៅពេលដែលអ្នកសួរចម្លើយ គេសួរចម្លើយដល់អ្នកទោស ។ ក៏ប៉ុន្តែប្រសិនបើយើងក្រឡេកមើលប្រតិចារឹកដដែលហ្នឹង នៅថ្ងៃដដែលហ្នឹង នៅក្នុងទំព័រទី៣៩ នៅបន្ទាត់ទី១២ លោកបានអះអាងថា លោកមិនដែលបានចូលទៅដល់កន្លែងសួរចម្លើយទេ ហើយលោក ក៏មិនដែលសួរចម្លើយដោយផ្ទាល់ដែរ លើកលែងតែករណីសំខាន់ប៉ុន្មានដែលលោកបានរៀបរាប់កន្លងមក។ អ៊ីចឹងតើលោកអាចបញ្ជាក់បានទេ ពីភាពហាក់ដូចជាមិនស៊ីសង្វាក់នៃចម្លើយទាំងពីររបស់លោកហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី ខ្ញុំឮដូចកញ្ញាមានប្រសាសន៍អំមិញថា ប្រតិចារឹកភាសាអង់គ្លេស តើមែនទេ? ខ្ញុំឮកញ្ញាមានប្រសាសន៍អំមិញថា កញ្ញាប្រើប្រតិចារឹកជាភាសាអង់គ្លេស មែនទេ?

**ស៖** ចា៎!

**ឆ៖** ចុះម៉េចក៏កញ្ញាមិនប្រើប្រតិចារឹកជាភាសាខ្មែរ?

**ស៖** ដោយសារវាពិបាកនៅក្នុងការរកបន្តិច ហើយនាងខ្ញុំរកបន្ទាន់ អ៊ីចឹងបានជាខ្ញុំប្រើប្រតិ-ចារឹកជាភាសាអង់គ្លេស ។

**ឆ៖** អរគុណ ខ្ញុំក្តាប់មិនបានទេណា ដូច្នេះចាំមើលខ្ញុំផ្ទៀងផ្ទាត់ប្រតិចារឹកហ្នឹងថ្ងៃណា មានពេលទំនេរសឹមខ្ញុំឆ្លើយ។ ខ្ញុំនឹកមិនឃើញថាវាខ្វែងគ្នា ចម្លើយខ្ញុំទាំងពីរលើកនេះ ។ នឹកមិនឃើញសុំអត់ទោស ។

**ស៖** អរគុណចំពោះចំណាប់អារម្មណ៍របស់លោក។ នាងខ្ញុំមានសំណួរមួយទៀត ទាក់ទងជាមួយនឹងទម្រង់នៃការធ្វើទារុណកម្ម ប្រភេទនៃទារុណកម្មដែលបានប្រើនៅមន្ទីរស-២១។ តើលោកធ្លាប់បានដឹងទេថា អ្នកសួរចម្លើយគាត់ធ្លាប់ប្រើបារីដែលគាត់ជក់ហើយវាឆេះ ហើយគាត់បានយកបារីហ្នឹងទៅអុជនៅលើមុខមាត់ ឬក៏នៅលើរូបរាងកាយអ្នកទោសដែលគាត់កំពុងសួរចម្លើយហ្នឹង ។ តើលោកមានដឹងអំពីការអនុវត្តន៍នេះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ព្រឹកមិញខ្ញុំឆ្លើយសំណួរនេះហើយ ប៉ុនឥឡូវខ្ញុំបញ្ជាក់ថា ខ្ញុំអត់បាន ណែនាំឲ្យអនុវត្តទារុណកម្មនេះទេ តែខ្ញុំជឿថាវាកើតមាន។ ខ្ញុំសូមឆ្លើយឡើងវិញប៉ុណ្ណឹង ។

**ស៖** អរគុណសម្រាប់ចម្លើយរបស់លោក ។ សំណួរជាបន្ទាប់មកទៀត កាលពីសវនាការ ថ្ងៃទី ១៦ ខែមិថុនា ហ្នឹង លោកបានរំឭកឡើងអំពីឈ្មោះជនរងគ្រោះពីររូបគឺឈ្មោះរបស់លោក សួន កាសេត ហើយនិងឈ្មោះរបស់លោកស្រី ជូឡុង វាំងស៊ី ។ ពេលនោះលោកបានឆ្លើយ លោកបានអះអាងថា ពួកគាត់បានឆ្លើយសារភាពដោយសារមានអំពើទារុណកម្ម ។ អ៊ីចឹងធ្វើឲ្យខ្ញុំចាប់អារម្មណ៍ឃើញថា លោកប្រហែលជាដឹងរឿងរបស់ពួកគាត់ចាំរឿងរបស់គាត់ច្រើន។ ដូច្នេះ បើសិនជាលោកអាចចាំបាន តើលោកអាចប្រាប់អង្គសវនាការបន្តិចបានទេថា តើពួកគាត់ត្រូវបានសម្លាប់ដោយរបៀបណា ហើយនៅកន្លែងណា? នៅជើងឯក ឬក៏នៅក្នុងបរិវេណនៃមន្ទីរស-២១?

**ឆ៖** ខ្ញុំមើលទៅទាំងពីរនាក់ហ្នឹងប្រហែលជានៅឯតាខ្មៅឯណោះ ប្រហែលជានៅគុកតាខ្មៅឯណោះ ឬក៏អាចនៅស-២១ ក៏ថា បានដែរ ។

**ស៖** អរគុណច្រើនសម្រាប់ការបញ្ជាក់របស់លោក ។ នាងខ្ញុំមានសំណួរមួយទៀត តើលោកអាចប្រាប់បានទេថា តើមានការអនុវត្តនៅក្នុងការបញ្ជូនអ្នកទោសពីមន្ទីរស-២១ ទៅព្រៃស ដែរឬទេ? តើមានករណីហ្នឹងដែរទេ?

[១៥:៤៣:១៨]

**ឆ៖** គ្មានទេ។ ហើយខ្ញុំសូមបញ្ជាក់ឡើងវិញចម្លើយខ្ញុំអំមិញហ្នឹងណ៎ា អំពីរឿង សួន កាសេត ហើយនិងម៉ាដាម ជូឡុង វាំងស៊ី ខ្ញុំនិយាយតាមការសន្និដ្ឋានពេលវេលាដែលគាត់មិនដល់ហ្នឹង មិនច្បាស់ទេ សូមនិយាយប៉ុណ្ណឹង ។

**ស៖** អរគុណច្រើន ។ សំណួរមួយទៀត សូមអរគុណលោកជនជាប់ចោទដែលលោកបានមានសេចក្តីក្លាហាននៅក្នុងការជម្រាបដល់អង្គសវនាការអំពីការសម្រេចចិត្តមួយរបស់លោក ដែលលោកសម្រេចចិត្តក្នុងការប្រឆាំងបញ្ជារបស់បងធំទីពីរនៃកម្ពុជាប្រជាធិបតេយ្យទាក់ទងជាមួយនឹងរឿងពិសោធថ្នាំ ។ អរគុណដែលលោកបានប្រកាសការណ៍នេះដល់ពិភពលោកទាំងមូល ។ នាងខ្ញុំមានសំណួរអ៊ីចេះចង់សួរអំពីចិត្តរបស់លោកផ្ទាល់ ឧទាហរណ៍ថា អ្នកដែលទទួលបញ្ជានៅក្នុងការប្រតិបត្តិ ការពិសោធន៍ថ្នាំហ្នឹង មិនមែនលោកទេ គឺជាជននៅក្រោមបង្គាប់ណាម្នាក់របស់លោក ហើយពេលនោះគាត់បានសម្រេចចិត្តធ្វើដូចជាលោកអ៊ីចឹង ដោយមូលហេតុពីរយ៉ាងសាមញ្ញបំផុតដែលមនុស្សជាទូទៅ គាត់អាចគិតដល់ ។ ទីមួយគឺគាត់អាណិតអាសូរដល់ជនរងគ្រោះហ្នឹង។ ទីពីរគឺ គាត់ការពារដៃរបស់គាត់ មិនឲ្យប្រលាក់ឈាម ។ គាត់បានសម្រេចចិត្តធ្វើដូចជាលោកអ៊ីចឹង ។ ហើយនៅពេលហ្នឹងលោកបានដឹងពីការ

ដែលមិនស្តាប់បង្គាប់ពីថ្នាក់លើហ្នឹង របស់ថ្នាក់លើហ្នឹង អ៊ីចឹងក្នុងនាមលោកជាប្រធាននៃមន្ទីរស-២១ តើលោកនឹងមានវិធានការយ៉ាងណាចំពោះបុគ្គលិកដែលប្រឆាំងជាមួយនឹងបញ្ជាថ្នាក់លើបែបនេះ?

**ឆ៖** នេះជាសេចក្តីសន្និដ្ឋានរបស់កញ្ញា ដែលបារាំងគេហៅថា *សាប់ប៉ូស៊ីស្យុង* នោះ ខ្ញុំឆ្លើយមិនរួចទេ ចំពោះសំណួរ *សាប់ប៉ូហ្សេ* អ៊ីចឹង ។

**ស៖** អរគុណលោកដែលបានប្រាប់តាមត្រង់ថា លោកមិនអាចឆ្លើយនឹងសំណួរនេះបាន។ អ៊ីចឹងតើយើងអាចជាការត្រឹមត្រូវទេ ដែលយើងនិយាយថា ដើម្បីការពារប្រយោជន៍របស់លោក ឬក៏អាយុជីវិតរបស់លោក គឺលោកអាចមានជម្រើសមួយ ហើយលោកអាចនឹងធ្វើការសម្រេចចិត្តដ៏មោះមុតមួយថាប្រឆាំងនឹងបញ្ជាថ្នាក់លើរបស់លោក។ តើការនិយាយបែបនេះ ជាការត្រឹមត្រូវដែរទេ?

[១៥:៤៥:៥២]

**ឆ៖** យើងប៊ានធ្វើលុះត្រាតែយើងធានាក្នុងចិត្តថា វាស្ងាត់មិនបែកការ មិនគ្រោះថ្នាក់ដល់ជីវិតនេះបានយើងប៊ានធ្វើ។ ក្នុងករណីនេះគត់ ។

**ស៖** អរគុណលោកសម្រាប់ការបញ្ជាក់នេះ ។ មានសំណួរមួយទៀត ខ្ញុំសូមត្រឡប់ទៅជនរងគ្រោះពីរនាក់ដែលខ្ញុំបានសួរលោកពីមុនហ្នឹងបន្តិចហ្នឹង ទាក់ទងជាមួយនឹងជនរងគ្រោះ ឈ្មោះ សួន កាសេត ហើយនិង ជូឡុង វាំងស៊ី ហ្នឹង ។ នៅក្នុងគំនិតរបស់លោក តើលោកគិតថា គាត់ត្រូវបានចាត់ទុក ថាជាអ្នកទោសសំខាន់ ឬក៏ជាអ្នកទោសធម្មតាម្នាក់តែប៉ុណ្ណោះ?

**ឆ៖** លោក សួន កាសេត ហើយនិង អ្នកស្រី ជូឡុង វាំងស៊ី ជាអ្នកទោសសាមញ្ញ គឺជាអ្នករាជការ ចាស់ៗ ។

**ស៖** នាងខ្ញុំសូមអរគុណសម្រាប់ចម្លើយរបស់លោក ។ នាងខ្ញុំមានសំណួរចុងក្រោយមួយទៀតដើម្បីសួរលោក តើលោកមានចាំឈ្មោះអ្នកទោសម្នាក់នៅស-២១ គាត់ឈ្មោះលោក អ៊ុក កេត ដែលគាត់ជាអតីតនៅខាងក្រសួងការបរទេស ។ លោកនៅចាំបានទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! ខ្ញុំចាំមិនបានទេ ក៏ប៉ុន្តែខ្ញុំបានអានបណ្តឹងរដ្ឋប្បវេណីរបស់ម៉ាដាម អ៊ុក កេត ស្ទី *ឡឺហ្វេរ* នោះ ខ្ញុំបានអានៗហើយ ។

**ស៖** ខ្ញុំនឹងមានសំណួរទាក់ទងជាមួយនឹងរូបជនរងគ្រោះម្នាក់នេះ តើខ្ញុំចង់សួរជនជាប់ចោទថាតើលោកចង់ឲ្យមានការបង្ហាញឯកសារហ្នឹងដោយលោក ឬក៏លោកគិតថាអាចឆ្លើយបានដោយមិនចាំ

បាច់បង្ហាញឯកសារទេ ទាក់ទងជាមួយនឹងបញ្ជីឈ្មោះអ្នកទោសដែលត្រូវកម្ទេចដែលនៅក្នុងហ្នឹងមាន បង្ហាញឈ្មោះរបស់ជនរងគ្រោះម្នាក់នេះដែរ ខ្ញុំគិតថា លោកបានអានហើយ ។

**ឆ៖** បើអានឯកសារខ្ញុំបានអាន ក៏ប៉ុន្តែខ្ញុំអាចភ្លេចៗ ។

**ស៖** អរគុណលោក ។ ខ្ញុំមកនេះ ខ្ញុំបាននាំនូវបំណងប្រាថ្នាមួយរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលគាត់ជាសាច់ញាតិរបស់ជនរងគ្រោះឈ្មោះ អ៊ុក កេត នេះ ។ លោក អ៊ុក កេត ត្រូវបានចាប់ខ្លួនទៅ ដាក់នៅមន្ទីរស-២១ នៅថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៧៧ ហើយនៅក្នុងបញ្ជីឈ្មោះអ្នកទោសគាត់ត្រូវបាន សម្រេចបញ្ជូនទៅកម្ទេចនៅថ្ងៃទី៩ ខែធ្នូ ឆ្នាំ១៩៧៧ ។ ដើម្បីឆ្លើយតបនឹងបំណងប្រាថ្នារបស់ដើម បណ្តឹងរដ្ឋប្បវេណីរូបនេះ ដែលគាត់បានព្យាយាមស្វែងរកអំពីដំណឹងសាច់ញាតិរបស់គាត់ ហើយគាត់ ស្វែងរកអំពីមូលហេតុ អំពីហេតុការណ៍ដែលកើតឡើងចំពោះជនរងគ្រោះម្នាក់នេះ ។ ដើម្បីឆ្លើយតបនឹង បំណងប្រាថ្នានេះ តើលោកអាចរៀបរាប់ប្រាប់អង្គសវនាការទាំងមូលបានទេថា ហេតុអ្វីបានជាអំឡុង ពេលនៃការឃុំខ្លួនទៅលើរូបគាត់ហ្នឹងវាមានរយៈពេលយូរ រហូតដល់ប្រហែលជាប្រាំមួយខែបែបនេះ ពីព្រោះ បើសិនជាតាមដែលខ្ញុំចាំបាន លោកថាទាក់ទងជាមួយនឹងអ្នកទោសដែលសំខាន់គេអាចឃុំខ្លួន អ្នកទោសទាំងអស់នោះរហូតដល់រាប់ខែ អាចប្រាំ-ប្រាំមួយខែអ៊ីចឹង ។ អ៊ីចឹងខ្ញុំចង់សួរថា តើមូលហេតុ អ្វីលោកអាចជម្រាបបានទេ តើដោយសារតែជនរងគ្រោះម្នាក់ហ្នឹងគាត់គឺជាអ្នកទោសដែលសំខាន់ ឬ ក៏ដោយសារ មានមូលហេតុអ្វីដែលនៅពីក្រោយហ្នឹងដោយឡែកមួយទៀត?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! រឿងច្រើនណាស់ ខ្ញុំចាំមិនអស់ទេ ប្រសិនបើកញ្ញាចង់ឲ្យខ្ញុំ ពន្យល់ អំពីករណី អ៊ុក កេត ខ្ញុំសូមកញ្ញាផ្តល់នេះមក សេចក្តីសារភាពរបស់ អ៊ុក កេត មកឲ្យខ្ញុំសិន ហើយដល់ ពេលណាជួបដើមបណ្តឹងរដ្ឋប្បវេណី សឹមខ្ញុំឆ្លើយបញ្ជាក់ជូនគេថែមទៀត ។

[១៥:៥០:០៥]

**កញ្ញា ម៉ុច សុវណ្ណារី៖**

អរគុណ ចំពោះសន្តានចិត្តរបស់លោក តែគួរឲ្យស្តាយណាស់ឯកសារទាំងអស់នោះត្រូវបាន បំផ្លាញ ហើយយើងមិនអាចរកឃើញពីចម្លើយសារភាពទេ ។

អរគុណ លោកប្រធាន នាងខ្ញុំអស់សំណួរដើម្បីសួរហើយ ។ ហើយនាងខ្ញុំសង្កេតឃើញថាមាន ពេលវេលាមួយចំនួន ដែលនៅសល់ពីក្រុមរបស់នាងខ្ញុំ អ៊ីចឹងនាងខ្ញុំសូមអនុញ្ញាតដល់លោកប្រធានដើម្បី

នឹងផ្ទេរពេលវេលាដែលនៅសល់នេះ ជាប្រយោជន៍ដល់មេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រោយទៀត ដែលគាត់មានសំណួរដើម្បីនឹងសួរ ។ នាងខ្ញុំសូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តទៅនេះសូមអញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ។ អញ្ជើញមេធាវីតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណីក្រុមពីរ ។

**លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី៖**

សូមអភ័យទោសលោកប្រធាន ។ យើងយល់ស្របថា ប្រសិនបើអត់លោកចៅក្រមអត់ជំទាស់ គឺយើងអាចបន្តទៀតបាន ។

**ប្រធានអង្គជំនុំ៖**

បានសេចក្តីថា លោកស្រីមិនត្រូវ មិនអត់គ្មានមានសំណួរ ឬយ៉ាងម៉េច?

លោកស្រីបង្ហាញជូនអង្គជំនុំជម្រះឲ្យបានច្បាស់លាស់ថា លោកស្រីគ្មានសំណួរ ឬក៏យ៉ាងម៉េច? មិនមែនលោកស្រីស្រេចតែចិត្តលោកស្រីនោះទេ ។ នេះគឺតាមលំហូរនៃនីតិវិធីពីក្រុមបួន មកក្រុមបី មកក្រុមពីរ ហើយចុងក្រោយគឺក្រុមមួយ លក្ខណៈវិលជុំដូច្នេះ ។ បើច្បាស់លាស់ថាគ្មាន គឺបញ្ជាក់ពីភាពថាគ្មាន បើសុំគឺសុំឲ្យបានច្បាស់លាស់ មិនមែនស្រេចលើលោកស្រី ជាអ្នកកំណត់នូវការដំណាក់កាល ឬក៏លំដាប់នៃការដេញដោលនោះទេ ។ យើងជាប្រធានអង្គជំនុំជម្រះ ជាអ្នកកំណត់អំពីបញ្ហានេះ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្សីនស្គី៖**

**ស៖** អរគុណលោកប្រធាន។ ខ្ញុំនឹងចាប់ផ្តើមតាំងសំណួរ ប៉ុន្តែខ្ញុំយល់ថាគឺវាទៅតាមដើមបណ្តឹងរដ្ឋប្បវេណីថា តើយើងចែកពេលវេលាយ៉ាងម៉េច? ហើយខ្ញុំនឹងធ្វើការចាប់ផ្តើមការតាំងសំណួររបស់ខ្ញុំតាមការបង្គាប់របស់លោកប្រធាន ។

ជាបឋមសំណួររបស់ខ្ញុំ គឺសុំការបំភ្លឺយោងតាមប្រតិចារឹក នៅចាប់ពីថ្ងៃទី១៧ ខែមិថុនានៅក្នុងទំព័រទី៣៧ ជួរទី១៣ គឺយើងមានការលើកឡើងអំពីអ្នកទោសបរទេស គឺរូបភាពទាក់ទងទៅនឹងអ្នកទោសបរទេស ហើយនៅក្នុងទំព័រទី៣៦ ជួរ២១ នៅថ្ងៃដដែលនោះ នៅក្នុងប្រតិចារឹកលោកនិយាយថាមិនមានការថតរូបនោះទេ ថាលោកអាចបំភ្លឺដែរឬទេ? ថាវាជាបញ្ហានៃការបកប្រែ តែមានការលើកឡើងខុសគ្នា រវាងសក្ខីកម្មទាំងពីរនេះ?

[១៥:៥៤:០៩]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! មេធាវី ខ្ញុំសុំនិយាយអំពីជនបស្ចិមប្រទេសបួនរូប ខ្ញុំជឿថាកញ្ញាចាប់អារម្មណ៍បញ្ហានេះជាងគេ ។ ជនបស្ចិមប្រទេសបួនរូបនេះ មិនមានថតរូបដូចពួក វន វេត ទេ ក៏ប៉ុន្តែសាកសពរបស់គេត្រូវដុតឲ្យទាល់តែខ្ទេច នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណេះ ។

**ស៖** ខ្ញុំយល់ថា គឺមិនមានការថតរូបទៅលើអ្នកទាំងអស់នោះទេ នេះជាអ្វីដែលលោកលើកឡើងចំពោះអ្នកទោសបរទេសបស្ចិមបួននាក់នោះ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំសូមបញ្ជាក់ម្តងទៀតថា មនុស្សដែលគេទារឲ្យថតរូបក្រោយដែលសម្លាប់ហើយនេះ គឺមានតែពួកខ្មែរទេ ដែលគេទារថតរូបហើយ-- អ៎! សម្លាប់ហើយថតយកទៅបង្ហាញខាងលើៗ ក្រៅពីនោះគ្មានទេ ។

**ស៖** ខ្ញុំនឹងបន្តការតាំងសំណួររបស់ខ្ញុំ ថាតើមានការថតរូបដែរឬទេ? តាមអ្វីដែលខ្ញុំយល់កាលពីប៉ុន្មានថ្ងៃមុន គឺវាមិនមានការស្នើសុំពីអ្នកសាមញ្ញ ប៉ុន្តែ បុគ្គលិកគឺគាត់ធ្វើការថតរូប ដើម្បីបង្ហាញថា ដើម្បីបង្ហាញទៅដល់ថ្នាក់លើ ថាតើបុគ្គលនោះត្រូវបានស្លាប់ ឬក៏មិនទាន់បានស្លាប់? ហើយតាមអ្វីដែលខ្ញុំយល់ លោកបានលើកឡើងផងដែរ មានការថតរូបដោយមិនមានការស្នើសុំនោះទេ ប៉ុន្តែ មានការថតរូបទៅលើបុគ្គលដែលស្លាប់នៅស-២១ តើលោកអាចបញ្ជាក់បំភ្លឺនេះជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** ខ្ញុំសុំបញ្ជាក់ថា រឿងថតរូបអ្នកស្លាប់ហើយនៅមន្ទីរស-២១ ដែលអនុប្រធានខ្ញុំគេបញ្ជាឲ្យថត មានមែន ។ ពីអង្កាល់ជំនាន់នោះ ខ្ញុំអត់ដឹង ខ្ញុំឃើញ ខ្ញុំដឹង នៅពេលចៅក្រមស៊ើបអង្កេត គាត់នាំខ្ញុំទៅបង្ហាញដល់ទីកន្លែង ហើយគាត់សួរបុគ្គលិកស-២១ អានេះរូបនេះ ស្លាប់ពីល្ងាច ព្រឹកឡើងគេថតទុកអ៊ីចឹងជាភស្តុតាងថាស្លាប់ នឹងខ្ញុំឃើញរូបថតមួយហ្នឹង ហើយដែលចៅក្រមស៊ើបអង្កេត គាត់សួរច្បាស់នៅនឹងភ្នែកខ្ញុំ នេះជារឿងពិត ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹង ។

**ស៖** តើលោកបានដឹងដែរឬទេថា អ្នកទោសដែលបាននាំទៅជើងឯកនោះ ត្រូវបានគេថតរូបនៅទីនោះ ដើម្បីបង្ហាញថា ប្រសិនបើមានការស្នើសុំ នោះថាពួកគេត្រូវបានសម្លាប់ ឬក៏មិនទាន់បានសម្លាប់នៅជើងឯក?

**ឆ៖** នៅជើងឯកខ្ញុំគ្មានបញ្ជាឲ្យថតរូបទេ គ្មានទាល់តែសោះ ហើយក៏មិនដែលឃើញរូបថតណារហូតមកដល់ទាល់ថ្ងៃនេះពីការសម្លាប់នៅជើងឯកមានថតរូប ។

[១៥:៥៩:២៨]

**ស៖** ខ្ញុំសូមត្រឡប់ទៅលើអ្នកទោសបស្ចិមបួនរូប ដែលត្រូវបានដុតឲ្យសុសនៅស-២១ ។លោកបានប្រកាសនឹងលើកឡើងជាក់លាក់ថា វាបញ្ជារបស់ នួន ជា ដូច្នេះតើលោកអាចជម្រាបយើងខ្ញុំដែរឬទេថាតើលោកបញ្ជាមួយណាទៅដល់បុគ្គលិករបស់លោក ចំពោះអ្នកទាំងបួននោះ តាមអ្វីដែលខ្ញុំយល់នោះ គឺនួន ជា មិនបាននិយាយអំពីការដុតឲ្យសុសនោះទេ? ប៉ុន្តែគាត់និយាយថា ឆ្អឹងរបស់ពួកនោះគឺមិនសំខាន់ទេ ។

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំសុំមិនធ្វើអត្ថាធិប្បាយទេ ខ្ញុំសុំរក្សាសិទ្ធិនៅស្ងៀម ។

**ស៖** អ៊ីចឹង ខ្ញុំនឹងព្យាយាមសួរលោកសួរនូវសំណួរនេះ ។ តើលោកចេញបញ្ជាផ្ទាល់ដើម្បីឲ្យបុគ្គលិករបស់លោកធ្វើការដុតសាកសពអ្នកទាំងនោះឬ?

**ឆ៖** ខ្ញុំសុំរក្សាសិទ្ធិនៅស្ងៀម ។

**ប្រធានអង្គជំនុំ៖**

នាងមេធាវីតសំណួរទៀត ពីព្រោះសំណួររបស់មេធាវីច្រំដដែល និងសំណួរដែលអង្គជំនុំជម្រះបានសួររួចហើយ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទួតហ្វ៊ីនស្គី៖**

**ស៖** លោកបានជម្រាបដល់អង្គសវនាការថា ការសម្លាប់នោះ គឺជាសម្ងាត់ ហើយមិនមាននរណាដែលត្រូវឲ្យដឹងអំពីការសម្លាប់នោះទេ? តែមានសាក្សីដែលបានរាយការណ៍ថា ជនបរទេសនោះឯងត្រូវបានគេដុតទាំងរស់ ។ ថាតើហេតុអ្វីទៅ ដែលអាចមានសាក្សីដែលបានសង្កត់ សង្កេតមើលឃើញទៅថា ពួកគេហ្នឹងឯងត្រូវបានគេដុតទាំងរស់នោះ? ហើយពីព្រោះអីលោកនិយាយថា ការសម្លាប់នេះគឺត្រូវបានធ្វើឡើងជាសម្ងាត់ ។

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! រឿងសាក្សីគេសង្កេតឃើញយ៉ាងម៉េច អាហ្នឹងកញ្ញាពិនិត្យមើលទៅទៀតចុះ ។ ពិនិត្យមើលគេនុំងទៅ ម៉េចបានគេសង្កេតឃើញ ។ ខ្ញុំមិនដឹងទេ ។

[១៦:០៣:២៧]

**ស៖** ឥឡូវនេះ ខ្ញុំនិយាយអំពីប្រធានបទមួយផ្សេងទៀត ។ តើលោកនៅចាំទេ នៅពេលដែលប្រធានពេទ្យនៅស-២១ ត្រូវបានចាប់ខ្លួននោះ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ប្រធានពេទ្យនៅស-២១ ពីរនាក់ ។ មុនដំបូង មិត្តអឿ ត្រូវចាប់ខ្លួនឡើង មិត្តទ្រី ដល់ក្រោយមកមិត្តទ្រី ត្រូវចាប់ខ្លួនទៀត ហើយអ្នកក្រោយទៀត ខ្ញុំមិនដឹងប្រធានពេទ្យអ្នកណាទេ ។ ខ្ញុំសូមជម្រាបអ៊ីចឹង ។

**ស៖** ខ្ញុំចង់សួរអំពីមិត្តទ្រី តើលោកនៅចាំទេថា មិត្តទ្រី ហ្នឹងត្រូវបានចាប់ខ្លួននៅពេលណា?

**ឆ៖** អឺយ! ជម្រាបប្រសាសន៍កញ្ញាណំា យកឯកសារមកស្រួលជាង ខ្ញុំអត់ចាំទេ មនុស្សជាងមួយម៉ឺននាក់ ឲ្យខ្ញុំចេះតែចាំម៉េច ។ សូម្បីតែបង ង៉ែត យូ ហៅហុង នោះ ខ្ញុំដឹងថ្ងៃខែ ខ្ញុំចាំម្ដង ឥឡូវភ្លេចទៅទៀតហើយ រួចខ្ញុំចាំច្បាស់តែបង វន វ៉េត ប៉ុណ្ណឹង ។

[១៦:០៥:00]

**ស៖** តើលោកមានចាំទេថា គាត់ត្រូវបានគេដាក់នៅមន្ទីរឃុំឃាំងនៅ ស-២១ ដែរ?

**ឆ៖** បុគ្គលិករបស់មន្ទីរស-២១ ក៏ដោយ សូម្បីតែអតីតប្រធានមន្ទីរស-២១ ក៏ត្រូវទៅជាប់នៅស-២១ ហ្នឹងដែរ ព្រោះអចិន្ត្រៃយ៍វាសម្រេចស-២១ ដាក់ពួកនុ៎ង ។

**ស៖** តើលោកចាំទេថា ប្រធានមន្ទីរពេទ្យ៩៨ ឈ្មោះ សួន ណាត ហៅ តៃ នៅពេលដែលគាត់ចាប់នោះ តើគាត់ត្រូវបានចាប់ខ្លួននៅពេលណា?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញាមេធាវី! មិត្តតៃ នេះខ្ញុំស្គាល់ ។ ចាប់ខ្លួនមិនដឹងឆ្នាំណាទេ ដូចជម្រាបអ៊ីចឹងគ្នាច្រើនណាស់ ។ មើលឯកសារទៅ ។

**ស៖** តើលោកនៅចាំទេ តើនរណាគេជាមេរបស់គាត់? ជាប្រធានរបស់គាត់?

**ឆ៖** ប្រធានមន្ទីរពេទ្យ៩៨ នេះ មេរបស់គេ គឺលោកគ្រូ សុន សេន ។

**ស៖** តើលោកមានបានដឹងទេថា គាត់ត្រូវបានគេបញ្ជូនទៅស-២១?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! អ្នកណាក៏ដោយ ចាប់តាំងពីថ្ងៃដែលខ្ញុំឡើងធ្វើប្រធាន បញ្ជូនទៅស-២១ សុទ្ធតែត្រូវឆ្លងតាមខ្ញុំទាំងអស់ ។ ខ្ញុំសុទ្ធតែត្រូវដឹង ក៏ប៉ុន្តែ ខ្ញុំភ្លេចអស់ហើយ ។

**ស៖** លោកបាននិយាយថា លោកបានទាក់ទងជាមួយគាត់ ប៉ុន្តែក្រោយមក គឺថា មានន័យថាទំនាក់ទងជាមួយគាត់ហ្នឹង គឺជិតស្និទ្ធ ។ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំ និងមិត្តតៃ ស្គាល់គ្នាតាំងពីឆ្នាំ១៩៧០ អង្កាល់ដែលខ្ញុំនៅតំបន់២៥ នៅស្អាងកោះធំ ។ ជិតស្និទ្ធមែន ។

**ស៖** តើលោកមានបានជួបគាត់ទេ នៅអំឡុងពេលដែលលោកជាប្រធាន ស-២១ នោះ?

**ឆ៖** ខ្ញុំនឹកមិនឃើញទេ បើជួប ក៏ជួបក្រៅផ្លូវការ ។

**ស៖** តើលោកមានបានពិភាក្សាជាមួយគាត់ ឬតាមរយៈ សុន សេន នូវតម្រូវការរបស់អង្គភាព ៩៨ ហើយដែលថា ស-២១ នេះអាចចូលរួមចំណែកបាន?

**ឆ៖** រឿងនោះ ខ្ញុំគិតថា កញ្ញានិយាយអំពីរឿងឈាម មែនទេ?

**ស៖** គឺមិនកម្រិតត្រឹមតែឈាមទេ ប៉ុន្តែ គឺទាក់ទងទៅនឹងកិច្ចការទាំងអស់ដែលមានទំនាក់ទំនងរវាងអង្គភាព៩៨ ហើយនិងស-២១?

[១៦:១០:១២]

**ឆ៖** រឿងឈាម មេបញ្ជាមកឲ្យស-២១ ផ្តល់ឲ្យ៩៨ ។ ៩៨ ត្រូវតែធ្វើ-- សូមទោស ស-២១ ត្រូវតែធ្វើ ។ ខាង ស-២១ នេះ អ្នកចាត់ចែងបូមឈាម ពេទ្យទ្រី ហើយយកឈាមហ្នឹង ទៅភ្លាមៗជូនដល់មិត្តតៃ ។ នេះរឿងដែលខ្ញុំនៅចាំ នេះខ្ញុំសូមសង្ខេបប៉ុណ្ណេះ អំពីរឿងឈាម ។

**ស៖** តើអង្គភាព៩៨ គឺជាមន្ទីរពេទ្យតែមួយដែលត្រូវការឈាមសម្រាប់ឲ្យយុទ្ធជន ឬមួយក៏មានតម្រូវការដើម្បីបណ្តុះបណ្តាលសិស្សក្នុងការសិក្សាអំពីកាយវិភាគ?

**ឆ៖** សំណួរនេះពីរ ត្រូវនិយាយពីរដាច់ដោយឡែកពីគ្នា ។ អង្គភាព ព-៩៨ ជាអង្គភាពរបស់សេនាធិការ វាស្ថិតនៅក្រោមមេតែមួយជាមួយគ្នានឹងស-២១ ។ ដូច្នេះ មេភ្ជង់ផ្តើមអង្គភាពរបស់គាត់ហើយភ្ជង់ផ្តើមអង្គភាពអ្នកផ្សេងទៀតទេ នេះបញ្ហាមួយ ។ មួយទៀតបញ្ហារៀនកាយវិភាគ នេះជាសេចក្តីសម្រេចរបស់ ណាត ប្រហែលជាមេអនុញ្ញាត ។ មិនមែនប្រហែលទេ តាមការសន្និដ្ឋានរបស់ខ្ញុំមេអនុញ្ញាត នេះជាកិច្ចរបស់ស-២១ តែឯង ។

**ស៖** លោកបានជម្រាបដល់អង្គសវនាការថា ការអនុវត្តនៃការបូមឈាមហ្នឹង ត្រូវបានឈប់បន្ទាប់ពីប្រធានពេទ្យតៃ ឈ្មោះតៃ ហ្នឹង ត្រូវបានចាប់ខ្លួន ហើយលោកក៏មិនបន្តការអនុវត្តការបូមឈាមនេះ ជាមួយនឹងប្រធានពេទ្យថ្មីដែរ ។ សំណួររបស់ខ្ញុំ តើអ្វីដែលខ្ញុំលើកឡើងហ្នឹង ត្រឹមត្រូវដែរឬទេ?

**ឆ៖** ត្រឹមត្រូវហើយៗ ។

**ស៖** ហើយសំណួររបស់ខ្ញុំហ្នឹងគឺថា តើមេរបស់លោក សុន សេន បានចេញបញ្ជាឲ្យផ្តល់ជំនួយ ឬក៏ការគាំទ្រដល់អង្គភាព៩៨ នោះដែរឬទេ ? ឬក៏គាត់បានដកបញ្ជានោះចេញវិញ ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ។ ខ្ញុំមិនឮខាងប្រធានព-៩៨ ថ្មីគេទារ ហើយមេខ្ញុំក៏មិនឮតេអ្វ--តេពីអ្នកលឿងមកបញ្ជាឲ្យខ្ញុំផ្តល់ឈាមឲ្យដែរទៀតទេ ។ នេះ ហេតុផលពីរនេះដែលខ្ញុំនៅចាំថាការផ្គត់ផ្គង់ឈាមទៅដល់៩៨ វាចប់ត្រឹមនុ៎ង ។

**ស៖** តើគណៈ ស-២១ ត្រូវបានជូនដំណឹងអំពីការបូមឈាមដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ខ្ញុំសូមរក្សាសិទ្ធិមិននិយាយ-- រក្សាសិទ្ធិនៅស្ងៀម ។

**ស៖** សំណួរបន្ទាប់នេះ ដើម្បីធ្វើការសូមបញ្ជាក់ឲ្យបានច្បាស់តែប៉ុណ្ណោះ អាចជាបញ្ហានៃការបកប្រែ ។ តើការបូមឈាមនោះធ្វើនៅឯណា? នៅស-២១ ឬក៏នៅមន្ទីរ-- នៅអង្គភាព៩៨? ពីព្រោះអីនៅក្នុងប្រតិចារឹកនៅក្នុងភាសាអង់គ្លេស គឺថាឈាមហ្នឹង គឺថាអ្នកទោសត្រូវបានគេបញ្ជូនទៅពេទ្យ៩៨នោះ ។

[១៦:១៥:៤៧]

**ឆ៖** ខ្ញុំសូមនិយាយបែបនេះបន្តិចទៅចុះ ដឹកមនុស្សរស់យកទៅ៩៨ ទៅបូមឯ៩៨ វាធ្ងន់ណាស់ ។ បើឈាមប្រាំលីត្រ គិតថាប្រាំមួយគីឡូទៅចុះ វាស្រាលជាង ។ នេះខ្ញុំសូមនិយាយទៅមួយបែបទៀត ដើម្បីបញ្ជាក់ថា ឈាមនេះ គឺនៅស-២១ យកទៅឈាមទទេមនុស្សនៅស-២១ ឯណោះ ។

**ស៖** សូមអរគុណ ។ ទាក់ទងទៅនឹងការវះកាត់ និងការសិក្សាកាយវិភាគ តើការសិក្សាហ្នឹងធ្វើការសិក្សាអំពីកាយវិភាគហ្នឹង ធ្វើឡើងនៅ ស-២១ ឬ?

**ឆ៖** បាទ ។

**ស៖** តើមានការរៀបចំជាពិសេសឬ ដែលបន្ទប់ និងទីកន្លែងត្រូវបានរៀបចំសម្រាប់ការសិក្សាកាយវិភាគនោះ?

**ឆ៖** ខ្ញុំអត់ដឹងទេ អត់បានទៅអើតមើលទេ ។

**ស៖** តើលោកមិនបានទទួលព័ត៌មានអំពីដំណើរនេះដែរឬទេ ទោះបីជាលោកមិនបានទៅឃើញដោយផ្ទាល់ក្តី?

**ឆ៖** ខ្ញុំអត់បានទទួលព័ត៌មានទេ ។

**ស៖** តើគណៈ ស-២១ ត្រូវបានជូនដំណឹងអំពីការសិក្សាលើកាយវិភាគនេះដែរឬទេ?

**ឆ៖** ខ្ញុំមិនដឹងទេ ។ ខ្ញុំអ្នកនយោបាយធ្វើម៉េចកុំឲ្យតែវាខុសនយោបាយរបស់បក្សទៅបានហើយ ឯចំណែកកាយវិភាគយ៉ាងម៉េច អីយ៉ាងម៉េចខ្ញុំអត់បានគិតទេ វិជ្ជាពេទ្យផ្សេងគ្នា ។

**ស៖** តើលោកមានបានដឹងទេថា អ្នកទោសប៉ុន្មាននាក់ ត្រូវបានគេប្រើសម្រាប់ការពិសោធបែបនេះ?

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា ខ្ញុំអត់ដឹងទេ ។ ខ្ញុំដឹងតែប្រពន្ធ ចាច់ ជា មួយតែប៉ុននុ៎ង ។

**ស៖** ឥឡូវនេះខ្ញុំចង់និយាយអំពីការធ្វើពិសោធន៍ទៅលើថ្នាំ ឬក៏ការព្យាយាមធ្វើពិសោធន៍ទៅលើថ្នាំពេទ្យ ។ លោកបានប្រាប់អង្គសវនាការថា លោកបានធ្វើដោយផ្ទាល់ដៃ ដោយលោកទទួលបញ្ជាយ៉ាងតឹងរ៉ឹងពី នួន ជា ដើម្បីឲ្យរក្សាការសម្ងាត់លើការធ្វើពិសោធន៍នេះ ។ សំណួររបស់ខ្ញុំនោះ គឺថា ដូចដែលលោកជម្រាបអង្គសវនាការថា បុគ្គលិកពីស-២១ ទទួលបានដំណឹងនេះ ហើយបាននិយាយជាមួយលោក។ ខ្ញុំដកស្រង់ចេញពីការដកសម្ដីនៅក្នុងថ្ងៃទី១៦ ខែមិថុនា ទំព័រទី២៨ ។ អ៊ីចឹង ថាតើបុគ្គលិកនៅស-២១ ទទួលបានដំណឹងអំពីការសាកល្បងលើថ្នាំនោះយ៉ាងម៉េច?

[១៦:២១:០៤]

**ឆ៖** ជម្រាបប្រសាសន៍កញ្ញា! ខ្ញុំចាំមិនភ្លេចទេរឿងនេះ ។ ខ្ញុំកាន់ថ្នាំដៃឯង បញ្ជាឲ្យគេដាក់ខ្នោះអ្នកទោសនៅនឹងចន្លោះកន្លែងថតរូប ហើយនិងកន្លែងរោងជាងគូរឆ្លាក់ ។ គ្នាប្រហែលជាបួននាក់ បើតាមខ្ញុំចាំដូចជាបួននាក់ ។ ខ្ញុំយកថ្នាំទៅឲ្យអ្នកទោសដៃឯង គេថាខ្ញុំទៅព្យាបាលអ្នកទោស ។ បើអ្នកទោសអស់ហ្នឹង អត់ឈឺផង ដូច្នេះគេជឿហើយ គេជឿថាខ្ញុំធ្វើពិសោធន៍ថ្នាំពុលទៅលើអ្នកទោស ។ គេឃើញ គេជឿ គេសន្និដ្ឋាន នេះរឿងដែលខ្ញុំបាននិយាយក្នុងប្រតិចារឹកពេលនោះ ខ្ញុំជឿថាវាមានន័យអ៊ីចឹង។ មិនបានដូចពាក្យហ្នឹងគ្រប់ម៉ាត់ទេ ។ នេះខ្ញុំសូមបញ្ជាក់ឡើងវិញ ។

**ស៖** ខ្ញុំចូលទៅដល់ចំណុចមួយទៀត ។ លោកបានរៀបរាប់រួចហើយ អំពីការបង្កើតអ្នកសួរចម្លើយស្ត្រី ថាតើអ្នកសួរចម្លើយជាស្ត្រីនោះទទួលបានការអប់រំ ថាតើធ្វើទារុណកម្ម ឬក៏សួរចម្លើយយ៉ាងម៉េចដែរឬទេ?

**ឆ៖** ធម្មតាខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ការអប់រំអំពីវិធីសួរចម្លើយទៅឲ្យកម្មាភិបាលសួរចម្លើយនៅកងពល៧០៣ ខ្ញុំបានធ្វើតែនៅក្នុងដើមសម័យស-២១ ប៉ុននុ៎ង ។ បន្ទាប់មកយកអ្នកថ្មី មើលអ្នកចាស់គេសួរ ហើយក៏ចាប់ផ្ដើមឲ្យសួរទៅ ។ អ្នកចាស់គេប្រាប់បន្តិចបន្តួចបណ្ដើរៗមក ។ ដូច្នេះ ប្រពន្ធកម្មាភិបាលទាំងអស់ ដែលខ្ញុំយកមកដាក់ឲ្យសួរចម្លើយនេះ ក៏គ្មានបានទទួលការអប់រំអីពីបច្ចេកទេសពីខ្ញុំទេ គឺទៅមើលអ្នកផ្សេងទៀតដែលសួរនុ៎ង ហើយក៏ដំណើរការទៅ ។ នេះ គឺខ្ញុំជឿជាក់ថាវាដំណើរអ៊ីចឹងកិច្ចណែនាំរបស់ខ្ញុំ គឺអ៊ីចឹងឯង ។

**ស៖** តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ? ពួកគេទាំងអស់នោះបានចូលរួមនៅក្នុង គឺនៅក្នុងសួរចម្លើយរបស់អ្នកចាស់ៗថា តើគេនឹងធ្វើចម្លើយ ធ្វើយ៉ាងម៉េចទៅលើបញ្ហាហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** មុនដំបូងអ្នកចាស់ៗគេសួរខ្លួនគេ អ្នកថ្មីទៅអង្គុយមើល ។ រួមចំណែកសួរមួយម៉ាត់ មួយកនៅពេលណាដែលគេអនុញ្ញាត ។

**ស៖** ថាតើគេចាត់តាំងអ្នកសួរចម្លើយស្ត្រីទាំងអស់នេះ ទៅដល់អ្នកចាស់ៗជាអ្នកសួរចម្លើយម្នាក់ ឬក៏អ្នកសួរចម្លើយស្ត្រីនីមួយៗនេះ ទៅជាមួយអ្នកចាស់ៗម្នាក់ ឬក៏ទៅទាំងក្រុមតែម្តង?

**ឆ៖** បើតាមខ្ញុំចាំ រឿងនេះវាឆ្នាំហើយ ។ បើតាមខ្ញុំចាំស្ត្រីទាំងប្រាំនាក់នេះ ទៅទាំងក្រុម ទៅមើលមនុស្សម្នាក់ ហើយក្រោយមកទៅមើលមនុស្សម្នាក់ទៀត ពីរបីនាក់ទៅសួរចម្លើយ ។ នេះ ខ្ញុំបញ្ជាក់ជូនកញ្ញាប៉ុណ្ណេះថា កម្មាភិបាលស្រីៗ សួរចម្លើយស្រីសុទ្ធតែប្រពន្ធមេ ។ ប្រពន្ធមិត្តហ៊ា, ប្រពន្ធមិត្តហ៊ុយ, ប្រពន្ធមិត្តប៉ុន សុទ្ធតែប្រពន្ធមេ ។ ដូច្នេះ អ្នកសួរចម្លើយចាស់ អ្នកសួរចម្លើយពីមុនៗមក ចង់ដែរចង់បង្ហាញឲ្យប្រពន្ធមេវាឃើញ ថាខ្លួនយកចិត្តទុកដាក់ដល់ប្រពន្ធមេប៉ុនណា ជួយប្រពន្ធមេយ៉ាងម៉េច ។ នេះខ្ញុំសូមបញ្ជាក់ប៉ុណ្ណឹងថែម ។

[១៦:២៦:០៥]

**ប្រធានអង្គជំនុំ៖**

ឥឡូវដល់ម៉ោងត្រូវសម្រាកនៅពេលល្ងាចហើយ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការដេញដោលសម្រាប់ថ្ងៃនេះត្រឹមនេះ។ អង្គសវនាការលើកទៅបន្តសវនាការនៅថ្ងៃស្អែកចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ។ អ៊ីចឹងជម្រាបជូនភាគីឲ្យបានជ្រាប ។ អនុរក្សមន្ទីរឃុំឃាំងឲ្យនាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំង ហើយឲ្យនាំគាត់មកកាន់បន្ទប់សវនាការនៅថ្ងៃស្អែកឲ្យបានមុនម៉ោងបួនជាកំណត់ ។

*[សវនាការផ្អាកនៅម៉ោង ១៦:២៧នាទី]*